


This is an informal translation of the Framework of Analysis for Atrocity Crimes undertaken by our Country Partners Cambodian Institute for Co-operation and Peace (CICP) and supported by the Asia Pacific centre for the Responsibility to Protect APR2P.Our translations aim to support countries in the Asia Pacific to improve early warning and monitoring for risk assessment for Atrocity crimes. All reasonable efforts have been made to ensure this is an accurate translation The Khmer version is a translation of the original in English for information purposes only. In case of a discrepancy, the English original will prevail.

CAMBODIAN INSTITUTE FOR COOPERATION AND PEACE

Asia-Pacific Centre for the Responsibility to Protect

Informal Translation

# Framework of Analysis For ATROCITY CRIMES

## A tool for prevention

United Nations, 2014

# ក្របខ័ណ្ឌនៃការវិភាគអំពីឧក្រិដ្ឋកម្មឃោរឃៅ

## វិធានសម្រាប់ការបង្ការ

អង្គការសហប្រជាជាតិ ២០១៤

# Foreword បុព្វកថា

## by the Secretary-General of the United Nations

ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ

All of us have a responsibility to ask ourselves what we can do to protect populations from the most serious international crimes: genocide, crimes against humanity and war crimes. These crimes continue to be perpetrated in many places across the world. Although calls for accountability are now the norm when such crimes are committed, impunity is all too common. We can and must do more, much earlier, to save lives and prevent societies from collapsing and descending into horrific violence.

យើងទាំងអស់គ្នាមានការទទួលខុសត្រូវក្នុងការសួរខ្លួនឯងថាតើមានអ្វីដែលយើងអាចធ្វើបានដើម្បីការពារប្រជាជនពីឧក្រិដ្ឋកម្មអន្តរជាតិដ៏ធ្ងន់ធ្ងរបំផុតដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ឧក្រិដ្ឋកម្មទាំងនេះនៅតែបន្តកើតមាននៅកន្លែងជាច្រើន ទូទាំងពិភពលោក។ ទោះបីជាមានការអំពាវនាវឱ្យមានការទទួលខុសត្រូវក្លាយជាបទដ្ឋាននៅពេលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តក៏ដោយ ក៏និទណ្ឌភាពគឺនៅតែកើតមានឡើងជាដដែលៗ។ យើងអាច និងត្រូវធ្វើឱ្យបានច្រើនថែមទៀត ឱ្យបានឆាប់រហ័ស ដើម្បីសង្គ្រោះជីវិតនិងបង្ការកុំឱ្យសង្គមបែកបាក់និងធ្លាក់ចូលទៅក្នុងអំពើហិង្សាដ៏គួរឱ្យរន្ធត់នេះ។

The first thing we can do is to be more alert and pay attention to the warning signs. Atrocity crimes take place on a large scale, and are not spontaneous or isolated events; they are processes, with histories, precursors and triggering factors which, combined, enable their commission.

រឿងដំបូងដែលយើងអាចធ្វើបានគឺត្រូវប្រុងប្រយ័ត្ន និង យកចិត្តទុកដាក់បន្ថែមទៀត លើសញ្ញាព្រមាន។ ឧក្រិដ្ឋកម្មឃោរឃៅកើតឡើង ក្នុងទ្រង់ទ្រាយធំ ហើយមិនមែនជាព្រឹត្តិការណ៍ដែលកើតឡើងដោយឯកឯងនោះឡើយ។ ឧក្រិដ្ឋកម្មទាំងនេះគឺជាដំណើរការដែលមានដំណើរដើមទង និងកត្តាបង្កហេតុ ដែលរួមបញ្ចូល គ្នាបង្កើតបានជាការប្រព្រឹត្តបទឧក្រិដ្ឋ។

My Special Advisers on the Prevention of Genocide and on the Responsibility to protect have developed this Framework of Analysis for the Prevention of Atrocity Crimes as a guide for assessing the risk of genocide, crimes against humanity and war crimes. With the help of the Framework, we can better sound the alarm, promote action, improve monitoring or early warning by different actors, and help Member States to identify gaps in their atrocity prevention capacities and strategies.

ក្រុមទីប្រឹក្សាពិសេសរបស់ខ្ញុំផ្នែកទប់ស្កាត់អំពើប្រល័យពូជសាសន៍ និង ទំនួលខុសត្រូវក្នុងការការពារ បានបង្កើតក្របខ័ណ្ឌនៃការវិភាគសម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនេះ សម្រាប់ជាមគ្គុទេសក៍ដើម្បីវាយតម្លៃហានិភ័យនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ដោយមានជំនួយពីក្របខ័ណ្ឌនេះ យើងអាចប្រកាសឱ្យមានការប្រុងប្រយ័ត្នជាងមុន ជំរុញឱ្យមានសកម្មភាព និង ធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ ឬ ការព្រមានជាមុនដោយភាគីផ្សេងៗ និងជួយដល់រដ្ឋជាសមាជិកក្នុងការកំណត់ពីការខ្វះចន្លោះ ទាក់ទងសមត្ថភាពនិងយុទ្ធសាស្រ្តក្នុងការទប់ស្កាត់អំពើឃោរឃៅនេះ។

I am pleased to present this Framework at a time when the United Nations is undergoing a system-wide revision of the way we respond to situations where serious violations of international human rights and humanitarian law are happening or could happen. Through the "Human Rights Up Front" initiative, we are committed to upholding the promise of "never again" and drawing lessons from past failures. In practice, it means putting human rights, the protection of populations and the prevention of atrocity crimes at the centre of our work.

ខ្ញុំមានសេចក្តីរីករាយណាស់ក្នុងការដាក់បង្ហាញនូវក្របខ័ណ្ឌនេះនៅចំពេលដែលអង្គការសហប្រជាជាតិកំពុងពិនិត្យឡើងវិញអំពីប្រព័ន្ធទាំងមូល នូវរបៀបដែលយើងឆ្លើយតបចំពោះស្ថានភាពដែល មានការរំលោភបំពានធ្ងន់ធ្ងរចំពោះច្បាប់សិទ្ធិមនុស្សនិងមនុស្សធម៌អន្តរជាតិដែលកំពុងកើតឡើងឬអាចកើតឡើង។ តាមរយៈគំនិតផ្តួចផ្តើម "សិទ្ធិមនុស្សជាគោល" យើងប្តេជ្ញាធ្វើតាមការសន្យា "មិនឱ្យកើតមានទៀតជាដាច់ខាត" និងសិក្សាបទពិសោធន៍ពី ការបរាជ័យពីអតីតកាល។ នៅក្នុងការអនុវត្តជាក់ស្តែង វាមានន័យថាការដាក់សិទ្ធិមនុស្ស ការការពារប្រជាពលរដ្ឋ និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅជាការងារស្នូលរបស់យើង។

As affirmed at the 2005 World Summit, States havethe primary responsibility for protecting their own populations from genocide, war crimes, ethnic cleansing and crimes against humanity. The international community has committed to support each State in this endeavour and, should States manifestly fail in meeting their responsibilities, to take collective action in a timely and decisive manner in line with the United Nations Charter.

ដូចដែលបានអះអាងក្នុងកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ២០០៥ រដ្ឋមានទំនួលខុសត្រូវចម្បងក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សហគមន៍អន្តរជាតិបានប្តេជ្ញាគាំទ្ររដ្ឋនីមួយៗនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះហើយប្រសិនបើរដ្ឋណាមួយមិនបានបំពេញភារកិច្ចរបស់ខ្លួនទេនោះ ត្រូវចាត់វិធានការរួមគ្នាឱ្យបានទាន់ពេលវេលានិងប្រកបដោយការសម្រេចចិត្តច្បាស់លាស់ ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ។

I therefore urge the widest possible use of this Framework to support prevention strategies at the national, regional and international levels. Prevention means acting early; to do that, we need to know what to look for. Together with a commitment to account- ability, we owe this to the millions of victims of the horrific international crimes of the past — and those whose lives we may be able to save in the future.

ដូច្នេះខ្ញុំសូមជំរុញឱ្យប្រើប្រាស់ក្របខ័ណ្ឌនេះឱ្យបានទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបានដើម្បីគាំទ្រដល់យុទ្ធសាស្ត្របង្ការនានានៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។ ការបង្ការមានន័យថាការធ្វើសកម្មភាពទុកជាមុន។ ដើម្បីធ្វើដូចនេះបាន យើងត្រូវដឹងពីអ្វីដែលយើងត្រូវស្វែងរក។ រួមជាមួយការប្តេជ្ញាចិត្តចំពោះការទទួលខុសត្រូវ យើងត្រូវធ្វើអ្វីៗដើម្បីជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិដ៏គួរឱ្យរន្ធត់ពីអតីតកាលរាប់លាននាក់ និងអ្នកដែលមានជីវិតរស់នៅដែលយើងអាចជួយសង្គ្រោះបាននាពេលអនាគត។

BAN Ki-moon
United Nations Secretary-General July 2014

បាន គីមូន

អគ្គលេខាធិការអង្គការសហប្រជាជាតិ

ខែកក្កដាឆ្នាំ ២០១៤

## មាតិកា

**បុព្វកថាដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ**

**ការណែនាំពីក្របខ័ណ្ឌនៃការវិភាគ**

តើឧក្រិដ្ឋកម្មឃោរឃៅ មានន័យយ៉ាងដូចម្តេចចំពោះយើង?

តើនរណាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មឃោរឃៅ?

ហេតុអ្វីបានជាការបង្ការឧក្រិដ្ឋកម្មអំពើឃោរឃៅមានសារៈសំខាន់?

តើមានការទទួលខុសត្រូវផ្នែកច្បាប់ក្នុងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅឬទេ?

តើឧក្រិដ្ឋកម្មឃោរឃៅអាចនឹងត្រូវបានទប់ស្កាត់ដោយរបៀបណា?

តើតួនាទីរបស់ក្រុមប្រឹក្សាពិសេសសម្រាប់ការទប់ស្កាត់ការប្រល័យពូជសាសន៍និងទំនួលខុសត្រូវក្នុងការការពារមានអ្វីខ្លះ?

តើក្របខ័ណ្ឌនៃការវិភាគនេះគឺជាអ្វី?

តើកត្តានិងសូចនាករហានិភ័យគឺជាអ្វី?

របៀបក្នុងការប្រើក្របខ័ណ្ឌនៃការវិភាគ

តើការវាយតម្លៃហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅមានសុក្រិតភាពកម្រិតណា?

**ក្របខ័ណ្ឌនៃការវិភាគសម្រាប់ឧក្រិដ្ឋកម្មឃោរឃៅ**

កត្តាហានិភ័យទូទៅ

- កត្តាហានិភ័យ1៖ ស្ថានការណ៍ក្នុងជម្លោះប្រដាប់អាវុធឬទម្រង់ផ្សេងៗទៀតនៃអស្ថិរភាព
- កត្តាហានិភ័យ2៖ កំណត់ត្រានៃការរំលោភច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិធ្ងន់ធ្ងរ
- កត្តាហានិភ័យ3៖ ភាពទន់ខ្សោយនៃរចនាសម្ព័ន្ធរដ្ឋ
- កត្តាហានិភ័យ4៖ មូលហេតុ ឬ កត្តាជំរុញទឹកចិត្ត
- កត្តាហានិភ័យ5៖ លទ្ធភាពក្នុងប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ
- កត្តាហានិភ័យ6៖ អវត្តមាននៃកត្តាកាត់បន្ថយ
- កត្តាហានិភ័យ7៖ កាលៈទេសៈអំណោយផល ឬ សកម្មភាពរៀបចំទុកជាមុន
- កត្តាហានិភ័យ8៖ កត្តាបង្កហេតុ

កត្តាហានិភ័យជាក់លាក់

- កត្តាហានិភ័យ9៖ ភាពតានតឹងអន្តរក្រុម ឬ លំនាំគំរូនៃការរើសអើងមកលើក្រុមដែលត្រូវបានការពារ
- កត្តាហានិភ័យ10៖ សញ្ញានៃចេតនាក្នុងការបំផ្លាញទាំងមូលឬផ្នែកនៃក្រុមដែលត្រូវបានការពារ
- កត្តាហានិភ័យ11៖ សញ្ញានៃការវាយប្រហាររីករាលដាលនិងជាប្រព័ន្ធ មកលើក្រុមប្រជាជនស៊ីវិល
- កត្តាហានិភ័យ12៖ សញ្ញានៃផែនការ ឬ គោលនយោបាយវាយប្រហារមកលើក្រុមប្រជាជនស៊ីវិល
- កត្តាហានិភ័យ13៖ ការគំរាមកំហែងធ្ងន់ធ្ងរលើជនដែលត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិ
- កត្តាហានិភ័យ14៖ ការគំរាមកំហែងធ្ងន់ធ្ងរដល់ប្រតិបត្តិការមនុស្សធម៌ឬរក្សាសន្តិភាព

**ឧបសម្ព័ន្ធ 1៖និយមន័យផ្លូវច្បាប់នៃឧក្រិដ្ឋកម្មឃោរឃៅ**

**Atrocity crimes are considered to be the most serious crimes against humankind. Their status as international crimes is based on the belief that the acts associated with them affect the core dignity of human beings.**

ឧក្រិដ្ឋកម្មឃោរឃៅត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏ធ្ងន់ធ្ងរបំផុត។ ការចាត់ទុកឧក្រិដ្ឋកម្មនេះជាឧក្រិដ្ឋកម្មអន្តរជាតិគឺផ្អែកលើជំនឿថាសកម្មភាពទាំងឡាយណាពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្មនេះគឺប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរស្នូលរបស់មនុស្ស។

# I. INTRODUCING THEFRAMEWORK OF ANALYSIS

# I. ការណែនាំអំពីក្របខ័ណ្ឌនៃការវិភាគ

## What do we mean by atrocity crimes?

### តើឧក្រិដ្ឋកម្មឃោរឃៅ មានន័យយ៉ាងដូចម្តេចចំពោះយើង?

The term “atrocity crimes” refers to three legally defined international crimes: **genocide**, **crimes against humanity** and **war crimes**. The definitions of the crimes can be found in the 1948 Convention on the Prevention and Punishment of the Crime of Genocide, the 1949 Geneva Conventions1 and their 1977 Additional Protocols,2 and the 1998 Rome Statute of the International Criminal Court, among other treaties.3

ពាក្យ “ឧក្រិដ្ឋកម្មឃោរឃៅ” សំដៅទៅលើឧក្រិដ្ឋកម្មបី ដែលមានចែងក្នុងច្បាប់អន្តរជាតិ៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ និយមន័យនៃឧក្រិដ្ឋកម្មទាំងបីនេះ មាននៅក្នុងអនុសញ្ញាឆ្នាំ1948 ស្តីពីការបង្ការ និង ការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ1949១ និង អនុស្សរណៈបន្ថែមឆ្នាំ1977២ និង លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ1998 និងសន្ធិសញ្ញាផ្សេងទៀត៣។

In the 2005 World Summit Outcome Document (paragraphs 138 and 139), United Nations Member States made a commitment to protect populations from genocide, war crimes, ethnic cleansing and crimes against humanity, a principle referred to as the “Responsibility to Protect”. In this context, the term “atrocity crimes” has been extended to include **ethnic cleansing** which, while not defined as an independent crime under international law, includes acts that are serious violations of international human rights and humanitarian law that may themselves amount to one of the recognized atrocity crimes, in particular crimes against humanity.4

ក្នុង ឯកសារលទ្ធផលកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ 2005 (កថាខណ្ឌ 138 និង 139) សមាជិកអង្គការសហប្រជាជាតិ បានធ្វើការប្តេជ្ញាការពារប្រជាជន ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ក្រោមគោលការណ៍ “ទំនួលខុសត្រូវក្នុងការការពារ”។ ក្នុងបរិបទនេះ “ឧក្រិដ្ឋកម្មឃោរឃៅ” ត្រូវបានពង្រីកដើម្បីរាប់បញ្ចូលការលុបបបាត់ជាតិសាសន៍ ដែលទោះមិនបានកំណត់ថាជា ឧក្រិដ្ឋកម្មដាច់ដោយឡែកក្រោមច្បាប់អន្តរជាតិក៏ដោយ តែមានរាប់បញ្ចូល សកម្មភាពដែលរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ ដែលអាចត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មឃោរឃៅ ជាពិសេសឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ៤។

1 The Geneva Conventions comprise the 1949 Geneva Convention (I) for the Amelioration of the Condition of the Wounded and Sick in Armed Forces in the Field; the 1949 Geneva Convention (II) for the Amelioration of the Condition of Wounded, Sick and Shipwrecked Members of Armed Forces at Sea; the 1949 Geneva Convention (III) relative to the Treatment of Prisoners of War; and the 1949 Geneva Convention (IV) relative to the Protection of Civilian Persons in Time of War.

១ អនុសញ្ញាទីក្រុងហ្សឺណែវរួមមានអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ 1949 (1) សម្រាប់ការកែលម្អស្ថានភាពរបស់អ្នករងរបួសអ្នកជំងឺក្នុងកងកម្លាំងប្រដាប់អាវុធក្នុងសមរភូមិ; អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ1949 (2) សម្រាប់ការកែលម្អស្ថានភាពរបស់កងកម្លាំងប្រដាប់អាវុធដែលរងរបួស មានជំងឺ និងរងគ្រោះដោយការលិចកប៉ាល់នៅសមុទ្រ។ ; អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ 1949 (3) ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើឈ្លើយសឹក និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ 1949 (4) ទាក់ទងទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម។

2 The Additional Protocols comprise the 1977 Protocol Additional to the Geneva Conventions of 12 August 1949, and relating to the Protection of Victims of International Armed Conflicts (Protocol I); and the 1977 Protocol Additional to the Geneva Conventions of 12 August 1949, and relating to the Protection of Victims of Non-International Armed Conflicts (Protocol II).

២ អនុស្សរណៈបន្ថែមរួមមានអនុស្សរណៈបន្ថែមឆ្នាំ១៩៧៧ លើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី 12 ខែសីហាឆ្នាំ 1949 និងដែលទាក់ទងទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធលក្ខណៈអន្តរជាតិ (អនុស្សរណៈ 1) និង អនុស្សរណៈបន្ថែមឆ្នាំ១៩៧៧ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី 12 ខែសីហាឆ្នាំ 1949 និងទាក់ទងទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធលក្ខណៈមិនអន្តរជាតិ (អនុស្សរណៈ 2) ។

3 For definitions of each of the crimes, consult Annex I.

៣ និយមន័យនៃឧក្រិដ្ឋកម្មនីមួយៗ សូមមើលឧបសម្ព័ន្ធ I។

៤ For possible definitions of ethnic cleansing, consult Annex I.

និយមន័យមួយចំនួននៃការលុបបំបាត់ជាតិសាសន៍ សូមមើលឧបសម្ព័ន្ធ I។

**Who are the victims of atrocity crimes?** Atrocity crimes are considered to be the most serious crimes against humankind. Their status as international crimes is based on the belief that the acts associated with them affect the core dignity of human beings, in particular the persons that should be most protected by States, both in times of peace and in times of war. However, the victims targeted by acts of genocide, crimes against humanity and war crimes differ.

**តើនរណាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មឃោរឃៅ?**

ឧក្រិដ្ឋកម្មឃោរឃៅត្រូវបានគេចាត់ទុកថាជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតទៅលើមនុស្សជាតិ។ ក្នុងច្បាប់អន្តរជាតិ ឧក្រិដ្ឋកម្មនេះត្រូវបានគេផ្អែកលើជំនឿថាទង្វើដែលពាក់ព័ន្ធដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរស្នូលរបស់មនុស្សជាតិ ជាពិសេសមនុស្សដែលគួរត្រូវបានការពារជាងគេដោយរដ្ឋនានា ទាំងនៅក្នុងពេលមានសន្តិភាពនិងពេលមានសង្គ្រាម។ តែជនរងគ្រោះដែលត្រូវបានកំណត់គោលដៅ ដោយអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម គឺខុសៗគ្នា។

**Genocide**, according to international law, is a crime committed against members of a national, ethnical, racial or religious group. Even though the victims of the crimes are individuals, they are targeted because of their membership, real or perceived, in one of these groups. When speaking about potential victims of gen- ocide, the Framework will refer to them as "**protected groups**".

**អំពើប្រល័យពូជសាសន៍** បើយោងតាមច្បាប់អន្តរជាតិ គឺជាបទឧក្រិដ្ឋដែលបានប្រព្រឹត្តមកលើសមាជិកនៃរដ្ឋ ជាតិសាសន៍ ក្រុមសាសនា ឬ ពូជសាសន៍ណាមួយ។ ទោះបីជាជនរងគ្រោះនៃឧក្រិដ្ឋកម្មជាបុគ្គលក៏ដោយ ក៏ពួកគេត្រូវក្លាយជាគោលដៅដោយសារតែសមាជិកភាពរបស់ខ្លួនមិនថាស្ថិតក្នុងក្រុមមួយដែលបានរៀបរាប់ខាងលើឡើយ ទោះជាពិតឬជាការគិត ។ នៅពេលដែលនិយាយអំពីជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ក្របខ័ណ្ឌនេះ គឺសំដៅដល់ពួកគេថាជា "**ក្រុមត្រូវបានការពារ**" ។

**Crimes against humanity** encompass acts that are part of a widespread or systematic attack directed against any civilian population. Even if non-civilians might also become victims of the attack, for an act to be considered a crime against humanity, the ultimate target of the attack must be the civilian population. When speaking about potential victims of crimesagainst humanity, the Framework will refer to them asa "**civilian population**".

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**រួមមានអំពើដែលជាផ្នែកមួយនៃការវាយប្រហារដ៏រាលដាល ឬ ជាប្រព័ន្ធ សំដៅលើក្រុមប្រជាជនស៊ីវិលណាមួយ។ បើទោះបីជាជានរងគ្រោះនៃការវាយប្រហារមិនមែនជាជនស៊ីវិលក៏ដោយ តែបើជាជនរងគ្រោះចុងក្រោយជាជនស៊ីវិល នោះការវាយប្រហារនេះនឹងត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ។ នៅពេលដែលនិយាយអំពីជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្របខ័ណ្ឌនេះសំដៅដល់ពួកគេថាជា "**ប្រជាជនស៊ីវិល**"។

**War crimes** can be committed against a diversity of victims, either combatants or non-combatants. In inter- national armed conflicts, victims include those specifically protected by the four 1949 Geneva Conventions, i.e., (1) the wounded and sick in armed forces in the field; (2) the wounded, sick and shipwrecked members of armed forces at sea; (3) prisoners of war; and (4) civilian persons. It also includes those protected under the 1977 Additional Protocol I. In the case of non- international armed conflicts, common Article 3 of the four 1949 Geneva Conventions affords protection to "persons taking no active part in the hostilities, including members of armed forces who have laid down their arms and those placed 'hors de combat' by sickness, wounds, detention, or any other cause". It also includes those protected under the 1977 Additional Protocol I. Protection under international humanitarian law in both types of conflicts covers medical and religious personnel, humanitarian workers and civil defence staff. When speaking about potential victims of war crimes, the Framework will refer to them as "**those protected under international humanitarian law**".

**ឧក្រិដ្ឋកម្មសង្គ្រាម** អាចនឹងប្រព្រឹត្តមកលើជនរងគ្រោះចម្រុះ ដែលអាចជាយុទ្ធជនឬ ជនមិនមែនជាយុទ្ធជន។ នៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ជនរងគ្រោះរួមមាន ក្រុមដែលត្រូវបានការពារ ដោយអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ 1949 ឧទាហរណ៍ (1) កងកម្លាំងប្រដាប់អាវុធដែលរងរបួស និងអ្នកមានជំងឺក្នុងសមរភូមិ (2) កងកម្លាំងប្រដាប់អាវុធដែលរងរបួស អ្នកជំងឺ និងជនរងគ្រោះដោយសារលិចកប៉ាល់នៅសមុទ្រ (3) ឈ្លើយសឹក និង (4) ជនស៊ីវិល។ រួមបញ្ចូលទាំងអ្នកដែលត្រូវបានការពារនៅក្នុងអនុស្សរណៈបន្ថែម (I) ឆ្នាំ1977។ ក្នុងករណីជម្លោះប្រដាប់អាវុធលក្ខណៈមិនអន្តរជាតិ ក្នុងមាត្រា3 នៃអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ1949 ទាំងបួន ផ្តល់ការការពារដល់ "មនុស្សដែលមិនបានចូលរួមយ៉ាងសកម្មក្នុងជម្លោះ នេះរួមទាំងសមាជិកកងកម្លាំងប្រដាប់អាវុធដែលបានដាក់អាវុធចុះនិងអ្នកដកខ្លួនចេញពីការប្រយុទ្ធដោយជំងឺ របួស ការឃុំខ្លួន ឬមូលហេតុផ្សេងទៀតណាមួយ"។ នេះរួមបញ្ចូលទាំងជនដែលបានការពារនៅក្រោមអនុស្សរណៈបន្ថែម (I) ឆ្នាំ1977។ ក្រោមច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងប្រភេទជម្លោះទាំងពីរ រាប់បញ្ចូលទាំង ក្រុមវេជ្ជសាស្រ្តនិងសាសនា ក្រុមមនុស្សធម៌ និងអ្នកការពារជាជនស៊ីវិល។ នៅពេលដែលនិយាយអំពីជនរងគ្រោះដែលអាចក្លាយជាគោលដៅនៃឧក្រិដ្ឋកម្មសង្គ្រាម ក្របខ័ណ្ឌនេះ គឺសំដៅដល់ពួកគេថាជា "**ជនដែលត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិ**"។

Due to the diversity of types of victims of the three crimes, when speaking broadly about potential victims of atrocity crimes as protected by international law, the Framework will refer to them as "**protected groups, populations or individuals**".

ដោយសារតែជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងបីនេះមានច្រើនប្រភេទ ពេលនិយាយពីជនរងគ្រោះទូទៅដែលអាចជាគោលដៅនៃឧក្រិដ្ឋកម្មឃោរឃៅដែលបានការពារក្រោមច្បាប់អន្តរជាតិ ក្របខ័ណ្ឌនេះ គឺសំដៅសល់ពួកគេថាជា "**ក្រុម ប្រជាជន ឬបុគ្គលដែលត្រូវដែលបានការពារ**" ។

## Why is it important to prevent atrocity crimes?

### ហេតុអ្វីបានជាការទប់ស្កាត់ឧក្រិដ្ឋកម្មអំពើឃោរឃៅមានសារៈសំខាន់?

One of the principal roles of the United Nations Special Advisers on the Prevention of Genocide and on the Responsibility to Protect is to mobilize action for the prevention of atrocity crimes. The first and most compelling reason for this focus is the imperative to **preserve human life**. Atrocity crimes are, for the most part, large-scale events that, if prevented, will avoid significant loss of human life, as well as physical, psychosocial and psychological damages and trauma. However, there are also other significant reasons to focus on prevention.

តួនាទីសំខាន់មួយរបស់ក្រុមទីប្រឹក្សាពិសេសអង្គការសហប្រជាជាតិក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និង ទំនួលខុសត្រូវក្នុងការការពារ គឺដើម្បីប្រមូលផ្តុំសកម្មភាពសម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ មូលហេតុទីមួយនិងចម្បងបំផុតសម្រាប់ការផ្តោតលើកិច្ចការនេះគឺដើម្បី **រក្សាអាយុជីវិតមនុស្ស** ដែលជាកិច្ចការចាំបាច់បំផុត។ ឧក្រិដ្ឋកម្មឃោរឃៅ ភាគច្រើនគឺជាព្រឹត្តិការណ៍ទ្រង់ទ្រាយធំ ដែលប្រសិនបើបើទប់ស្កាត់បានគឺ អាចជួសង្គ្រោះជីវិតមនុស្ស និង ចៀសវាងបាននូវការខូចខាតនិងការរបួសផ្លូវកាយ ផ្លូវចិត្ត និងភាពបាក់ស្បាត។ បន្ថែមពីលើនេះ ក៏មានមូលហេតុជាច្រើនទៀតដែលយើងត្រូវផ្តោតទៅលើការទប់ស្កាត់ផងដែរ។

Atrocity crimes tend to occur in countries with some level of instability or crisis. Consequently, measures taken to prevent these crimes are likely to contribute to **national peace and stability**. Prevention also serves the larger agenda of **regional and international peace and stability**. Atrocity crimes and their consequences can spill over into neighbouring countries by, for example, creating or reinforcing tensions between groups that are defined along religious or ethnic lines rather than by national borders. The United Nations Security Council has stated in several of its resolutions that serious and gross breaches of international human rights and humanitarian law constitute threats to international peace and security. The preamble to the Rome Statute of the International Criminal Court also states that international crimes “threaten the peace, security and well-being of the world”.

ឧក្រិដ្ឋកម្មឃោរឃៅច្រើនតែកើតមានឡើងនៅក្នុងប្រទេសដែលមានអស្ថិរភាព ឬមានវិបត្តិក្នុងកម្រិតណាមួយ។ ដូច្នេះហើយ វិធានការដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះគឺអាចជួយដល់**សន្តិភាពនិងស្ថិរភាពថ្នាក់ជាតិ** ទាំងមូល។ ការទប់ស្កាត់ក៏ជួយដល់របៀបវារៈធំៗនៃ**សន្តិភាពនិងស្ថិរភាពក្នុងតំបន់និងអន្តរជាតិ**ផងដែរ។ ឧក្រិដ្ឋកម្មឃោរឃៅនិងផលវិបាករបស់វាអាចឆ្លងទៅប្រទេសជិតខាង ឧទាហរណ៍ ការបង្កើតឬការបន្ថែមភាពតានតឹងរវាងក្រុមដែលប្រកាន់អត្តសញ្ញាណលើសាសនាឬជាតិសាសន៍ ជាជាងខ្សែបន្ទាត់ព្រំដែនរបស់ប្រទេស។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានថ្លែងនៅក្នុងសេចក្តីសម្រេចមួយចំនួនរបស់ខ្លួនថាការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌ គឺចាត់ទុកថាជាការគំរាមកំហែងដល់សន្តិភាពនិងសន្តិសុខអន្តរជាតិ។ សេចក្តីផ្តើមនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ថាឧក្រិដ្ឋកម្មអន្តរជាតិ “ជាការគំរាមកំហែងដល់សន្តិភាពសន្តិសុខនិងសុខុមាលភាពរបស់ពិភពលោកទាំងមូល”។

A further key reason for focusing on the prevention of atrocity crimes lies in the fact that prevention is **much less costly** than intervening to halt these crimes, or dealing with their aftermath. Wars, humanitarian crises, the rebuilding of nations and the building of sustainable peace after conflict require high and sustained levels of international support, often over many years. The political cost and challenges of early engagement by the international community are also less than when crises are imminent or ongoing, by which time options for preventive action are much more limited and there is a greater likelihood of political stalemate and failure.

មូលហេតុសំខាន់មួយទៀតសម្រាប់ការផ្តោតលើការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅគឺត្រូវការការចំណាយ**តិចជាង**ការធ្វើអន្តរាគមន៍ច្រើនណាស់ដើម្បីបញ្ឈប់ឧក្រិដ្ឋកម្ម ឬដោះស្រាយជាមួយនឹងបញ្ហាដែលកើតឡើងរួចមកហើយ។ សង្គ្រាម វិបត្តិមនុស្សធម៌ធ្ងន់ធ្ងរ ការកសាងប្រទេសជាតិឡើងវិញ និងការកសាង សន្តិភាពប្រកបដោយនិរន្តរភាពបន្ទាប់ពីមានជម្លោះ គឺទាមទារឱ្យមានការគាំទ្រពីអន្តរជាតិខ្ពស់ និងបន្តជាប់ជាច្រើនឆ្នាំ។ បញ្ហាប្រឈម និងតម្លៃនយោបាយក្នុងការចូលរួមរបស់សហគមន៍អន្តរជាតិនៅដំណាក់កាលដំបូង គឺមានតម្រូវការតិច បើប្រៀបធៀបទៅនឹងការជួយនៅពេលវិបត្តិរៀបនឹងកើតទៅហើយ ឬកំពុងបន្ត ព្រោះពេលនោះពេលវេលាសម្រាប់ការទប់ស្កាត់គឺមានតិច ហើយឱកាសក្នុងការជាប់គាំងផ្នែកនយោបាយនិងការបរាជ័យគឺមានច្រើន។

Finally, by taking measures to prevent atrocity crimes and fulfilling their primary responsibility to protect, **States reinforce their sovereignty** and reduce the need for more intrusive forms of response from other States or international actors. As the United Nations Secretary-General has emphasized, the principle of the Responsibility to Protect is designed to be an ally of sovereignty, rather than to undermine it. Efforts by States to prevent atrocity crimes from being commit- ted within their own borders are another way of fulfilling their sovereign responsibilities.

ជាចុងក្រោយ ការដាក់វិធានការដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនិងការបំពេញនូវទំនួលខុសត្រូវក្នុងការការពាររបស់រដ្ឋាភិបាលជា**ការពង្រឹងអធិបតេយ្យភាពរបស់ខ្លួន** និអាចកាត់បន្ថយការលូកដៃចូលពីបរទេស ឬភាគីអន្តរជាតិ។ ដូចដែល លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានបញ្ជាក់ហើយថា គោលការណ៍នៃទំនួលខុសត្រូវក្នុងការការពារ ត្រូវបានរៀបចំឡើងដើម្បីជាសម្ពន្ធមិត្ត របស់អធិបតេយ្យភាព មិនមែនដើម្បីធ្វើឱ្យអន្តរាយទេ។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋផ្សេងៗក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅក្នុងព្រំដែនរបស់ខ្លួនគឺជាទំនួលខុសត្រូវក្នុងដែនអធិបតេយ្យភាពរបស់រដ្ឋ។

## Is there a legal responsibility to prevent atrocity crimes?

### តើមានទំនួលខុសត្រូវផ្នែកច្បាប់ក្នុងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅឬទេ?

Apart from the moral and ethical responsibility that we all have to protect populations at risk of atrocity crimes, both individually and collectively, there are also **well-established legal obligations** to do so. Such obligations can be found in the Convention on the Prevention and Punishment of the Crime of Genocide, in international human rights and humanitarian law and in customary international law. International courts and tribunals have also cited these obligations and clarified their specific content.

ក្រៅពីការទទួលខុសត្រូវខាងសីលធម៌ ដែលយើងទាំងអស់គ្នាត្រូវការពារប្រជាជនដែលប្រឈមនឹងហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅ ទាំងបុគ្គលនិងជាសមូហភាពនោះ ក៏មាន**កាតព្វកិច្ចផ្លូវច្បាប់ដែលមានគ្រឹះរឹងមាំ** ដែរ។ កាតព្វកិច្ចទាំងនេះគឺមានចែងនៅក្នុងអនុសញ្ញាស្ដីពីការបង្ការ និង ការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ និងនៅក្នុងច្បាប់អន្តរជាតិដែលមានស្រាប់។ តុលាការនិងសាលាក្ដីអន្តរជាតិក៏ធ្លាប់បានលើកឡើងអំពីកាតព្វកិច្ច និងបានបញ្ជាក់អំពីខ្លឹមសារជាក់លាក់រួចមកហើយ។

The responsibilities that fall on States through ratified treaties or customary law entail an obligation not only to punish atrocity crimes but also to prevent them. In some cases, such as for the crime of genocide, the obligation to prevent contained in the Convention on the Prevention and Punishment of the Crime of Genocide (Article I) has become a norm of customary international law, which means that it is mandatory for all States, regardless of whether they have ratified the Convention. The obligation to "respect and ensure respect for international humanitarian law", as contained in common Article 1 of the Geneva Conventions, is also considered to be a norm of customary international law. This provision can be interpreted as including an obligation to prevent violations of international humanitarian law, including war crimes.

តាមរយៈសន្ធិសញ្ញាដែលបានទទួលសច្ចាប័នរួចហើយ ឬ ច្បាប់ប្រពៃណីដែលមានស្រាប់ បានដាក់ទំនួលខុសត្រូវលើរដ្ឋ មិនត្រឹមតែការដាក់ទោសទណ្ឌប៉ុណ្ណោះទេថែមទាំងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅផងដែរ។ ក្នុងករណីមួយចំនួន ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ កាតព្វកិច្ចក្នុងការទប់ស្កាត់បានចែងនៅក្នុងអនុសញ្ញាស្ដីពីការបង្ការ និង ការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (មាត្រា ១) បានក្លាយជាបទដ្ឋាននៃច្បាប់អន្តរជាតិដែលមានស្រាប់ មានន័យថាវាជាការតម្រូវសម្រាប់រដ្ឋទាំងអស់ ដោយមិនគិតថា តើរដ្ឋទាំងនោះបានឬមិនបានផ្ដល់សច្ចាប័នលើអនុសញ្ញានេះនោះឡើយ។ កាតព្វកិច្ចក្នុង "ការគោរពនិងធានាការគោរពច្បាប់មនុស្សធម៌អន្តរជាតិ" ដូចជាមាននៅក្នុងមាត្រាទូទៅ ១ នៃអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានចាត់ទុកផងដែរថាជាបទដ្ឋាននៃច្បាប់អន្តរជាតិដែលមានស្រាប់ផងដែរ។ បទប្បញ្ញត្តិនេះអាចបកស្រាយដោយមានរួមបញ្ចូលកាតព្វកិច្ចក្នុងការទប់ស្កាត់ការរំលោភច្បាប់មនុស្សធម៌អន្តរជាតិរួមទាំងឧក្រិដ្ឋកម្មសង្គ្រាម។

International human rights law also places obligations on State Parties to take steps to prevent the acts it seeks to prohibit. For example, the Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment specifies in Article 2 that State Parties "shall take effective legislative, administrative, judicial or other measures to prevent acts of torture". When part of a widespread or systematic attack against a civilian population, torture can constitute a crime against humanity.

ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានដាក់កាតព្វកិច្ចលើរដ្ឋជាភាគីដើម្បីចាត់វិធានការទប់ស្កាត់សកម្មភាពណាដែលបានហាមឃាត់។ ឧទាហរណ៍អនុសញ្ញាប្រឆាំងការធ្វើទារុណកម្មនិងអំពើព្រៃផ្សៃ អំពើអមនុស្សធម៌ ឬ ការប្រព្រឹត្តបន្ទាបបន្ថោក ឬ ការផ្ដន្ទាទោស មានចែងក្នុងមាត្រា ២ គឺរដ្ឋភាគី "ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព តាមផ្លូវច្បាប់ រដ្ឋបាល ប្រព័ន្ធតុលាការ ឬវិធានការដទៃទៀតដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម" ។ ការធ្វើទារុណកម្មត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅពេលដែលវាជាផ្នែកមួយនៃការវាយប្រហារទូលំទូលាយ ឬ ជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ។

On 27 February 2007 the International Court of Justice issued an important judgment in the Case Concerning Application of the Convention on the Prevention and Punishment of the Crime of Genocide (Bosnia and Herzegovina v. Serbia and Montenegro). The Court stated that the obligation "to prevent" within the scope of the Convention on the Prevention and Punishment of the Crime of Genocide imposed an obligation that was not territorially limited. According to the Court, every State with a "capacity to influence effectively the action of persons likely to commit, or already committing genocide," even if outside its own borders, is under the obligation "to employ all means reasonably available to them, so as to prevent genocide so far as possible".

នៅថ្ងៃទី 27 ខែកុម្ភៈឆ្នាំ 2007 តុលាការយុត្តិធម៌អន្តរជាតិបានចេញដីកាសម្រេចដ៏សំខាន់មួយក្នុងសំណុំរឿងស្ដីពីការអនុវត្តអនុសញ្ញាស្ដីពីការបង្ការ និង ការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (បូស្នៀនិងហឺហ្សេហ្គោវីណា និង ប្រទេសស៊ែប៊ីនិងម៉ុងតេណេហ្គ្រោ) ។ តុលាការបានបញ្ជាក់ថាកាតព្វកិច្ច "ដើម្បីទប់ស្កាត់" អនុសញ្ញាស្ដីពីការបង្ការ និង ការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺគ្មានការកំណត់ពីទឹកដីឡើយ។ យោងតាមតុលាការ រដ្ឋនីមួយៗ ដែលមាន

"សមត្ថភាពក្នុងការដាក់ឥទ្ធិពលប្រកបដោយប្រសិទ្ធភាពលើសកម្មភាពរបស់បុគ្គលណាដែលទំនងជានឹងប្រព្រឹត្តឬប្រព្រឹត្តអំពើប្រល័យពូជសាសន៍នេះរួចទៅហើយ" ទោះបីជានៅក្រៅព្រំដែនរបស់ខ្លួន គឺមានកាតព្វកិច្ច "ក្នុងការផ្តល់គ្រប់មធ្យោបាយដែលខ្លួនមានឱ្យបានសមរម្យដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទោះនៅទីណាក៏ដោយ"។

The principle of the Responsibility to Protect, which reaffirms the primary protect its population from atrocity crimes, is founded on all these legal obligations and interpretations. Paragraph 138 of the 2005 World Summit Outcome Documents specifies that States have a responsibility to prevent the commission of genocide, war crimes, ethnic cleansing and crimes against humanity, as well as incitement to these acts. Paragraph 139 goes on to underline the responsibility of the international com- munity to prevent atrocity crimes by helping States to build capacity to protect their populations and assisting State under stress "before crisis and conflicts break out". When States "manifestly fail" in their responsibility to protect populations from atrocity crimes, the international community has also declared that it is prepared to take collective action, in a "timely and decisive manner", to protect populations from these crimes, using all avail- able tools, and bearing in mind the principles of the United Nations Charter and international law.

គោលការណ៍នៃទំនួលខុសត្រូវក្នុងការការពារដែលបានបញ្ជាក់សជាថ្មីនូវការការពារចម្បងសម្រាប់ប្រជាជនរបស់ខ្លួនពីឧក្រិដ្ឋកម្មឃោរឃៅ ត្រូវបានបង្កើតឡើងពីកាតព្វកិច្ចនិងការបកស្រាយតាមផ្លូវច្បាប់ទាំងអស់នេះ។ កថាខណ្ឌ ១៣៨ នៃឯកសារលទ្ធផលនៃកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ 2005 បញ្ជាក់ថារដ្ឋនានាមានការទទួលខុសត្រូវក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងការញុះញង់ដែលអាចនាំឱ្យមានការប្រព្រឹត្តអំពើទាំងនេះ។ កថាខណ្ឌ 139 បន្តគូសបញ្ជាក់ពីការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅដោយការជួយរដ្ឋនានាក្នុងការកសាងសមត្ថភាពរបស់ពួកគេដើម្បីការពារការប្រជាជននិងជួយដល់រដ្ឋដែលកំពុងមានបញ្ហា "មុនពេលមានវិបត្តិនិងជម្លោះកើតឡើង"។ នៅពេលដែលរដ្ឋ "បង្ហាញសញ្ញាបរាជ័យ" ក្នុងទំនួលខុសត្រូវក្នុងការការពារប្រជាជនពីបទឧក្រិដ្ឋកម្មឃោរឃៅ សហគមន៍អន្តរជាតិបានប្រកាសឱ្យត្រៀមខ្លួនដើម្បីធ្វើសកម្មភាពរួម "ឱ្យបានទាន់ពេលវេលា និងប្រកបដោយការសម្រេចចិត្ត" ខ្ពស់" ដើម្បីការពារប្រជាជនពីបទឧក្រិដ្ឋកម្មទាំងនេះ ដោយប្រើប្រាស់មធ្យោបាយដែលមាន និងប្រកាន់ នូវគោលការណ៍នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិនិងច្បាប់អន្តរជាតិ។

> As the United Nations Secretary-General has emphasized, the principle of the Responsibility to Protect is designed to be an ally of sovereignty, rather than to undermine it
>
> ដូចដែល អគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជាក់ហើយថា គោលការណ៍នៃទំនួលខុសត្រូវក្នុងការការពារ ត្រូវបានរៀបចំឡើងដើម្បីជាសម្ពន្ធមិត្តនៃអធិបតេយ្យភាព មិនមែនដើម្បីធ្វើឱ្យអន្តរាយទេ។

## How can atrocity crimes be prevented? តើឧក្រិដ្ឋកម្មឃោរឃៅអាចត្រូវបានទប់ស្កាត់ដោយរបៀបណា ?

Preventing genocide, war crimes, ethnic cleansing and crimes against humanity is primarily the responsibility of individual States. Prevention is an ongoing process that requires sustained efforts to **build the resilience of societies to atrocity crimes** by ensuring that the rule of law is respected and that all human rights are protected, without discrimination; by establishing legitimate and accountable national institutions; by eliminating corruption; by managing diversity constructively; and by supporting a strong and diverse civil society and a pluralistic media. Failure by the State to

provide such protection and guarantees to its population can create an environment conducive to atrocity crimes. In such cases, prevention involves efforts to halt a likely course of events.

ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាការទទួលខុសត្រូវចម្បងរបស់រដ្ឋនីមួយៗ។ ការបង្ការទប់ស្កាត់គឺជាកិច្ចខិតខំប្រឹងប្រែងដែលកំពុងបន្ត ដើម្បីកសាងសង្គមដែលរឹងមាំប្រកបដោយនីតិរដ្ឋ សិទ្ធិមនុស្សត្រូវបានការពារដោយគ្មានការរើសអើង ដោយកសាងស្ថាប័នជាតិដែលស្របច្បាប់និងមានការទទួលខុសត្រូវ ដោយការលុបបំបាត់អំពើពុករលួយ ការគ្រប់គ្រងពិពិធកម្មឱ្យបានសមស្រប និងដោយការគាំទ្រពីសង្គមស៊ីវិលនិងប្រព័ន្ធផ្សព្វផ្សាយពីគ្រប់មជ្ឈដ្ឋាន។ ការបរាជ័យរបស់រដ្ឋមិនបានផ្តល់ការការពារនិងការធានាដល់ប្រជាជនរបស់ខ្លួនអាចបង្កើតបរិយាកាសអំណោយផលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ។ ក្នុងករណីដូចនោះ ការពារការត្រូវមានកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ឈប់ដំណើរនៃព្រឹត្តិការណ៍នោះ។

Atrocity crimes are not usually single or random events. Instead, they tend to develop in a dynamic process that offers entry points foraction to prevent their occurrence. To be able to engage in the level of violence associated with atrocity crimes, perpetrators need time to develop the capacity to do so, mobilize the resources, and take concrete steps that will help them to achieve their objectives. This does not mean that an overt plan to commit atrocity crimes will always exist from the onset of the process. In some past cases of genocide, for example, the intent to destroy a group was formulated at a later stage of the violence.

ឧក្រិដ្ឋកម្មឃោរឃៅតែងតែមិនមែនជាព្រឹត្តិការណ៍ដាច់ដោយឡែកមួយ ឬហេតុការណ៍កើតឡើងដោយចៃដន្យនោះទេ។ ផ្ទុយទៅវិញវាជាការវិវត្តក្នុងដំណើរការជាថាមវន្តដែលមានចំណុចចាប់ផ្តើមដែលអាចទប់ស្កាត់បាន។ ដើម្បីធ្វើចូលរួមក្នុងអំពើហិង្សាគ្រប់កម្រិតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មឃោរឃៅបាននោះ អ្នកប្រព្រឹត្តត្រូវការពេលក្នុងការអភិវឌ្ឍសមត្ថភាព ប្រមូលផ្តុំធនធាន និងចាត់វិធានដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន។ នេះមិនមែនមានន័យថាផែនការ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ តែងតែបានបញ្ចេញឱ្យឃើញតាំងពីដំណាក់កាលដំបូងនោះទេ។ ឧទាហរណ៍ នៅក្នុងករណីមួយចំនួននៃអំពើប្រល័យពូជសាសន៍កន្លងមក ចេតនាដើម្បីបំផ្លាញក្រុមប្រជាជន ត្រូវបានបង្កើតនៅក្នុងនោះដំណាក់កាលបន្ទាប់ពីអំពើហិង្សានេះ។

However, as atrocity crimes are processes, it is possible to identify warning signs or indicators that they might occur. This is particularly true in the case of genocide and crimes against humanity. If we **understand the root causes and precursors** of these crimes, and can **identify risk factors** that can lead to or enable their commission, it follows that we can also **identify measures that can be taken by States and the international community** to prevent these crimes.

ទោះជាយ៉ាងណា ឧក្រិដ្ឋកម្មឃោរឃៅគឺជាដំណើរការ ដូចនេះយើងអាចកំណត់បានសញ្ញាព្រមានឬសូចនាករដែលវាអាចកើតឡើង។ នេះគឺជាការពិត ជាពិសេសនៅក្នុងករណីនៃអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ប្រសិនបើយើងយល់ពីមូលហេតុ ដើមចមនៃឧក្រិដ្ឋកម្មទាំងនេះ និងអាចកំណត់ពីកត្តាហានិភ័យដែលនាំឱ្យកើតព្រឹត្តិការណ៍ យើងនឹងអាចកំណត់បានពីវិធានការដែលអាចអនុវត្តដោយរដ្ឋនិងសហគមន៍អន្តរជាតិដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ ។

The earlier the risk factors are identified, the greater the opportunities for early prevention. As times goes on, preventive action becomes more difficult and more costly. If, for example, the motivation behind increased violence against a particular group is recognized at an early stage, it will be possible for the State or the international community to develop strategies aimed at addressing and defusing this motivation. However, if atrocity crimes are already occurring, the options available to respond will be very limited and, in some cases, may require the use of coercive measures including, if all peaceful means fail, the use of force.

ការរកឃើញកត្តាហានិភ័យបានកាន់តែរហ័ស ឱកាសសម្រាប់ការទប់ស្កាត់ទុកជាមុនមានកាន់តែច្រើន។ បើពេលវេលាកន្លងទៅហួសច្រើនហើយនោះ សកម្មភាពបង្ការទប់ស្កាត់រឹតតែពិបាក និងការចំណាយកាន់តែច្រើន។ ឧទាហរណ៍ ប្រសិនបើការលើកទឹកចិត្តក្រោយការកើនឡើងនៃអំពើហិង្សាមកលើក្រុមណាមួយត្រូវបានរកឃើញនៅដំណាក់កាលដំបូង វានឹងអាចធ្វើឱ្យរដ្ឋឬសហគមន៍អន្តរជាតិ បង្កើតយុទ្ធសាស្រ្តក្នុងគោលបំណងដោះស្រាយនិងធ្វើឱ្យការជំរុញទឹកចិត្តថយចុះ។ ប៉ុន្តែ បើឧក្រិដ្ឋកម្មឃោរឃៅត្រូវបានកើតឡើងរួចទៅហើយ ជម្រើសតិចតួចដែលអាចមានដើម្បីយកមកដោះស្រាយ ហើយក្នុងករណីខ្លះ អាចនឹងតម្រូវឱ្យមានការការប្រើប្រាស់វិធានការក្តៅ រួមមានការប្រើកងកម្លាំង បើវិធានការសន្តិវិធីទាំងអស់ត្រូវបានបរាជ័យ ។

## What are the roles of the Special Advisers on the Prevention of Genocide and on the Responsibility to Protect?

តើតួនាទីរបស់ក្រុមទីប្រឹក្សាពិសេសសម្រាប់ការទប់ស្កាត់អំពើប្រល័យពូជសាសន៍និងទំនួលខុសត្រូវក្នុងការការពារមានអ្វីខ្លះ?

The United Nations Secretary-General's Special Advisers on the Prevention of Genocide and on the Responsibility to Protect, who have distinct but complementary mandates, work together to advance national and international efforts to protect populations from genocide, war crimes, ethnic cleansing and crimes against humanity, as well as their incitement.

ក្រុមទីប្រឹក្សាពិសេសស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍និងទំនួលខុសត្រូវក្នុងការការពាររបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលមានទទួលខុសត្រូវផ្សេងគ្នា តែជួយគ្នាក្នុងការធ្វើការរួមគ្នាដើម្បីដំណើរការកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិនិងអន្តរជាតិដើម្បីការពារប្រជាជនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការលុបបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ដូចជាការញុះញង់។

The Special Adviser on the Prevention of Genocide acts as an early warning mechanism by alerting the United Nations Secretary-General and, through him, the Security Council to situations where there is a risk of genocide and presenting recommendations. The Special Adviser also advocates and mobilizes the United Nations system, Member States, regional arrangements and civil society for appropriate preventive action. Working under the overall guidance of the Special Adviser on the Prevention of Genocide, the Special Adviser on the Responsibility to Protect leads the conceptual, political, institutional and operational development of the Responsibility to Protect principle and its implementation by the United Nations, Member States, regional arrangements and civil society.

ទីប្រឹក្សាពិសេសសម្រាប់ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដើរតួនាទីជាយន្តការព្រមានទុកជាមុន ដោយការជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ និង ក្រុមប្រឹក្សាសន្តិសុខ អំពីស្ថានភាព និង ហានិភ័យនៃអំពើប្រល័យពូជសាសន៍ ជាមួយនឹងការដាក់ជូនអនុសាសន៍។ ទីប្រឹក្សាពិសេសបញ្ចេញមតិគាំទ្រ ប្រមូលផ្តុំ ប្រព័ន្ធអង្គការសហប្រជាជាតិប្រទេសជាសមាជិក ចំណាត់ការក្នុងតំបន់ និងសង្គមស៊ីវិល សម្រាប់សកម្មភាពទប់ស្កាត់ក្នុងករណីសមស្រប។ ក្រោមការណែនាំទូទៅរបស់ទីប្រឹក្សាពិសេសសម្រាប់ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ទីប្រឹក្សាពិសេសខាងទំនួលខុសត្រូវក្នុងការការពារការជាអ្នកដឹកនាំ រៀបចំគោលការណ៍ និង ការអនុវត្ត ផ្នែកគោលគំនិត នយោបាយ ស្ថាប័ននិងប្រតិបត្តិការនៃទំនួលខុសត្រូវក្នុងការការពារ របស់អង្គការសហប្រជាជាតិ រដ្ឋជាសមាជិក ចំណាត់ការតំបន់ និងសង្គមស៊ីវិល។

The Special Advisers are supported by a joint office, the Office on Genocide Prevention and the Responsibility to Protect (the Office). The Office collects information and conducts assessments of situations worldwide that could potentially lead to atrocity crimes or their incitement. The Office also works to build the capacity of United Nations, Member States, regional and sub- regional organizations and civil society through training and technical assistance to strengthen prevention, early warning and response capacity; to promote a greater understanding of the causes and dynamics of atrocity crimes and of the measures that could be taken to pre- vent them; and to raise awareness among States and other actors about their responsibility to protect.

ក្រុមប្រឹក្សាពិសេស គឺទទួលការគាំទ្រពីការិយាល័យចម្រុះការិយាល័យទប់ស្កាត់អំពើប្រល័យពូជសាសន៍និងទំនួលខុសត្រូវក្នុងការការពារ (ការិយាល័យ) ។ ការិយាល័យនេះ ប្រមូលព័ត៌មាន និងវាយតម្លៃស្ថានភាពដែលអាចឈានទៅដល់ការកើតឡើងនូវឧក្រិដ្ឋកម្មឃោរឃៅ ឬការញុះញង់ ទូទាំងពិភពលោក។ ការិយាល័យនេះធ្វើការដើម្បីកសាងសមត្ថភាពរបស់អង្គការសហប្រជាជាតិ រដ្ឋជាសមាជិក អង្គការក្នុងតំបន់និងអនុតំបន់ សង្គមស៊ីវិលតាមរយៈការបណ្តុះបណ្តាលនិងជំនួយបច្ចេកទេសដើម្បីពង្រឹងការទប់ស្កាត់ ការព្រមានទុកជាមុន និងសមត្ថភាពឆ្លើយតប ដើម្បីលើកកម្ពស់ការយល់ដឹងកាន់តែច្រើននៃដើមហេតុ និងដំណើរការនៃឧក្រិដ្ឋកម្មឃោរឃៅ និង វិធានការដើម្បីទប់ស្កាត់ និងដើម្បីបង្កើនការយល់ដឹងក្នុងចំណោមរដ្ឋ ព្រមទាំងភាគីផ្សេងៗទៀតអំពីទំនួលខុសត្រូវក្នុងការការពារ។

It is worth noting that there are **other United Nations departments and institutions with mandates that are relevant to the prevention of atrocity crimes**. These include the Department of Political Affairs (DPA), through its work on conflict prevention and peaceful resolution; the Department of Peacekeeping Operations (DPKO), through its work on the protection of civilians; the Office of the United Nations High Commissioner for Human Rights (OHCHR), which takes the lead on the promotion and protection of human rights; the Office of the United Nations High Commissioner for Refugees (UNHCR), through its work on the protection of uprooted or stateless people; the United Nations Development Programme (UNDP), through its work to promote the rule of law and support democratic governance and crisis prevention initiatives; and the United Nations Office for the Coordination of Humanitarian Affairs (OCHA), through its coordination work among humanitarian actors with the aim of reducing the impact of conflict. The United Nations human rights monitoring mechanisms, such as the human rights treaty bodies and the Human Rights Council's special procedures, can also play an important early warning role.

គួរឱ្យកត់សម្គាល់ថា **មាននាយកដ្ឋាន និង ស្ថាប័នផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិដែលមានការងារទាក់ទងនឹងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ**។ រួមមាននាយកដ្ឋានកិច្ចការនយោបាយ (DPA) តាមរយៈការងាររបស់ខ្លួនស្តីពីការទប់ស្កាត់ជម្លោះនិងដំណោះស្រាយដោយសន្តិវិធី នាយកដ្ឋានប្រតិបត្តិការរក្សាសន្តិភាព (DPKO) តាមរយៈការងាររបស់ខ្លួននៅលើ ការការពារជនស៊ីវិល ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដែលឈានមុខក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) បានតាមរយៈការងាររបស់ខ្លួនលើការការពារនៃមនុស្សគ្មានរដ្ឋនេះ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) តាមរយៈការងាររបស់ខ្លួនក្នុងការលើកកម្ពស់នីតិរដ្ឋនិងគាំទ្រដល់អភិបាលកិច្ចបែបប្រជាធិបតេយ្យនិងការផ្តួចផ្តើមទប់ស្កាត់វិបត្តិធ្ងន់ធ្ងរ និងការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការសម្របសម្រួលកិច្ចការមនុស្សធម៌ (OCHA) បានតាមរយៈការងារសម្របសម្រួលក្នុងចំណោមភាគីមនុស្សធម៌ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់នៃជម្លោះ។ យន្តការឃ្លាំមើលសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដូចជាស្ថាប័នសិទ្ធិមនុស្ស និង នីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏ដើរតួនាទីសំខាន់ក្នុងការព្រមានជាមុននេះដែរ។

## What is the Framework of Analysis?

តើក្របខ័ណ្ឌនៃការវិភាគនេះគឺជាអ្វី?

In 2009, the then Office of the Special Adviser on the Prevention of Genocide developed a framework of analysis to support the assessment of the risk of the crime of genocide from an early warning perspective. However, with the subsequent expansion of the Office's responsibilities to also support the work of the Special Adviser on the Responsibility to Protect, there was a need to develop a framework that could be used to analyse not only the risk of genocide but also the risk of crimes against humanity, war crimes and ethnic cleansing. In

addition, new dynamics and a better understanding of the processes of atrocity crimes prompted the need for a revision of the elements included in the initial framework.

នៅឆ្នាំ 2009 កាលនោះនៅជាការិយាល័យទីប្រឹក្សាពិសេសស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ បានរៀបចំបង្កើតក្របខ័ណ្ឌនៃការវិភាគមួយដើម្បីគាំទ្រដល់ការវាយតម្លៃពីហានិភ័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពីទស្សនៈផ្តោតលើសញ្ញាព្រមានជាមុន។ ក្រោយមក ដោយមានការពង្រីកជាបន្តបន្ទាប់នៃការទទួលខុសត្រូវរបស់ការិយាល័យដើម្បីគាំទ្រដល់ការងាររបស់ទីប្រឹក្សាពិសេសលើទំនួលខុសត្រូវក្នុងការការពារ ក៏តម្រូវបង្កើត ក្របខ័ណ្ឌបន្ថែម ដែលអាចយកមកប្រើដើម្បីវិភាគទាំងហានិភ័យនៃអំពើប្រល័យពូជសាសន៍ និងហានិភ័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ឧក្រិដ្ឋកម្មសង្គ្រាម និងការលុបបំបាត់ជាតិសាសន៍។ លើសពីនេះទៀតដំណើរការថ្មីនិងការយល់ដឹងកាន់តែប្រសើរនូវដំណាក់កាលនៃការប្រព្រឹត្តបទល្មើសឃោរឃៅនេះបានជំរុញឲ្យមានការពិនិត្យឡើងវិញពីផ្នែកនានានៅក្នុងក្របខ័ណ្ឌ។

The present Framework replaces the previous document and provides an integrated analysis and risk assessment tool for atrocity crimes. The revision also reflects recent developments and new research into the processes that lead to those crimes. It was subject to consultations within and outside the United Nations system. The result is a Framework that serves as a working tool for the assessment of the risk of atrocity crimes in all parts of the world and in identify- ing those countries most at risk.

ក្របខ័ណ្ឌបច្ចុប្បន្នជំនួសឯកសារមុននិងផ្តល់នូវឧបករណ៍រួមសម្រាប់ការវិភាគរួមនិងការវាយតម្លៃហានិភ័យ សម្រាប់ឧក្រិដ្ឋកម្មឃោរឃៅ។ កំណែប្រែនេះគឺឆ្លុះបញ្ចាំងពីការវិវត្តថ្មីនិងការស្រាវជ្រាវថ្មីទៅក្នុងដំណើរការដែលនាំទៅដល់ការកើតមានឧក្រិដ្ឋកម្មទាំងនោះ។

ការពិភាក្សាមាននៅទាំងក្នុងនិងក្រៅប្រព័ន្ធអង្គការសហប្រជាជាតិ។ លទ្ធផលគឺក្របខ័ណ្ឌដែលបានប្រើការជាឧបករណ៍មួយសម្រាប់ការវាយតម្លៃការងារនៃហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងគ្រប់តំបន់ទាំងអស់ក្នុងពិភពលោកនិងក្នុងការកំណត់ប្រទេសដែលមានហានិភ័យខ្ពស់។

To be effective, assessments require the systematic collection of accurate and reliable information based on the risk factors and indicators that the Framework identifies. The broad risk factors and the more specific indicators reflect definitions of the crimes in international law, case law from the work of international courts or tribunals, and empirical analysis of past and present situations.

ដើម្បីឱ្យមានប្រសិទ្ធភាព ការវាយតម្លៃតម្រូវឱ្យមានការប្រមូលផ្តុំជាប្រព័ន្ធនូវព័ត៌មានដែលត្រឹមត្រូវ និងអាចជឿទុកចិត្តបានពដែលព័ត៌មានទាំងនោះផ្អែកលើកត្តាហានិភ័យនិងសូចនាករដែលក្របខ័ណ្ឌបានកំណត់។

កត្តាហានិភ័យទូទៅនិងសូចនាករជាក់លាក់ឆ្លុះបញ្ចាំងពីនិយមន័យនៃឧក្រិដ្ឋកម្មដែលមានក្នុងច្បាប់អន្តរជាតិបណ្តឹងរបស់តុលាការអន្តរជាតិឬសាលាក្តីផ្សេងៗ និងការវិភាគជាក់ស្តែងពីអតីតកាលនិងបច្ចុប្បន្ន។

Given the absence of a conceptual definition com- mon to all war crimes, such as that which exists for genocide and crimes against humanity, the Framework focuses only on war crimes that have an impact on the protection of human life, this being the primary objective of preventive action. In addition, given the focus of the Responsibility to Protect principle on the protection of populations from the most serious violations of international human rights and humanitarian law, the Framework covers war crimes that assume a more systematic or widespread pattern of conduct. Finally, given that ethnic cleansing does not have a distinct legal definition as an international crime, but includes acts that can constitute other atrocity crimes or elements of them, it has been integrated into the analysis of the risk factors for those crimes.

ដោយឧក្រិដ្ឋកម្មសង្គ្រាមទាំងអស់មិនមាននិយមន័យជាទស្សនៈទូទៅ ដូចនៅក្នុងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ ក្របខ័ណ្ឌនេះផ្តោតតែលើឧក្រិដ្ឋកម្មសង្គ្រាមដែលមានផលប៉ះពាល់លើការការពារជីវិតមនុស្ស នេះដោយសារគោលបំណងចម្បង គឺសកម្មភាពបង្ការ។ លើសពីនេះទៀត ដោយការផ្តោតជាចម្បងនៃគោលការណ៍ទំនួលខុសត្រូវក្នុងការការពារគឺលើការការពារប្រជាជនពីការរំលោភបំពានធ្ងន់ធ្ងរបំផុតនៃសិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ក្របខ័ណ្ឌនេះគ្របដណ្តប់លើឧក្រិដ្ឋកម្មសង្គ្រាមជាប្រព័ន្ធឬរីករាលដាល។

ជាចុងក្រោយដោយសារការលុបបំបាត់ជាតិសាសន៍មិនមាននិយមន័យផ្លូវច្បាប់ដាច់ដោយឡែកពីបទឧក្រិដ្ឋអន្តរជាតិនោះ តែបានរួមបញ្ចូលសកម្មភាពដែលអាចបង្កើតបានទៅជាឧក្រិដ្ឋកម្មឃោរឃៅ ឬធាតុផ្សេងៗរបស់ឧក្រិដ្ឋកម្មនេះ

ការលុបបំបាត់ជាតិសាសន៍ត្រូវបានដាក់បញ្ចូលទៅក្នុងការវិភាគអំពីកត្តាហានិភ័យចំពោះឧក្រិដ្ឋកម្មទាំងនោះ។

**The UN Secretary- General's Special Advisers on the Prevention of Genocide and on the Responsibility to Protect work together to advance national and international efforts to protect populations from atrocity crimes.**

**ទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍និងទំនួលខុសត្រូវក្នុងការការពារ ធ្វើការរួមគ្នាដើម្បីដំណើរការកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិនិងអន្តរជាតិដើម្បីការពារប្រជាជនពីបទឧក្រិដ្ឋកម្មឃោរឃៅ។**

This Framework is a public document. The Office encourages and welcomes its use by international, regional and national actors as a tool either for early warning mechanisms, or for other mechanisms used for monitoring, assessment and forecasting. In addition, the Office recommends that Member States use the Framework to help identify both areas of success as well as gaps in atrocity prevention capacities and strategies at the national level.

ក្របខ័ណ្ឌនេះគឺជាឯកសារសាធារណៈ។ ការិយាល័យ លើកទឹកចិត្តនិងស្វាគមន៍ចំពោះការប្រើប្រាស់ក្របខ័ណ្ឌនេះដោយភាគីជាតិ តំបន់និងអន្តរជាតិ ជាឧបករណ៍សម្រាប់យន្តការព្រមានទុកជាមុន ឬសម្រាប់យន្តការផ្សេងៗទៀតសម្រាប់ការត្រួតពិនិត្យ វាយតម្លៃនិងការព្យាករ។ លើសពីនេះទៀត ការិយាល័យ សូមផ្តល់អនុសាសន៍ ដល់រដ្ឋជាសមាជិក ឱ្យប្រើក្របខ័ណ្ឌនេះ ដើម្បីជួយដល់ការកំណត់ទាំងជោគជ័យ ព្រមទាំងចំណុចខ្សោយនៃសមត្ថភាពនិងយុទ្ធសាស្រ្តការទប់ស្កាត់អំពើឃោរឃៅនៅថ្នាក់ជាតិរបស់ខ្លួន។

## What are risk factors and indicators?

### តើកត្តានិងសូចនាករហានិភ័យគឺជាអ្វី?

Risk factors are conditions that increase the risk of or susceptibility to negative outcomes. Those identified in this framework

include behaviours, circumstances or elements that create an environment conducive to the commission of atrocity crimes, or indicate the potential, probability or risk of their occurrence. Risk factors are not all the same. Some are structural in nature, such as the weakness of State structures, while others pertain to more dynamic circumstances or events, such as triggering factors. Triggers and other dynamic elements transform general risk into an increased likelihood that atrocities crimes will be committed.

កត្តាហានិភ័យគឺជាស្ថានភាពដែលអាចបង្កើនហានិភ័យឬភាពងាយទទួលរងលទ្ធផលអវិជ្ជមាន។ អ្វីដែលបានកំណត់ក្នុងក្របខ័ណ្ឌនេះមានឥរិយាបថ កាលៈទេសៈ ឬធាតុផ្សំដែលអាចបង្កើតបរិយាកាសដែលងាយនឹងឈានដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ ឬចង្អុលបង្ហាញពីសក្តានុពលដែលអាចទៅរួច ឬហានិភ័យ ដែលអាចឱ្យកើតមានឧក្រិដ្ឋកម្មទាំងនោះ។ កត្តាហានិភ័យមិនមែនដូចគ្នាទាំងអស់នោះទេ។ ខ្លះគឺជាប្រព័ន្ធ ដូចជាភាពទន់ខ្សោយនៃរចនាសម្ព័ន្ធរបស់រដ្ឋ ឯខ្លះទៀតគឺទាក់ទងទៅនឹងដំណើរការកាលៈទេសៈភ្លាមៗ ដូចជាកត្តាបង្កហេតុជាដើម។ កត្តាបង្កហេតុនិងធាតុផ្សេងៗអាចផ្លាស់ប្តូរ ហានិភ័យទូទៅ ដែលបណ្តាលឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅកាន់តែខ្លាំងឡើង។

The **indicators** included in this framework are different manifestations of each risk factor, and therefore assist in determining the degree to which an individual risk factor is present. The particular indicators identified in the Framework have been drawn from past and current cases, but are not intended to be exhaustive.

សូចនាករដែលបានបញ្ចូលនៅក្នុងក្របខ័ណ្ឌនេះគឺជាបាតុភាពផ្សេងៗដែលកើតពីកត្តាហានិភ័យនីមួយៗ ដូច្នេះហើយ វាអាចជួយដល់ការកំណត់អំពីទំហំនៃកត្តាហានិភ័យនីមួយៗដែលមាន។ សូចនាករដែលបានកំណត់នៅក្នុងក្របខ័ណ្ឌនេះត្រូវបានដកស្រង់ចេញពីករណីពីអតីតកាលនិងបច្ចុប្បន្ន ប៉ុន្តែមិនបានគ្របដណ្តប់ទាំងស្រុងទាំងអស់នោះទេ។

## How to use the Framework of Analysis

The Framework contains two main analytical tools for assessing the risk of atrocity crimes: (a) a list of **14 risk factors** for atrocity crimes; and (b) **indicators** for each of the risk factors. Among the 14 risk factors outlined, the first eight are common to all crimes, reflecting the fact that atrocity crimes tend to occur in similar settings and share several elements or features. In addition to these common factors, the framework identifies six additional risk factors, two specific to each of the international crimes — namely genocide, crimes against humanity and war crimes.

### របៀបក្នុងការប្រើក្របខ័ណ្ឌនៃការវិភាគ

ក្របខ័ណ្ឌនេះមានឧបករណ៍វិភាគចម្បងពីរសម្រាប់ការវាយតម្លៃហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅ: (ក) បញ្ជីនៃកត្តាហានិភ័យចំនួន១៤ នៃឧក្រិដ្ឋកម្មឃោរឃៅ និង (ខ) សូចនាករសម្រាប់កត្តាហានិភ័យនីមួយៗ។ ក្នុងចំណោមកត្តាហានិភ័យទាំង១៤នេះ ៨ដំបូងជាកត្តាហានិភ័យទូទៅដែលមាននៅក្នុងឧក្រិដ្ឋកម្មទាំងអស់ ដែលនេះឆ្លុះបញ្ចាំងពីការពិតដែលថាឧក្រិដ្ឋកម្មឃោរឃៅមានទំនោរកើតឡើងក្នុងស្ថានភាពស្រដៀងគ្នា និងមានធាតុឬលក្ខណៈស្រដៀងគ្នា។ បន្ថែមពីលើកត្តាទូទៅទាំងនេះ,ក្របខ័ណ្ឌក៏បានកំណត់កត្តាចំនួនប្រាំមួយបន្ថែមទៀត មានកត្តាពីរៗដែលជាក់លាក់ទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិនីមួយៗ - ពោលគឺអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

The **common risk factors** help us identify the probability of atrocity crimes overall, without necessarily identifying the type of crime. In fact, in the initial stages of monitoring, it is not always possible to identify which specific crime is most at risk. This becomes clearer as the process leading to atrocity crimes progresses.For example, weak State structures put populations or groups at risk of any of these crimes. In addition, different kinds of atrocity crimes can occur concurrently in a same situation, or one crime might be a precursor to another form of atrocity crime.

កត្តាហានិភ័យទូទៅជួយឱ្យយើងកំណត់រកប្រូបាប៊ីលីតេនៃឧក្រិដ្ឋកម្មឃោរឃៅជារួមដោយមិនចាំបាច់កំណត់ប្រភេទជាក់លាក់នៃបទឧក្រិដ្ឋ។ ការពិត ក្នុងដំណាក់កាលដំបូងនៃការពិនិត្យ វាមិនអាចតែងតែអាចទៅរួចនោះទេ ក្នុងការកំណត់អត្តសញ្ញាណជាក់លាក់នៃប្រភេទបទល្មើសដែលប្រឈមហានិភ័យខ្ពស់ជាងគេ។ ប្រភេទនៃបទឧក្រិដ្ឋអាចលេចច្បាស់ឡើងនៅពេលដំណើរឈានជិតទៅដល់ឧក្រិដ្ឋកម្មជាក់ស្តែង។ ឧទាហរណ៍ ភាពទន់ខ្សោយនៃរចនាសម្ព័ន្ធរដ្ឋអាចធ្វើឱ្យប្រជាជន ឬក្រុមប្រឈមនឹងហានិភ័យនៃឧក្រិដ្ឋកម្មទាំងអស់នោះ។ លើសពីនេះទៅទៀត ឧក្រិដ្ឋកម្មប្រភេទផ្សេងៗគ្នាបានកើតមានឡើងស្របពេលជាមួយគ្នា ក្នុងស្ថានភាពតែមួយ ឬបទល្មើសមួយអាចជាដើមចមនៃឧក្រិដ្ឋកម្មឃោរឃៅមួយទៀត។

The **specific risk factors**, on the other hand, result from the fact that each crime has elements and pre- cursors that are not common to all three crimes. For example, one of the elements specific to the crime of genocide is the intent to destroy, in whole or in part, a national, ethnical, racial or religious group. Where signs or evidence of such intent are found, this points to a higher risk of genocide. In this way, the specific risk factors identified in the framework reflect the legal definitions of the crimes, even though they are not strictly limited by them, nor intend to be criminal evidence of them.

ម្យ៉ាងវិញទៀត កត្តាហានិភ័យជាក់លាក់ គឺជាលទ្ធផលនៃភាពជាក់ស្តែងនៃឧក្រិដ្ឋកម្មមួយដែលមានធាតុនិងដំណើរវិវត្តបឋមប្លែកគ្នាក្នុងឧក្រិដ្ឋកម្មទាំងបី។ ឧទាហរណ៍ធាតុមួយដែលជាក់លាក់ពីអំពើប្រល័យពូជសាសន៍ គឺគោលបំណងក្នុងការកម្ទេចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃជាតិ ជាតិសាសន៍ ពូជសាសន៍ ឬក្រុមសាសនា។ នៅពេលដែលសញ្ញាឬភ័ស្តុតាងនៃគោលបំណងនេះត្រូវបានរកឃើញនេះ វាបង្ហាញឱ្យឃើញថាហានិភ័យខ្ពស់នៃអំពើប្រល័យពូជសាសន៍។ តាមវិធីនេះ កត្តាហានិភ័យជាក់លាក់កំណត់នៅក្នុងក្របខ័ណ្ឌនេះ គឺនិយមន័យផ្អែកលើច្បាប់នៃឧក្រិដ្ឋកម្ម បើទោះបីជាកត្តាហានិភ័យទាំងនេះមិនមែនកំណត់ដោយតែឧក្រិដ្ឋកម្មទាំងនោះ ឬគ្រាន់តែជាភ័ស្តុតាងផ្នែកព្រហ្មទណ្ឌ។

To assess the risk of atrocity crimes in a given situation with the Framework of Analysis, a monitor or analyst should **use the risk factors and indicators to guide the collection and assessment of information**. For example,

taking Risk Factor 1 (Situations of Armed Conflict or Other Forms of Instability), they should collect reliable information from a variety of sources that would inform an assessment of whether any of the respective indicators is present or has changed: whether there is an international or non-international armed conflict (Indicator 1.1); whether there is evidence of a humanitarian crisis or emergency (Indicator 1.2); whether there is political instability caused by different factors (Indicators 1.3 to 1.6); economic instability (Indicator 1.7 to 1.9) or social instability (Indicators 1.10 and 1.11). The analysis of the totality of the information gathered will guide an assessment of whether a particular State faces the kind of stress that could generate an environment conducive to atrocity crimes and hence, the presence of Risk Factor1.

ដើម្បីវាយតម្លៃហានិភ័យដោយការប្រើប្រាស់ក្របខ័ណ្ឌវិភាគ ក្នុងស្ថានភាពមួយ, អ្នកត្រួតពិនិត្យឬអ្នកវិភាគគួរប្រើកត្តាហានិភ័យនិងសូចនាករដើម្បីណែនាំក្នុងការប្រមូលនិងការវាយតម្លៃព័ត៌មាន។ ឧទាហរណ៍ ក្នុងហានិភ័យ ១ (ស្ថានការណ៍នៃជម្លោះប្រដាប់អាវុធឬទម្រង់ផ្សេងទៀតនៃអស្ថិរភាព), ពួកគេគួរតែប្រមូលព័ត៌មានដែលអាចជឿទុកចិត្តបានពីប្រភពខុសៗគ្នាការវាយតម្លៃថាតើសូចនាករណាមួយដែលផ្តល់ព័ត៌មាន ឬត្រូវបានផ្លាស់ប្តូរ៖ ថាតើមាន ជម្លោះប្រដាប់អាវុធលក្ខណៈអន្តរជាតិឬមិនអន្តរជាតិ (សូចនាករ ១.១) ថាតើមានភ័ស្តុតាងនៃវិបត្តិមនុស្សធម៌ឬស្ថានភាពសង្គ្រោះបន្ទាន់ (សូចនាករ ១.២) ថាតើមានអស្ថិរភាពនយោបាយបានបង្កឡើងដោយកត្តាផ្សេងៗ (សូចនាករ ១.៣ ដល់ ១.៦) អស្ថិរភាពសេដ្ឋកិច្ច (សូចនាករ 1.7 ដល់ 1.9) ឬអស្ថិរភាពសង្គម (សូចនាករ 1.10 និង 1.11) ។ ការវិភាគអំពីព័ត៌មានសរុបដែលបានប្រមូលនឹងជួយដល់ការវាយតម្លៃថាតើរដ្ឋមួយកំពុងប្រឈមនឹងភាពតានតឹងដែលអាចបង្កើតបរិយាកាសអំណោយផលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ ដែលកំណត់ដោយកត្តាហានិភ័យទី ។

A few points should be kept in mind while using this Framework. First, **not all risk factors need to be present for there to be an assessment that there is a significant risk of atrocity crimes occurring**. For example, there are situations where information gathered has confirmed the presence of most of the risk factors, but atrocity crimes have not yet taken place. This could be due to the absence of a triggering event or the presence of a strong mitigating factor. It may also not be possible to obtain sufficiently accurate and reliable information to confirm the presence of a particular risk factor. Nevertheless, this should not deter monitors and analysts from warning of the likelihood that an atrocity crime could be committed. Triggering factors are not always predictable and a strong mitigating factor might weaken or disappear. It is also important to bear in mind that common risk factors tend to be manifest sooner than specific risk factors. Information that confirms the presence of specific risk factors is sometimes more difficult to obtain at an early stage.

មានចំណុចមួយចំនួនគួរតែត្រូវបានប្រុងប្រយ័ត្ន នៅពេលប្រើប្រាស់ក្របខ័ណ្ឌនេះ។ ទីមួយ មិនមែនកត្តាហានិភ័យទាំងអស់ត្រូវមានវត្តមាននោះទេ ដើម្បីវាយតម្លៃថាមានហានិភ័យខ្ពស់នៃការកើតមានឡើងបទឧក្រិដ្ឋកម្មឃោរឃៅ។ ឧទាហរណ៍ មានស្ថានភាពជាច្រើនដែលព័ត៌មានដែលបានប្រមូលបានបញ្ជាក់ថាមានវត្តមានកត្តាហានិភ័យភាគច្រើន ប៉ុន្តែឧក្រិដ្ឋកម្មឃោរឃៅនៅទាន់កើតឡើងនៅឡើយ។ នេះអាចដោយសារមិនទាន់មានព្រឹត្តិការណ៍បង្កហេតុឬ ដោយសារវត្តមាននៃកត្តាបន្ធូរបន្ថយ។ មួយវិញទៀត ព័ត៌មានខ្លះគឺអាចនឹងពិបាកក្នុងការប្រមូលឱ្យបានគ្រប់គ្រាន់ និងអាចទុកចិត្តបានដើម្បីបញ្ជាក់ពីវត្តមាននៃកត្តាហានិភ័យមួយជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយ នេះមិនគួររារាំងបង្អាក់អ្នកឃ្លាំមើលនិងអ្នកវិភាគពីការព្រមានពីលទ្ធភាពនៃឧក្រិដ្ឋកម្មឃោរឃៅដែលអាចកើតឡើងឡើយ។ កត្តាបង្កហេតុមិនតែងតែអាចព្យាករទុកមុនបាន ហើយកត្តាសម្រាល អាចនឹងចុះខ្សោយ ឬបាត់តែម្តង។ វាជាការសំខាន់ផងដែរ ដែលត្រូវគិតថាកត្តាហានិភ័យទូទៅរមែងតែងតែលេចចេញលឿនជាងកត្តាហានិភ័យជាក់លាក់។ ព័ត៌មានដែលបញ្ជាក់ពីវត្តមាននៃកត្តាហានិភ័យជាក់លាក់ពេលខ្លះពិបាកទទួលបាននៅដំណាក់កាលដំបូង។

Second, **the more risk factors (and the greater number of relevant indicators) that are present, the greater the risk that an atrocity crime may be committed**. Also, the greater the number of indicators of a particular risk factor that are present, the greater the importance and role of that factor in a particular situation.

ទីពីរ កត្តាហានិភ័យមានកាន់តែច្រើន (និងចំនួនសូចនាករពាក់ព័ន្ធមានកាន់តែច្រើន) ហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅដែលអាចនឹងកើតមានឡើងកាន់តែខ្ពស់។ មួយទៀតផងដែរ ចំនួនសូចនាករនៃកត្តាហានិភ័យមួយមានកាន់តែច្រើន តួនាទីរបស់កត្តាហានិភ័យនោះគឺកាន់តែសំខាន់ក្នុងស្ថានភាពនោះ។

Third, **the risk factors and the indicators are not ranked, as their relative importance will differ according to the particular context**. Even though armed conflict has been identified as the strongest or most important contributing risk factor, armed conflict is not a precondition of all atrocity crimes — genocide and crimes against humanity can also occur in times of peace. Certainly, some risk factors will have a greater weight than others, or will be manifest more often than others. However, all contribute to increasing the risk of atrocity crimes.

ទីបី **កត្តាហានិភ័យ និងសូចនាករមិនត្រូវបានរាយជាចំណាត់ថ្នាក់នោះទេ នេះដោយសារសារៈសំខាន់របស់ពួកគេ គឺអាស្រ័យតាមបរិបទ**។ បើទោះបីជាជម្លោះប្រដាប់អាវុធត្រូវបានគេកំណត់ថាជាកត្តាហានិភ័យខ្ពស់បំផុតដែលនាំដល់ឧក្រិដ្ឋកម្មឃោរឃៅ, តែជម្លោះប្រដាប់អាវុធមិនមែនតែងតែជាលក្ខខណ្ឌបឋមនៃឧក្រិដ្ឋកម្មឃោរឃៅទាំងអស់នោះទេ — អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចកើតមានឡើងនៅក្នុងពេលសន្តិភាពផងដែរ។ ជាការពិតណាស់, កត្តាហានិភ័យមួយចំនួនមានទម្ងន់ធំជាង ឬលេចចេញជាញឹកញាប់ជាងកត្តាផ្សេងទៀត។ តែទោះជាយ៉ាងនេះក្តី កត្តាទាំងអស់រួមចំណែកដល់ការបង្កើនហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅ។

Finally, monitors and analysts will need to be flexible when considering and weighing all the elements in this Framework and **situate them within a broader political, contextual, historical and cultural analysis**. In addition, given the development of new trends and patterns of violence and of conduct related to conflict, assessments should be open to new elements that might surface.

ជាចុងក្រោយ, អ្នកឃ្លាំមើលនិងអ្នកវិភាគត្រូវចេះបត់បែននៅពេលធ្វើការពិចារណានិងថ្លឹងថ្លែងធាតុទាំងអស់នៅក្នុងក្របខ័ណ្ឌនេះនិង **កំណត់ទីតាំងរបស់ធាតុទាំងនោះក្នុងការវិភាគឱ្យបានទូលំទូលាយដែលគ្របដណ្តប់លើនយោបាយ បរិបទ ប្រវត្តិសាស្ត្រ និងវប្បធម៌**។ លើសពីនេះទៅទៀត ដោយមានការវិវត្តនៃនិន្នាការនិងលំនាំគំរូថ្មីៗនៃអំពើហិង្សានិងការប្រព្រឹត្តដែលទាក់ទងទៅនឹងជម្លោះ ការវាយតម្លៃគួរតែមានការបើកចំហទៅកាន់ធាតុថ្មីៗដែលអាចនឹងលេចចេញជារូបរាង។

## How accurate are risk assessments of atrocity crimes?

The Framework of Analysis provides a set of elements to help monitors or analysts to make **qualitative and systematic assessments of the risk of atrocity crimes** in specific situations. However, the presence of risk factors of atrocity crimes in a particular situation does not directly or inevitably lead to the occurrence of those crimes — risk is not equated with inevitability. In fact, some of the risk factors identified in the Framework will be present in many situations or societies around the world where atrocity crimes have not taken place. Why is that? The absence of atrocity crimes in these societies can be linked to the strength of local sources of resilience, outside assistance that mitigates risk, the lack of motivation of the leadership to commit or permit atrocity crimes, or simply the absence of a triggering factor or event. On the other hand, unpredictable occurrences can disrupt a likely course of events.

### តើការវាយតម្លៃហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅមានសុក្រិតភាពកម្រិតណា?

ក្របខ័ណ្ឌនៃការវិភាគនេះផ្តល់នូវសំណុំនៃធាតុដើម្បីជួយអ្នកតាមដានឬក្រុមអ្នកវិភាគដើម្បីវាយតម្លៃលើគុណភាពនិងជាប្រព័ន្ធហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅក្នុងស្ថានភាពជាក់លាក់មួយ។ ទោះជាយ៉ាងណា វត្តមានកត្តាហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងស្ថានភាពមួយមិនមែនដឹងតែកើតមានផ្ទាល់ឬចៀសវាងបាននោះទេ។ ជាការពិតទៅ កត្តាហានិភ័យដែលបានកំណត់ក្នុងក្របខ័ណនេះនឹងមានវត្តមាននៅក្នុងស្ថានភាព ឬសង្គមជាច្រើននៅជុំវិញពិភពលោកដែលពុំមានឧក្រិដ្ឋកម្មឃោរឃៅកើតឡើង។ ហេតុអ្វីបានជាអញ្ចឹង? អវត្តមាននៃឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងសង្គមទាំងនោះគឺអាចដោយសារមានភាពរឹងមាំក្នុងថ្នាក់មូលដ្ឋាន ជំនួយពីខាងក្រៅដែលជួយកាត់បន្ថយការប្រឈម និងកង្វះការជំរុញទឹកចិត្តរបស់ថ្នាក់ដឹកនាំក្នុងការប្រព្រឹត្តឬអនុញ្ញាតឱ្យឧក្រិដ្ឋកម្មឃោរឃៅកើតឡើង ឬគ្រាន់តែដោយសារអវត្តមាននៃព្រឹត្តិការណ៍បង្កហេតុ។ ផ្ទុយទៅវិញ ព្រឹត្តិការណ៍ដែលមិនបានគិតទុកមុនអាចរំខានដល់ខ្សែវិវត្តនៃព្រឹត្តិការណ៍ដែលគួរកើតមានឡើង។

However, although it is impossible to draw a direct causal relation between the presence of particular risk factors and the occurrence of atrocity crimes, these crimes are **rarely committed in the absence of all or most of the risk factors** that the Framework identifies.

**To be effective, assessments require the systematic collection of accurate and reliable information based on the risk factors and indicators that the framework identifies.**

**ដើម្បីឱ្យមានប្រសិទ្ធភាព ការវាយតម្លៃតម្រូវឱ្យមានការប្រមូលផ្តុំជាប្រព័ន្ធនៃពត៌មានដែលសុក្រិត និងអាចជឿទុកចិត្តបាន ដែលផ្អែកលើកត្តាហានិភ័យនិងសូចនាករដែលក្របខ័ណ្ឌកំណត់។**

ទោះជាយ៉ាងនេះ ថ្វីបើកត្តាហានិភ័យទាំងនេះមិនអាចចាត់ទុកថាជាមូលហេតុផ្ទាល់ដែលតែងតែនាំឧក្រិដ្ឋកម្មឃោរឃៅ **តែបើពុំមានកត្តាហានិភ័យដែលក្របខ័ណ្ឌកំណត់ ឧក្រិដ្ឋកម្មឃោរឃៅក៏កម្រនឹងកើតមានឡើងដែរ**។

# II. FRAMEWORK OF ANALYSIS FOR ATROCITY CRIMES

# II. ក្របខ័ណ្ឌនៃការវិភាគសម្រាប់ឧក្រិដ្ឋកម្មឃោរឃៅ

## COMMON RISK FACTORS កត្តាហានិភ័យទូទៅ

| | | |
|---|---|---|
| Risk Factor<br>កត្តាហានិភ័យ | 1 | Situations of armed conflict or other forms of instability<br>ស្ថានការណ៍ក្នុងជម្លោះប្រដាប់អាវុធឬទម្រង់ផ្សេងៗទៀតនៃអស្ថិរភាព |
| Risk Factor<br>កត្តាហានិភ័យ | 2 | Record of serious violations of international human rights and humanitarian law<br>កំណត់ត្រានៃការរំលោភសិទ្ធិមនុស្សនិងច្បាប់មនុស្សអន្តរជាតិធ្ងន់ធ្ងរ |
| Risk Factor<br>កត្តាហានិភ័យ | 3 | Weakness of State structures ភាពទន់ខ្សោយនៃរចនាសម្ព័ន្ធរដ្ឋ |
| Risk Factor<br>កត្តាហានិភ័យ | 4 | Motives or incentives មូលហេតុ ឬ កត្តាជំរុញទឹកចិត្ត |
| Risk Factor<br>កត្តាហានិភ័យ | 5 | Capacity to commit atrocity crimes លទ្ធភាពក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ |
| Risk Factor<br>កត្តាហានិភ័យ | 6 | Absence of mitigating factors អវត្តមាននៃកត្តាកាត់បន្ថយ |
| Risk Factor<br>កត្តាហានិភ័យ | 7 | Enabling circumstances or preparatory action កាលៈទេសៈអំណោយផល ឬ សកម្មភាពរៀបចំ |
| Risk Factor<br>កត្តាហានិភ័យ | 8 | Triggering factors កត្តាបង្កហេតុ |

## SPECIFIC RISK FACTORS កត្តាហានិភ័យជាក់លាក់

### Genocide អំពើប្រល័យពូជសាសន៍

| | | |
|---|---|---|
| Risk Factor<br>កត្តាហានិភ័យ | 9 | Intergroup tensions or patterns of discrimination against protected groups<br>ភាពតានតឹងអន្តរក្រុម ឬ លំនាំគំរូនៃការរើសអើងប្រឆាំងនឹងក្រុមត្រូវបានការពារ |
| Risk Factor<br>កត្តាហានិភ័យ | 10 | Signs of an intent to destroy in whole or in part a protected group<br>សញ្ញានៃចេតនាក្នុងការបំផ្លាញទាំងមូលឬមួយផ្នែកនៃក្រុមដែលត្រូវបានការពារ |

### Crimes against humanity ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

| | | |
|---|---|---|
| Risk Factor<br>កត្តាហានិភ័យ | 11 | Signs of a widespread or systematic attack against any civilian population<br>សញ្ញានៃការវាយប្រហារីករាលដាលនិងជាប្រព័ន្ធ មកលើក្រុមប្រជាជនស៊ីវិលណាមួយ |
| Risk Factor<br>កត្តាហានិភ័យ | 12 | Signs of a plan or policy to attack any civilian population<br>សញ្ញានៃផែនការ ឬ គោលនយោបាយវាយប្រហារក្រុមប្រជាជនស៊ីវិលណាមួយ |

## War crimes ឧក្រិដ្ឋកម្មសង្គ្រាម

| | | |
|---|---|---|
| Risk Factor<br>កត្តាហានិភ័យ | 13 | Serious threats to those protected under international humanitarian law<br>ការគំរាមកំហែងធ្ងន់ធ្ងរលើអ្នកដែលត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិ |
| Risk Factor<br>កត្តាហានិភ័យ | 14 | Serious threats to humanitarian or peacekeeping operations<br>ការគំរាមកំហែងធ្ងន់ធ្ងរដល់ប្រតិបត្តិការមនុស្សធម៌ ឬរក្សាសន្តិភាព |

RISK FACTOR 1
កត្តាហានិភ័យ ១

# Situations of armed conflict or other forms of instability

ស្ថានការណ៍ក្នុងជម្លោះប្រដាប់អាវុធឬអស្ថិរភាពក្នុងទម្រង់ផ្សេងៗទៀត

## Situations that place a State under stress and generate an environment conducive to atrocity crimes.

ស្ថានភាពដែលធ្វើឱ្យរដ្ឋស្ថិតនៅក្រោមភាពតានតឹងនិងបង្កើតបរិយាកាសដែលអំណោយផលដល់ឧក្រិដ្ឋកម្មឃោរឃៅ។

| Indicators សូចនករ | |
|---|---|
| 1.1 | International or non-international armed conflict. ជម្លោះប្រដាប់អាវុធលក្ខណៈអន្តរជាតិឬមិនអន្តរជាតិ។ |
| 1.2 | Security crisis caused by, among other factors, defection from peace agreements, armed conflict in neighboring countries, threats of external interventions or acts of terrorism.<br>ក្នុងចំណោមកត្តាផ្សេងៗមានដូចជា វិបត្តិសន្តិសុខដែលបង្កឡើងដោយ ការដកខ្លួនពីកិច្ចព្រមព្រៀងសន្តិភាព ជម្លោះប្រដាប់អាវុធក្នុងប្រទេសជិតខាង ការគំរាមកំហែងធ្វើអន្តរាគមន៍ពីខាងក្រៅ ឬ អំពើភេរវកម្ម។ |
| 1.3 | Humanitarian crisis or emergency, including those caused by natural disasters or epidemics.<br>វិបត្តិមនុស្សធម៌ ឬការប្រកាសអាសន្ន រួមមានហេតុការណ៍គ្រោះមហន្តរាយធម្មជាតិ ឬរោគរាតត្បាតរហ័ស។ |
| 1.4 | Political instability caused by abrupt or irregular regime change or transfer of power.<br>អស្ថិរភាពនយោបាយដែលបានបង្កឡើងដោយការផ្លាស់ប្តូររបប ឬ ការផ្ទេរអំណាចរហ័ស ឬ មិនទៀងទាត់។ |
| 1.5 | Political instability caused by disputes over power or growing nationalist, armed or radical opposition movements.<br>អស្ថិរភាពនយោបាយបានដែលបង្កឡើងដោយជម្លោះដណ្តើមអំណាចឬកំណើនជាតិនិយម ចលនាប្រដាប់អាវុធឬចលនាប្រឆាំង។ |
| 1.6 | Political tension caused by autocratic regimes or severe political repression.<br>ភាពតានតឹងផ្នែកនយោបាយដែលបង្កឡើងដោយរបបផ្តាច់ការ ឬការគាបសង្កត់នយោបាយធ្ងន់ធ្ងរ។ |
| 1.7 | Economic instability caused by scarcity of resources or disputes over their use or exploitation.<br>អស្ថិរភាពសេដ្ឋកិច្ចដែលបង្កឡើងដោយភាពកង្វះនៃធនធាន ឬជម្លោះលើការប្រើប្រាស់ឬការកេងប្រវ័ញ្ច។ |
| 1.8 | Economic instability caused by severe crisis in the national economy.<br>អស្ថិរភាពសេដ្ឋកិច្ចដែលបង្កឡើងដោយវិបត្តិធ្ងន់ធ្ងរនៅក្នុងសេដ្ឋកិច្ចជាតិ។ |
| 1.9 | Economic instability caused by acute poverty, mass unemployment or deep horizontal inequalities.<br>អស្ថិរភាពសេដ្ឋកិច្ចដែលបង្កឡើងដោយភាពក្រីក្រខ្លាំង ភាពអត់ការងារធ្វើ ឬ វិសមភាពសង្គម។ |
| 1.10 | Social instability caused by resistance to or mass protests against State authority or policies.<br>អស្ថិរភាពក្នុងសង្គមដែលបង្កឡើងដោយការតស៊ូឬបាតុកម្មមហាជនប្រឆាំងនឹងអាជ្ញាធរឬគោលនយោបាយ។ |
| 1.11 | Social instability caused by exclusion or tensions based on identity issues, their perception or extremist forms.<br>អស្ថិរភាពសង្គមបានបង្កឡើងដោយការបដិសេធឬភាពតានតឹងផ្អែកលើបញ្ហាអត្តសញ្ញាណ លើទស្សនៈឬទម្រង់និយមជ្រុល។ |

## Comment:

Atrocity crimes usually take place against a background of either an international or non-international armed conflict. Armed conflicts are periods characterized by a high incidence of violence, insecurity and the permissibility of acts that would otherwise not be acceptable. In addition, the capacity of States to inflict harm is usually at its peak during periods of conflict. If armed conflict is a violent way of dealing with problems, it is clear that the risk of atrocity crimes acutely increases during these periods. However, other situations that are not typical armed conflicts canalso put a State under such a level of stress that it becomes more prone to serious human rights violations and, eventually, to atrocity crimes. In fact, genocide and crimes against humanity can also occur during times of peace.This is most likely when there are serious levels of political instability, threats to the security of the country or evenvolatility in economic or social affairs. Although situations of instability, or even of armed conflict, will not necessarilylead to the occurrence of atrocity crimes, they highly increase the likelihood of those crimes.

### មតិយោបល់:

ឧក្រិដ្ឋកម្មឃោរឃៅជាធម្មតាកើតឡើងក្នុងជម្លោះប្រដាប់អាវុធលក្ខណៈអន្តរជាតិឬមិនអន្តរជាតិ។ ជម្លោះប្រដាប់អាវុធជា ពេលដែលមានអំពើហិង្សាខ្ពស់ អសន្តិសុខ និង ពេលដែលអំពើមួយចំនួនជាធម្មតាមិនអាចទទួលយកបាន លើសពីនេះទៀត សមត្ថភាពរបស់រដ្ឋក្នុងបង្កការខូចខាតឈានដល់ចំណុចកំពូលរបស់ខ្លួននៅក្នុងអំឡុងពេលនេះ។ ប្រសិនបើមានជម្លោះប្រដាប់អាវុធក្លាយជាវិធីហិង្សាក្នុងការដោះស្រាយបញ្ហា វាច្បាស់ណាស់ថាហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅនឹងកើនឡើងក្នុងអំឡុងពេលនេះ។ ទោះយ៉ាងនេះក្តី ក៏មានស្ថានភាពផ្សេងទៀតដែលមិនមែនជាជម្លោះប្រដាប់អាវុធធម្មតា តែអាចធ្វើឱ្យរដ្ឋស្ថិតក្រោមកម្រិតនៃភាពតានតឹងដែលអាចងាយនឹងឈានដល់ការប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ហើយចុងក្រោយអាចឈានដល់ឧក្រិដ្ឋកម្មឃោរឃៅ។ ជាការពិត អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចកើតឡើងក្នុងអំឡុងពេលសន្តិភាពផងដែរ។ ជាពិសេសនៅពេលមានអស្ថិរភាពនយោបាយកម្រិតធ្ងន់ធ្ងរ ការគំរាមកំហែងដល់សន្តិសុខនៃប្រទេស ឬភាពប្រែប្រួលរហ័សនៃបញ្ហាសេដ្ឋកិច្ច ឬ សង្គម។ ទោះបីជាស្ថានការណ៍អស្ថិរភាព ឬ សូម្បីតែមានជម្លោះប្រដាប់អាវុធនឹងមិនតែងតែចាំបាច់ នាំឱ្យមានការកើតឡើងនៃឧក្រិដ្ឋកម្មឃោរឃៅក្តី ផ្ទុយទៅវិញឧក្រិដ្ឋកម្មទាំងនោះក៏កើនឡើងខ្ពស់ដែរ។

RISK FACTOR 2
កត្តាហានិភ័យ ២

## Record of serious violations of international human rights and humanitarian law

កំណត់ត្រានៃការរំលោភច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិធ្ងន់ធ្ងរ

**Past or current serious violations of international human rights and humanitarian law, particularly if assuming an early pattern of conduct, and including those amounting to atrocity crimes, that have not been prevented, punished or adequately addressed and, as a result, create a risk of further violations.**

**ការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់សិទ្ធិមនុស្សច្បាប់មនុស្សធម៌អន្តរជាតិ ទោះពីអតីតកាលឬបច្ចុប្បន្ន ជាពិសេសការបើមានគំរូផ្តើមនៃការប្រព្រឹត្ត រួមទាំងសកម្មភាពដែលអាចឈានដល់ឧក្រិដ្ឋកម្មឃោរឃៅ ដែលមិនត្រូវបានរារាំង ផ្តន្ទាទោស ដោះស្រាយគ្រប់គ្រាន់នោះ អាចក្លាយជាលទ្ធផលការបង្កើតឱ្យមានហានិភ័យនៃការរំលោភបំពានបន្ថែមតទៅទៀត។**

## Indicators សូចនាករ

**2.1** Past or present serious restrictions to or violations of international human rights and humanitarian law, particularly if assuming an early pattern of conduct and if targeting protected groups, populations or individuals.

ការដាក់កម្រិតធ្ងន់ធ្ងរពីអតីតកាលឬបច្ចុប្បន្ននៃឬការរំលោភបំពានច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិ ជាពិសេសបើគំរូផ្តើមបានចាប់ប្រព្រឹត្ត ទៅលើក្រុមប្រជាជនឬបុគ្គលដែលត្រូវបានការពារ ។

**2.2** Past acts of genocide, crimes against humanity, war crimes or their incitement.

អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឬការញុះញង់ក្នុងអតីតកាល។

**2.3** Policy or practice of impunity for or tolerance of serious violations of international human rights and humanitarian law, of atrocity crimes, or of their incitement.

គោលនយោបាយឬការអនុវត្តនៃនិទណ្ឌភាពឬការអត់ឱនចំពោះការរំលោភច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិយ៉ាងធ្ងន់ធ្ងរ ឧក្រិដ្ឋកម្មឃោរឃៅ ឬការញុះញង់។

**2.4** Inaction, reluctance or refusal to use all possible means to stop planned, predictable or ongoing serious violations of international human rights and humanitarian law or likely atrocity crimes, or their incitement.

ភាពអសកម្ម ភាពមិនខ្វាយខ្វល់ ឬការបដិសេធក្នុងការប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ដែលអាចទៅរួចដើម្បីបញ្ឈប់ការរំលោភបំពានធ្ងន់ធ្ងរនៃការរំលោភសិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិ ដែលព្យាករឃើញឬកំពុងកើតឡើងយ៉ាងធ្ងន់ធ្ងរឬឧក្រិដ្ឋកម្មឃោរឃៅដែលនឹងអាចកើតឡើង ឬការញុះញង់។

**2.5** Continuation of support to groups accused of involvement in serious violations of international human rights and humanitarian law, including atrocity crimes, or failure to condemn their actions.

ការបន្តការគាំទ្រដល់ក្រុមត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងបទល្មើសធ្ងន់ធ្ងរនៃច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិនិងរួមទាំងឧក្រិដ្ឋកម្មឃោរឃៅ ឬការមិនបានថ្កោលទោសចំពោះសកម្មភាពទាំងនោះ។

**2.6** Justification, biased accounts or denial of serious violations of international human rights and humanitarian law or atrocity crimes.

ការវិនិច្ឆ័យ ភាពលម្អៀងឬការបដិសេធនៃការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិ ឬឧក្រិដ្ឋកម្មឃោរឃៅ។

**2.7** Politicization or absence of reconciliation or transitional justice processes following conflict.

ការធ្វើនយោបាយកម្មឬអវត្តមាននៃដំណើរការផ្សះផ្សាជាតិ ឬយុត្តិធម៌អន្តរកាលក្រោយជម្លោះ។

**2.8** Widespread mistrust in State institutions or among different groups as a result of impunity.

ការរីករាលដាលនៃភាពមិនទុកចិត្តនៅក្នុងស្ថាប័នរដ្ឋឬក្នុងចំណោមក្រុមផ្សេងៗដែលជាលទ្ធផលនៃនិទណ្ឌភាព។

## Comment:

Societies that have a history of violence and serious violations of international human rights and humanitarian law or atrocity crimes, or where these are currently taking place, can be more prone to further atrocity crimes. As history has demonstrated, atrocity crimes in general and genocide in particular are preceded by less widespread or systematic serious violations of international human rights and humanitarian law.

### មតិយោបល់

សង្គមដែលធ្លាប់មានអំពើហិង្សានិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៃច្បាប់សិទ្ធិមនុស្ស និង ច្បាប់មនុស្សធម៌អន្តរជាតិ និងឧក្រិដ្ឋកម្មឃោរឃៅ ឬនៅកន្លែងដែលកំពុងតែកើតមានរឿងទាំងនេះ ងាយនឹងកើតមានឡើងនូវឧក្រិដ្ឋកម្មឃោរឃៅបន្តបន្ទាប់បន្ថែមទៀត។ ដូចដែលប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា ឧក្រិដ្ឋកម្មឃោរឃៅទូទៅនិងអំពើប្រល័យពូជសាសន៍ជាពិសេសគឺកើតឡើងបន្ទាប់ពីមានការរំលោភបំពានរាលដាលកម្រិតតូចឬមិនមានលក្ខណៈជាប្រព័ន្ធយ៉ាងធ្ងន់ធ្ងរនៃច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ។

These are typically violations of civil and political rights, but they may include also severe restrictions to economic, social and cultural rights, often linked to patterns of discrimination or exclusion of protected groups, populations or individuals. This risk factor is also relevant where the legacies of past atrocity crimes have not been adequately addressed through individual criminal accountability, reparation, truth-seeking and reconciliation processes, as well as comprehensive reform measures in the security and judicial sectors. A society in this situation is more likely to resort again to violence as a form of addressing problems.

ការរំលោភសិទ្ធិបែបនេះជាធម្មតាគឺទៅលើសិទ្ធិស៊ីវិលនិងនយោបាយ ប៉ុន្តែក៏អាចនឹងរួមបញ្ចូលការដាក់កម្រិតធ្ងន់ធ្ងរដល់សិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌ ដែលជាញឹកញាប់ផ្សារភ្ជាប់ទៅនឹងទម្រង់នៃការរើសអើង ឬការមិនរាប់បញ្ចូលក្រុម ប្រជាជន ឬបុគ្គលដែលត្រូវបានការពារ។ កត្តាហានិភ័យនេះគឺពាក់ព័ន្ធទៅនឹងកេរដំណែលនៃឧក្រិដ្ឋកម្មឃោរឃៅដែលមិនត្រូវបានដោះស្រាយគ្រប់គ្រាន់តាមរយៈការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល សំណង ការស្វែងរកការពិត និងការដំណើរការផ្សះផ្សាព្រមទាំងវិធានការកំណែទម្រង់ទូលំទូលាយក្នុងវិស័យសន្តិសុខនិងតុលាការ។ សង្គមនៅក្នុងស្ថានភាពនេះគឺងាយងាកជាថ្មីម្តងទៀតទៅរកអំពើហិង្សាក្នុងការដោះស្រាយបញ្ហា។

RISK FACTOR 3
កត្តាហានិភ័យ ៣

## Weakness of State structures ភាពទន់ខ្សោយនៃរចនាសម្ព័ន្ធរដ្ឋ

### Circumstances that negatively affect the capacity of a State to prevent or halt atrocity crimes.

កាលៈទេសៈ ដែលប៉ះពាល់ជាអវិជ្ជមានដល់សមត្ថភាពរបស់រដ្ឋក្នុងបង្ការឬបញ្ឈប់ឧក្រិដ្ឋកម្មឃោរឃៅ។

## Indicators សូចនាករ

**3.1** National legal framework that does not offer ample and effective protection, including through ratification and domestication of relevant international human rights and humanitarian law treaties.

ក្របខ័ណ្ឌច្បាប់ជាតិដែលមិនផ្តល់ការការពារច្រើននិងមានប្រសិទ្ធភាព រួមទាំងតាមរយៈការផ្តល់សច្ចាប័ននិងការផ្សាំងបញ្ចូលនូវសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធនិងសន្ធិសញ្ញាមនុស្សធម៌នានា។

**3.2** National institutions, particularly judicial, law enforcement and human rights institutions that lack sufficient resources, adequate representation or training.

ស្ថាប័នជាតិ ពិសេសតុលាការ ស្ថាប័នដែលអនុវត្តច្បាប់និងស្ថាប័នសិទ្ធិមនុស្ស ដែលខ្វះធនធាន ការតំណាងមិនគ្រប់គ្រាន់ ឬខ្វះការបណ្តុះបណ្តាល។

**3.3** Lack of an independent and impartial judiciary. កង្វះនៃប្រព័ន្ធតុលាការឯករាជ្យនិងមិនលំអៀង។

**3.4** Lack of effective civilian control of security forces.

ខ្វះប្រសិទ្ធភាពនៃការត្រួតពិនិត្យខាងស៊ីវិលលើកងកម្លាំងសន្តិសុខ។

**3.5** High levels of corruption or poor governance. កម្រិតខ្ពស់នៃអំពើពុករលួយឬភាពទន់ខ្សោយនៃអភិបាលកិច្ច។

**3.6** Absence or inadequate external or internal mechanisms of oversight and accountability, including those where victims can seek recourse for their claims.

អវត្តមានឬភាពមិនគ្រប់គ្រាន់នៃយន្តការខាងក្រៅឬខាងក្នុងក្នុងការត្រួតពិនិត្យនិងការទទួលខុសត្រូវ រួមទាំងកន្លែងដែលជនរងគ្រោះអាចស្វែងធនធានសម្រាប់ពាក្យបណ្តឹងរបស់ពួកគេ។

**3.7** Lack of awareness of and training on international human rights and humanitarian law to military forces, irregular forces and non-State armed groups, or other relevant actors.

កង្វះការយល់ដឹងអំពីនិងកង្វះការបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិសម្រាប់កងកម្លាំងយោធា កងកម្លាំងប្រដាប់អាវុធក្រៅក្របខ័ណ្ឌនិងក្រុមធោធាមិនមែនរបស់រដ្ឋ ឬក្រុមពាក់ព័ន្ធផ្សេងៗទៀត។

**3.8** Lack of capacity to ensure that means and methods of warfare comply with international humanitarian law standards.

កង្វះសមត្ថភាពដើម្បីធានាថាមធ្យោបាយនិងវិធីសាស្ត្រធ្វើសង្គ្រាមគោរពតាមបទដ្ឋានច្បាប់មនុស្សធម៌អន្តរជាតិ។

**3.9** Lack of resources for reform or institution-building, including through regional or international support.

កង្វះធនធានសម្រាប់ការធ្វើកំណែទម្រង់ ឬការកសាងស្ថាប័ន រួមទាំងតាមរយៈការគាំទ្រពីតំបន់ឬអន្តរជាតិ។

**3.10** Insufficient resources to implement overall measures aimed at protecting populations.

ធនធានមិនគ្រប់គ្រាន់ដើម្បីអនុវត្តវិធានការរួម ក្នុងគោលបំណងដើម្បីការពារប្រជាជន។

## Comment:

The risk of atrocity crimes can be increased by a State's lack of capacity to prevent these crimes. A State protects its population through the establishment of frameworks and institutions that are guided by the rule of law and good governance principles. However, when such structures are inadequate or simply do not exist, the ability of the State to prevent atrocity crimes is significantly diminished. As a consequence, populations are left vulnerable to those who may take advantage of the limitations or the dysfunction of State machinery, or to those that may opt for violence to respond to real or perceived threats.

មតិយោបល់

ហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅនេះអាចនឹងត្រូវបានបង្កើនឡើងបើរដ្ឋខ្វះសមត្ថភាពក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ។ រដ្ឋការពារប្រជាជនរបស់ខ្លួនតាមរយៈការបង្កើតក្របខ័ណ្ឌនិងស្ថាប័នដែលដឹកនាំដោយនីតិរដ្ឋនិងគោលការណ៍អភិបាលកិច្ចល្អ។ ទោះជាយ៉ាងណានៅពេលដែលរចនាសម្ព័ន្ធរបស់រដ្ឋមិនមានលក្ខណៈគ្រប់គ្រាន់ឬគ្មានសោះតែម្តង សមត្ថភាពរបស់រដ្ឋក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅត្រូវបានថយចុះយ៉ាងខ្លាំង។ ជាលទ្ធផលប្រជាជននឹងងាយរងគ្រោះដោយអ្នកដែលអាចទាញយកឱកាសពីភាពមានកម្រិតឬដំណើរការច្របូកច្របល់នៃយន្តការរបស់រដ្ឋ ឬដោយក្រុមដែលជ្រើសរើសយកអំពើហិង្សាដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងពិតឬដោយការគិតរបស់ខ្លួន។

This is even more the case in a situation of armed conflict, when it is paramount that those resorting to the use of force are fully aware of and respect the rules that aim to protect populations from such force, and have the necessary means to do so. The weakness of State structures will not necessarily be a cause of atrocity crimes, but it undoubtedly decreases the level of protection and, when analysed in conjunction with other risk factors, increases the probability of atrocity crimes.

ករណីបែបនេះមានកាន់តែច្រើននៅក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ ដែលនៅអំឡុងពេលនេះ អ្នកដែលប្រើកម្លាំងអាវុធត្រូវដឹងនិងគោរពច្បាប់ដែលមានគោលបំណងការពារប្រជាជនពីកម្លាំងអាវុធ វារឿងដែលសំខាន់បំផុត ព្រោះពួកគេមានមធ្យោបាយ ។ ពេលដែលធ្វើការវិភាគដោយភ្ជាប់ជាមួយកត្តាហានិភ័យដទៃទៀត ភាពទន់ខ្សោយនៃរចនាសម្ព័ន្ធរបស់រដ្ឋបង្កើនប្រូបាប៊ីលីតេនៃឧក្រិដ្ឋកម្មឃោរឃៅ ទោះជាវាមិនរមែងជាបុព្វហេតុនៃឧក្រិដ្ឋកម្មឃោរឃៅ ប៉ុន្តែច្បាស់ណាស់វាជាការកាត់បន្ថយកម្រិតនៃការការពារ។

RISK FACTOR 4
កត្តាហានិភ័យ ៤

## Motives or incentives មូលហេតុ ឬ កត្តាជំរុញទឹកចិត្ត

**Reasons, aims or drivers that justify the use of violence against protected groups, populations or individuals, including by actors outside of State borders.**

មូលហេតុ គោលបំណង ឬចលករដែលការពារការប្រើប្រាស់អំពើហិង្សាមកលើក្រុម ប្រជាជន ឬបុគ្គលដែលបានការពាររួមទាំងភាគីនៅក្រៅព្រំដែនរដ្ឋ។

## Indicators

**4.1** Political motives, particularly those aimed at the attainment or consolidation of power.

មូលហេតុនយោបាយ ជាពិសេសអ្នកដែលមានគោលបំណងចាប់យកឬប្រមូលផ្តុំអំណាច។

**4.2** Economic interests, including those based on the safeguard and well-being of elites or identity groups, or control over the distribution of resources.

ផលប្រយោជន៍សេដ្ឋកិច្ច រួមបញ្ចូលទាំងគោលដៅដែលមានមូលដ្ឋានលើការការពារនិងសុខុមាលភាពនៃក្រុមឥស្សរជនជាន់ខ្ពស់ឬក្រុមអត្តសញ្ញាណណាមួយ ឬដើម្បីការគ្រប់គ្រងលើការចែកចាយធនធាន។

**4.3** Strategic or military interests, including those based on protection or seizure of territory and resources.

ផលប្រយោជន៍យុទ្ធសាស្ត្រ ឬ យោធា រួមបញ្ចូលទាំងគោលដៅដែលមានមូលដ្ឋានលើការការពារឬការរឹបអូសយកទឹកដីនិងធនធាន។

**4.4** Other interests, including those aimed at rendering an area homogeneous in its identity.

ផលប្រយោជន៍ផ្សេងៗទៀត រួមបញ្ចូលទាំងគោលដៅក្នុងការបង្ហាញឱ្យឃើញតំបន់មានអត្តសញ្ញាណជាតិដើម។

**4.5** Real or perceived threats posed by protected groups, populations or individuals, against interests or objectives of perpetrators, including perceptions of disloyalty to a cause.

គំរាមកំហែងពិតឬការគិតថាមានការគំរាមកំហែងដែលបង្កឡើងដោយក្រុមប្រជាជនឬបុគ្គលដែលត្រូវបានការពារ ទៅលើផលប្រយោជន៍ឬគោលបំណងនៃជនល្មើស រួមទាំងការគិតថាមានភាពមិនស្មោះត្រង់លើបុព្វហេតុមួយរបស់ពួកគេ។

**4.6** Real or perceived membership of or support for armed opposition groups, by protected groups, populations or individuals.

សមាជិកពិតប្រាកដឬការយល់ឃើញថាជាសមាជិកនៃឬការគាំទ្រក្រុមប្រឆាំងប្រដាប់អាវុធ ដោយក្រុមប្រជាជនឬបុគ្គលដែលបានការពារ។

**4.7** Ideologies based on the supremacy of a certain identity or on extremist versions of identity.

មនោគមវិជ្ជាផ្អែកលើភាពកំពូលលើគេនៃអត្តសញ្ញាណជាក់លាក់មួយ ឬលើភាពនិយមជ្រុលនៃអត្តសញ្ញាណ។

**4.8** Politicization of past grievances, tensions or impunity.

ការធ្វើនយោបាយកម្មលើការតវ៉ាភាពតានតឹង ឬនិទណ្ឌភាពពីអតីតកាល។

**4.9** Social trauma caused by past incidents of violence not adequately addressed and that produced feelings of loss, displacement, injustice and a possible desire for revenge.

ភាពបាក់ស្បាតក្នុងសង្គម ដែលបណ្តាលមកពីអំពើហិង្សាកន្លងមកដែលមិនត្រូវបានដោះស្រាយគ្រប់គ្រាន់ ដែលបានបង្កើតអារម្មណ៍ ថាបាត់បង់ ភៀសខ្លួន អយុត្តិធម៌ និង មានបំណងចង់សងសឹក។

**Comment:**

The motives or incentives that lead perpetrators to commit atrocity crimes are not elements of the legal definition

of those crimes and are therefore not relevant to determine individual criminal responsibility. However, from an early warning perspective, it is extremely important to be able to identify motivations, aims or drivers that could influence certain individuals or groups to resort to massive violence as a way to achieve goals, feed an ideology or respond to real or perceived threats.

មតិយោបល់

ហេតុផលឬកត្តាជំរុញទឹកចិត្តនាំឱ្យជនល្មើសប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅមិនមែនជាធាតុនៃនិយមន័យច្បាប់នៃបទល្មើសទាំងនោះទេហើយដូច្នេះកត្តាទាំងនោះមិនមានជាប់ពាក់ព័ន្ធក្នុងការកំណត់ជនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ទោះយ៉ាងណានេះក្តី ក្នុងការប្រុងប្រយ័ត្នជាមុន វាសំខាន់ណាស់ក្នុងការដែលអាចកំណត់ ការជំរុញទឹកចិត្ត គោលបំណង ឬ ចលករ ដែលអាចជះឥទ្ធិពលដល់បុគ្គលឬក្រុមណាមួយឱ្យប្រើអំពើហិង្សាទ្រង់ទ្រាយធំជាមធ្យោបាយដើម្បីសម្រេចបានគោលដៅ ការបណ្តុះមនោគមវិជ្ជា ឬឆ្លើយតបទៅនឹងការគំរាមកំហែងពិតឬដោយការគិតរបស់ពួកគេ។

On one hand, to do so allows for a higher degree of prediction of the likelihood of those crimes. On the other, it opens the opportunity to develop prevention strategies aimed at neutralizing or curbing those motives or incentives. No one specific motive or incentive will automatically lead to atrocity crimes, but certain motives or incentives are more likely to, especially those that are based on exclusionary ideology, which is revealed in the construction of identities in terms of “us” and “them” to accentuate differences. The historical, political, economic or even cultural environment in which such ideologies develop can also be relevant.

ម្យ៉ាងវិញទៀត ការធ្វើបែបនេះអាចសម្រេចការព្យាករត្រឹមត្រូវកម្រិតខ្ពស់នៃការកើតមានឧក្រិដ្ឋកម្មទាំងនោះ។ ម្យ៉ាងមួយទៀត វាជាឱកាសដើម្បីបង្កើតយុទ្ធសាស្រ្តទប់ស្កាត់ក្នុងគោលបំណង លុបបំបាត់ឬកាត់បន្ថយ ហេតុផលឬកត្តាជំរុញទឹកចិត្ត។ គ្មានមូលហេតុ ឬកត្តាជំរុញចិត្តច្បាស់លាស់តែមួយណាដែលនាំដល់ឧក្រិដ្ឋកម្មឃោរឃៅកើតឡើងដោយស្វ័យប្រវត្តិនោះទេ តែមានមូលហេតុ ឬកត្តាជំរុញចិត្តមួយចំនួនដែលរមែងតែងតែជាអ្នកបង្ក ជាពិសេសប្រភេទដែលផ្អែកលើមនោគមវិជ្ជាបំបែក ដកចេញ ដែលតែងលេចចេញពេលមានការបង្កើតអត្តសញ្ញាណ "យើង" និង "ឯង" ដើម្បីសង្កត់ធ្ងន់លើភាពខុសគ្នា។ បរិយាកាសប្រវត្តិសាស្រ្ត នយោបាយ សេដ្ឋកិច្ច ឬសូម្បីតែវប្បធម៌ដែលផ្តល់ឱ្យមនោគមវិជ្ជាកើតឡើង ក៏ជាប់ពាក់ព័ន្ធផងដែរ។

RISK FACTOR 5

កត្តាហានិភ័យ ៥

# Capacity to commit atrocity crimes សមត្ថភាពក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ

## Conditions that indicate the ability of relevant actors to commit atrocity crimes.

លក្ខខណ្ឌដែលបង្ហាញពីលទ្ធភាពនៃភាគីដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ។

## Indicators

**5.1** Availability of personnel and of arms and ammunition, or of the financial resources, public or private, for their procurement.

លទ្ធភាពដែលអាចរកបាននៃសមាជិក អាវុធ និងគ្រាប់រំសេវ ឬធនធានហិរញ្ញវត្ថុសម្រាប់លទ្ធកម្ម សាធារណៈឬឯកជន ។

**5.2** Capacity to transport and deploy personnel and to transport and distribute arms and ammunition.

សមត្ថភាពក្នុងការដឹកជញ្ជូននិងដាក់ពង្រាយសមាជិកនិងការដឹកជញ្ជូននិងចែកចាយអាវុធនិងគ្រាប់រំសេវ។

**5.3** Capacity to encourage or recruit large numbers of supporters from populations or groups, and availability of the means to mobilize them.

សមត្ថភាពក្នុងការលើកទឹកចិត្តឬរើសបញ្ចូលអ្នកគាំទ្រក្នុងចំនួនច្រើនពីប្រជាជនឬក្រុមណាមួយ និងលទ្ធភាពនៃមធ្យោបាយដើម្បីប្រមូលផ្តុំពួកគេ។

**5.4** Strong culture of obedience to authority and group conformity.

វប្បធម៌ផ្តោតខ្លាំងលើការស្តាប់បង្គាប់ពីអ្នកមានអំណាចនិងអនុលោមភាពក្នុងក្រុម។

**5.5** Presence of or links with other armed forces or with non-State armed groups.

វត្តមានរបស់ឬទំនាក់ទំនងជាមួយកងកម្លាំងប្រដាប់អាវុធផ្សេងទៀតឬជាមួយក្រុមប្រដាប់អាវុធក្រៅផ្លូវការ។

**5.6** Presence of commercial actors or companies that can serve as enablers by providing goods, services, or other forms of practical or technical support that help sustain perpetrators.

វត្តមានរបសភាគីពាណិជ្ជកម្មឬក្រុមហ៊ុនដែលអាចជួយតាមរយៈការផ្តល់នូវសេវាកម្ម ទំនិញឬរូបភាពឬបច្ចេកទេសដទៃទៀតដែលជួយគាំទ្រជនល្មើស។

**5.7** Financial, political or other support of influential or wealthy national actors.

ហិរញ្ញវត្ថុ នយោបាយឬការគាំទ្រផ្សេងៗទៀតនៃភាគីក្នុងស្រុកដែលមានសក្តានុពលឬអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ។

**5.8** Armed, financial, logistic, training or other support of external actors, including States, international or regional organizations, private companies, or others.

ប្រដាប់អាវុធ, ហិរញ្ញវត្ថុ, ដឹកជញ្ជូន, ការបណ្តុះបណ្តាឬការគាំទ្រផ្សេងៗទៀតនៃភាគីខាងក្រៅរួមទាំងរដ្ឋ អង្គការអន្តរជាតិឬក្នុងតំបន់ ក្រុមហ៊ុនឯកជន ឬអ្នកដទៃទៀត។

## Comment:

Atrocity crimes are not easy to commit. In particular, genocide and crimes against humanity, but also several war crimes, are characterized by large-scale violence that requires a level of planning and that, in most cases, is sustained over a period of time. To be able to engage in such conduct, actors aiming at committing atrocity crimes must have at their disposal the necessary, substantial resources and support, either internal or external.

### មតិយោបល់

ឧក្រិដ្ឋកម្មឃោរឃៅមិនងាយស្រួលប្រព្រឹត្តទេ។ ជាពិសេស ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួន ស្ថិតក្នុងរូបភាពអំពើហិង្សាទ្រង់ទ្រាយធំដែលតម្រូវឱ្យមានការរៀបចំផែនការដល់កម្រិតមួយដែលក្នុងករណីភាគច្រើនត្រូវការរយៈពេលយូរ។ ដើម្បីអាចចូលរួមក្នុងសកម្មភាពបែបនេះបានភាគីដែលមានបំណងប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅត្រូវការចាំបាច់នូវ ធនធាន ការគាំទ្រជាប់ជានិច្ចពីខាងក្នុងឬខាងក្រៅ។

That capacity can be intentionally developed or it can also be incidental. Accordingly, the fact that States or groups have the capacity to perpetrate atrocity crimes does not imply that they will commit them — for that, it is also necessary that they have the intention to make use of that capacity against a protected group, population or individual. Therefore, this risk factor must be assessed in conjunction with other factors. In contrast, those who do not have the capacity to commit atrocity crimes, i.e., where one or more of the indicators mentioned above are not present, will most likely not be able to put any plan into action, or will face serious challenges in its attempt to implement it.

សមត្ថភាពនោះអាចត្រូវបានបង្កើតដោយចេតនាឬចៃដន្យ។ អាស្រ័យហេតុនេះហើយ វាជាការពិតដែលថារដ្ឋឬក្រុមណាដែលមានសមត្ថភាពក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅមិនមានន័យថាពួកគេនឹងប្រាកដថាប្រព្រឹត្តនោះទេ លុះត្រាពួកគេមានបំណងក្នុងការប្រើសមត្ថភាពនោះប្រឆាំងនឹងក្រុមប្រជាជន ឬបុគ្គលដែលត្រូវបានការពារ។ ហេតុដូច្នេះកត្តាហានិភ័យមួយនេះត្រូវតែវាយតម្លៃដោយភ្ជាប់ជាមួយកត្តាដទៃទៀត។ ផ្ទុយទៅវិញអ្នកដែលមិនមានសមត្ថភាពក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ ឧទាហរណ៍ពេលសូចនាករមួយ ឬច្រើនដែលបានលើកឡើងខាងលើមិនមានវត្តមាន ក្នុងករណីនេះ ផែនការរបស់ពួកគេគួរតែមិនអាចអនុវត្តបានឬនឹងប្រឈមនឹងបញ្ហាធ្ងន់ធ្ងរបើព្យាយាមអនុវត្តនោះ។

# Absence of mitigating factors អវត្តមាននៃកត្តាកាត់បន្ថយ

## Absence of elements that, if present, could contribute to preventing or to lessening the impact of serious acts of violence against protected groups, populations or individuals.

អវត្តមាននៃធាតុ ដែលបើមានវត្តមាន អាចរួមចំណែកដល់ការរារាំងឬសម្រាលផលប៉ះពាល់ធ្ងន់ធ្ងរនៃអំពើហិង្សាមកលើក្រុមប្រជាជនឬបុគ្គលដែលត្រូវបានការពារ។

## Indicators សូចនាករ

**6.1** Limited or lack of empowerment processes, resources, allies or other elements that could contribute to the ability of protected groups, populations or individuals to protect themselves.

មានកម្រិតឬកង្វះដំណើរការពង្រឹងអំណាច ធនធាន សម្ពមន្ធមិត្ត ឬធាតុផ្សេងទៀតដែលអាចរួមចំណែកដល់លទ្ធភាពរបស់ក្រុមប្រជាជនឬបុគ្គលដែលបានការពារ ក្នុងការការពារខ្លួន។

**6.2** Lack of a strong, organized and representative national civil society and of a free, diverse and independent national media.

កង្វះតំណាងសង្គមស៊ីវិលជាតិដែលខ្លាំងនិងមានការរៀបចំ និងប្រព័ន្ធផ្សព្វផ្សាយថ្នាក់ជាតិមួយដែលសេរី ចម្រុះនិងឯករាជ្យ។

**6.3** Lack of interest and focus of international civil society actors or of access to international media.

កង្វះការចាប់អារម្មណ៍និងការផ្តោតរបស់ភាគីសង្គមស៊ីវិលអន្តរជាតិឬទំនាក់ទំនងទៅប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ។

**6.4** Lack of or limited presence of the United Nations, INGOs or other international or regional actors in the country and with access to populations.

កង្វះឬភាពមានកម្រិតនៃវត្តមានអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ឬ ភាគីអន្តរជាតិ ឬ ក្នុងតំបន់ ដែលនៅក្នុងប្រទេសនេះហើយមានទំនាក់ទំនងជាមួយប្រជាជន។

**6.5** Lack of membership and effective participation of the State in international or regional organizations that establish mandatory membership obligations.

កង្វះនៃការចូលជាសមាជិកនិងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋនៅក្នុងអង្គការអន្តរជាតិឬថ្នាក់តំបន់ដែលបង្កើតកាតព្វកិច្ចសមាជិកភាពចាំបាច់។

**6.6** Lack of exposure, openness or establishment of political or economic relations with other States or organizations.

កង្វះនៃការបង្ហាញ ភាពបើកចំហឬការបង្កើតទំនាក់ទំនងនយោបាយឬសេដ្ឋកិច្ចជាមួយប្រទេសឬអង្គការនានា។

**6.7** Limited cooperation of the State with international and regional human rights mechanisms.

កិច្ចសហប្រតិបត្តិការរបស់រដ្ឋជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិនិងតំបន់នៅមានកម្រិត។

**6.8** Lack of incentives or willingness of parties to a conflict to engage in dialogue, make concessions and receive support from the international community.

កង្វះកត្តាលើកទឹកចិត្តឬឆន្ទៈរបស់ភាគីជម្លោះដើម្បីចូលរួមក្នុងកិច្ចសន្ទនា ធ្វើសម្បទាននិងការទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ។

**6.9** Lack of interest, reluctance or failure of United Nations Member States or international or regional organizations to support a State to exercise its responsibility to protect populations from atrocity crimes, or to take action when the State manifestly fails that responsibility.

កង្វះការចាប់អារម្មណ៍ មានការស្ទាក់ស្ទើរ

ឬបរាជ័យនៃរដ្ឋជាសមាជិកអង្គការសហប្រជាជាតិឬអង្គការអន្តរជាតិឬតំបន់ដើម្បីគាំទ្រដល់រដ្ឋមួយអនុវត្តការទទួលខុសត្រូវរបស់ខ្លួនដើម្បីការពារប្រជាជនពីឧក្រិដ្ឋកម្មឃោរឃៅឬដើម្បីចាត់វិធានការពេលដែលរដ្ឋមួយនោះបានបរាជ័យមិនបានទទួលខុសត្រូវ។

**6.10** Lack of support by neighbouring States to protect populations at risk and in need of refuge, including by closure of borders, forced repatriation or aid restrictions.

កង្វះការគាំទ្រពីប្រទេសជិតខាងដើម្បីការពារប្រជាជនដែលមានហានិភ័យនិងជនភៀសខ្លួន ដូចជាការបិទព្រំដែន ការបង្ខំឱ្យធ្វើមាតុភូមិនិវត្ត ឬការរឹតបន្តឹងជំនួយ។

**6.11** Lack of an early warning mechanism relevant to the prevention of atrocity crimes.

កង្វះយន្តការព្រមានជាមុនដែលសមស្របនឹងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។

## Comment:

Atrocity crimes result from a convergence of elements, as demonstrated in this framework. Among those elements, some point more directly to the likelihood of atrocity crimes, while others might have a more indirect effect and seem secondary, or even too broad to merit consideration.

**មតិសំគាល់:**

ឧក្រិដ្ឋកម្មឃោរឃៅ កើតចេញពីការផ្សំគ្នានៃធាតុនានាដែលបានបង្ហាញក្នុងក្របខ&ណ្ឌនេះ។ ក្នុងចំណោមធាតុទាំងនោះ ខ្លះចង្អុលដោយ ផ្ទាល់ទៅនឹងលទ្ធភាពដែលអាចកើតឧក្រិដ្ឋកម្មឃោរឃៅ ខណៈធាតុខ្លះវិញអាចមានឥទ្ធិពលដោយប្រយោលនិងហាក់ដូចជាបន្ទាប់បន្សំ ឬអាចនឹងដូចជាទូលំទូលាយពេកដើម្បីចាត់ទុកជា មូលហេតុនៅក្នុងការពិចារណា។

However, even if indirect, these elements can contribute to preventing an escalation of violence or even to ending it and can therefore reduce the probability of atrocity crimes. Some of these elements can exist prior to the development of tensions, crises or conflict, while others can arise as a situation escalates. Such elements, either internal or external, are important to consider for early warning purposes.

ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែធាតុប្រយោលទាំងនេះអាចរួមចំណែកក្នុងការទប់ស្កាត់ការកើនឡើងនៃអំពើហិង្សាឬនឹងអាចបញ្ចប់វា និង ជួយដល់ការកាត់បន្ថយប្រូបាប៊ីលីតេនៃឧក្រិដ្ឋកម្មឃោរឃៅ។ ធាតុមួយចំនួនទាំងនេះអាចកើតមានមុនពេលភាពតានតឹង វិបត្តិឬការប៉ះទង្គិចគ្នាកើតមានឡើង ខណៈដែលធាតុខ្លះទៀតអាចកើតឡើងនៅពេលដែលស្ថានភាពអាក្រក់ទាំងនោះកំពុងរីករាលដាល។ ធាតុផ្សំទាំងនេះ ទោះមកពីខាងក្នុងឬខាងក្រៅគឺមានសារៈសំខាន់ដូចគ្នាក្នុងការពិចារណាដើម្បីគោលបំណងប្រុងប្រយ័ត្នទុកជាមុន។

RISK FACTOR 7
កត្តាហានិភ័យ ៧

# Enabling circumstances or preparatory action
**កាលៈទេសៈអំណោយផល ឬ សកម្មភាពរៀបចំទុកជាមុន**

**Events or measures, whether gradual or sudden, which provide an environment conducive to the commission of atrocity crimes, or which suggest a trajectory towards their perpetration.** ព្រឹត្តិការណ៍ឬចំណាត់ការមិនថាបន្តិចម្តងៗឬក៏ភ្លាមៗ ដែលផ្តល់នូវបរិយាកាសអំណោយផលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ ឬដែលបង្ហាញពីមុខព្រួញឆ្ពោះទៅកាន់ការប្រព្រឹត្តឧក្រិដ្ឋកម្ម។

## Indicators សូចនាករ

**7.1** Imposition of emergency laws or extraordinary security measures that erode fundamental rights.

ការប្រើច្បាប់គ្រាអាសន្នឬវិធានការសន្តិសុខវិសាមញ្ញដែលប៉ះពាល់សិទ្ធិមូលដ្ឋាន។

**7.2** Suspension of or interference with vital State institutions, or measures that result in changes in their composition or balance of power, particularly if this results in the exclusion or lack of representation of protected groups.

ការផ្អាកឬការជ្រៀតជ្រែកជាមួយស្ថាប័នរដ្ឋសំខាន់ណាស់ៗ ឬវិធានការនានាដែលឈានដល់ការផ្លាស់ប្តូរសមាសធាតុឬតុល្យភាពនៃអំណាច ជាពិសេសប្រសិនបើនេះជាលទ្ធផលពីការដកចេញឬកង្វះការតំណាងនៃក្រុមដែលត្រូវបានការពារ។

**7.3** Strengthening of the security apparatus, its reorganization or mobilization against protected groups, populations or individuals.

ការពង្រឹងប្រព័ន្ធ ការរៀបចំឡើងវិញ ឬការចល័តក្រុមសន្តិសុខ ដើម្បីប្រឆាំងនឹងក្រុម ប្រជាជន ឬបុគ្គលដែលត្រូវបានការពារ។

**7.4** Acquisition of large quantities of arms and ammunition or of other objects that could be used to inflict harm.

ការទិញអាវុធនិងគ្រាប់រំសេវឬវត្ថុផ្សេងទៀតក្នុងបរិមាណច្រើន ដែលអាចប្រើដើម្បីបង្ករបួស។

**7.5** Creation of, or increased support to, militia or paramilitary groups.

ការបង្កើតឬការបង្កើនការគាំទ្រដល់កម្លាំងជីវពលឬក្រុមយោធាប៉ារ៉ា។

**7.6** Imposition of strict control on the use of communication channels, or banning access to them.

ការត្រួតពិនិត្យយ៉ាងតឹងរឹង ឬការហាមឃាត់ការប្រើប្រាស់បណ្តាញទំនាក់ទំនង ការហាមឃាត់

**7.7** Expulsion or refusal to allow the presence of NGOs, international organizations, media or other relevant actors, or imposition of severe restrictions on their services and movements.

បណ្តេញចេញឬការបដិសេធមិនអនុញ្ញាតឱ្យមានវត្តមាននៃអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយ ឬភាគីដែលពាក់ព័ន្ធផ្សេងទៀត ឬការដាក់កំហិតធ្ងន់ធ្ងរលើសេវាកម្មនិងចលនារបស់ពួកគេ។

**7.8** Increased violations of the right to life, physical integrity, liberty or security of members of protected groups, populations or individuals, or recent adoption of measures or legislation that affect or deliberately discriminate against them.

ការកើនឡើងនៃការរំលោភបំពានសិទ្ធិរស់រានមានជីវិតសេចក្តីថ្លៃថ្នូររូបរាងកាយ សេរីភាពឬសុវត្ថិភាពនៃសមាជិកនៃក្រុម ប្រជាជនឬបុគ្គលដែលត្រូវបានការពារ ឬការអនុម័តថ្មីមួយនៃវិធានការឬច្បាប់ដែលប៉ះពាល់ដល់ឬចេតនាលើការរើសអើងប្រឆាំងនឹងក្រុមនេះ។

**7.9** Increased serious acts of violence against women and children, or creation of conditions that facilitate acts of sexual violence against those groups, including as a tool of terror.

ការកើនឡើងអំពើហឹង្សាធ្ងន់ធ្ងរ ឬការបង្កើតលក្ខខណ្ឌដែលជួយសម្រួលដល់ការប្រព្រឹត្តអំពើហិង្សាផ្លូវភេទប្រឆាំងស្រ្តីនិងកុមារដែលរួមបញ្ចូលទាំងការជាប្រើប្រាស់ហឹង្សានិងលក្ខខណ្ឌទាំងនេះជាឧបករណ៍នៃការបំភិតបំភ័យ។

**7.10** Imposition of life-threatening living conditions or the deportation, seizure, collection, segregation, evacuation, or forced displacement or transfer of protected groups, populations or individuals to camps, rural areas, ghettos or other assigned locations.

ការដាក់បង្ខំលក្ខខណ្ឌដែលគំរាមកំហែងដល់ការរស់ជីវិតឬការនិរទេស ការរឹបអូស ការប្រមូល ការបែងចែក ការជម្លៀស ឬការភៀសខ្លួនដោយបង្ខំ ឬការផ្ទេរ ក្រុម ប្រជាជនឬបុគ្គលដែលត្រូវបានការពារទៅជំរំតំបន់ជនបទ តំបន់ទីទ័លក្រ ឬទីតាំងដែលបានរៀបចំទុក។

**7.11** Destruction or plundering of essential goods or installations for protected groups, populations or individuals, or of property related to cultural and religious identity.

ការបំផ្លាញឬលួចប្លន់ទំនិញសំខាន់ៗឬការរៀបចំផ្សេងៗសម្រាប់ក្រុម ប្រជាជន ឬបុគ្គលដែលត្រូវបានការពារ ឬសម្បត្តិទាក់ទងទៅនឹងវប្បធម៌និងសាសនា។

**7.12** Marking of people or their property based on affiliation to a group.

ការបង្កើតក្រុមមនុស្សឬទ្រព្យសម្បត្តិរបស់ពួកគេដោយផ្អែកលើទំនាក់ទំនងឬការពាក់ព័ន្ធនឹងក្រុមណាមួយ។

**7.13** Increased politicization of identity, past events or motives to engage in violence.

ការកើននយោបាយកម្មនៃអត្តសញ្ញាណ ពីអតីតកាលឬហេតុផលក្នុងការប្រើអំពើហិង្សា។

**7.14** Increased inflammatory rhetoric, propaganda campaigns or hate speech targeting protected groups, populations or individuals.

ការកើនឡើងវោហាសាស្ត្រ យុទ្ធនាការឃោសនាបញ្ឆេះឬសម្តីស្អប់ខ្ពើមក្នុងគោលដៅប្រឆាំងនឹង ក្រុម ប្រជាជនឬបុគ្គលដែលត្រូវបានការពារ។

## Comment:

Atrocity crimes, and in particular genocide and crimes against humanity, are processes that take time to plan, coordinate and implement. They cannot be explained as isolated or spontaneous events that perpetrators decided to commit without some level of preparation. Also, as mentioned in a previous risk factor, perpetrators need to possess sufficient resources to be able to commit massive or widespread acts of violence. Such resources are not always readily available and can take time to assemble.

## មតិយោបល់:

ឧក្រិដ្ឋកម្មឃោរឃៅជាពិសេសអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាដំណើរការដែលត្រូវការពេលវេលា រៀបចំផែនការ ចាត់ចែង និងអនុវត្ត។ ឧក្រិដ្ឋកម្មទាំងនេះមិនអាចពន្យល់បានថាជាព្រឹត្តិការណ៍ដាច់ដោយឡែកតែឯង ឬដែលកើតឡើងដោយសារការសម្រេចចិត្តភ្លាមៗដោយគ្មានការរៀបចំទុកជាមុនក្នុងកម្រិតមួយនោះទេ។ ដូចគ្នានេះ ដូចដែលបានលើកឡើងនៅក្នុងកត្តាហានិភ័យកន្លងទៅហើយ ជនល្មើសត្រូវការ ធនធានគ្រប់គ្រាន់ដើម្បីអាចប្រព្រឹត្តអំពើហិង្សាទ្រង់ទ្រាយធំ ឬរីករាលដាលបាន។ ធនធានបែបនេះមិនតែងតែអាចរកបានទេ តែត្រូវ ចំណាយពេលវេលាដើម្បីប្រមូលផ្តុំ។

Consequently, throughout the development of these processes, it should be possible to identify events, actions or changes that point to the likelihood that certain actors are taking steps towards a scenario of mass violence and possibly atrocity crimes. Alternatively, such events, actions or changes can also serve to create an environment that favors or even encourages the commission of such crimes. Recognizing such indicators and establishing a causal link to the probability of atrocity crimes is not always easy, but it is of great relevance. As with all risk factors, analysis of this risk factor should take into consideration a context in which other risk factors might also be present.

ហេតុដូច្នេះហើយ ក្នុងអំឡុងពេលនៃការអភិវឌ្ឍដំណើរការទាំងនេះ ការកំណត់ប្រភេទព្រឹត្តិការណ៍ សកម្មភាពឬការផ្លាស់ប្តូរ ដែលចង្អុលបង្ហាញពីភវនីយភាពដែលភាគីណាមួយ កំពុងចាត់វិធានការឆ្ពោះទៅរកសេណារីយ៉ូនៃអំពើហិង្សាទ្រង់ទ្រាយធំនិងឧក្រិដ្ឋកម្មឃោរឃៅគឺអាចទៅរួច។ ជាជម្រើសមួយវិញទៀត ប្រភេទព្រឹត្តិការណ៍ សកម្មភាពឬការផ្លាស់ប្តូរក៏អាចបង្កើតបរិយាកាសដែលជួយឬញុះញង់ជំរុញដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះផងដែរ។ ការទទួលស្គាល់សូចនាករបែបនេះនិងការបង្កើតឱ្យឃើញពីទំនាក់ទំនងហេតុនិងព្រឹត្តិការណ៍ទាក់ទងនឹងប្រូបាប៊ីលីតេនៃឧក្រិដ្ឋកម្មឃោរឃៅគឺមិនមែនងាយស្រួលនោះទេ ប៉ុន្តែវាពិតជាមានសារៈសំខាន់ណាស់។ ដូចគ្នានឹងកត្តាគ្រោះថ្នាក់ទាំងអស់ ការវិភាគអំពីកត្តាហានិភ័យនេះគួរតែពិចារណាលើបរិបទមួយដែលថាមានកត្តាហានិភ័យផ្សេងៗទៀតផងដែរ។

## Triggering factors កត្តាបង្កហេតុ

**Events or circumstances that, even if seemingly unrelated to atrocity crimes, may seriously exacerbate existing conditions or may spark their onset.**

ព្រឹត្តិការណ៍ឬកាលៈទេសៈ ដែលទោះបីហាក់ដូចជាមិនទាក់ទងទៅនឹងឧក្រិដ្ឋកម្មឃោរឃៅ អាច
ធ្វើឱ្យលក្ខខណ្ឌដែលមានស្រាប់កាន់តែធ្ងន់ធ្ងរឡើងលើ ឬ បញ្ឆេះព្រឹត្តិការណ៍ដំបូង។

## Indicators សូចនាករ

**8.1** Sudden deployment of security forces or commencement of armed hostilities.

ការដាក់ពង្រាយកងកម្លាំងសន្តិសុខជាបន្ទាន់ឬការចាប់ផ្តើមនៃការគំរាមកំហែងប្រដាប់អាវុធ។

**8.2** Spillover of armed conflicts or serious tensions in neighbouring countries.

ការជះឥទ្ធិពលនៃជម្លោះប្រដាប់អាវុធឬភាពតានតឹងធ្ងន់ធ្ងរពីប្រទេសជិតខាង។

**8.3** Measures taken by the international community perceived as threatening to a States' sovereignty.

វិធានការរបស់សហគមន៍អន្តរជាតិត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់អធិបតេយ្យភាពរបស់រដ្ឋ។

**8.4** Abrupt or irregular regime changes, transfers of power, or changes in political power of groups.

ការផ្លាស់ប្តូររបបគ្រប់គ្រងរហ័សឬមិនទៀងទាត់ ឬការផ្ទេរអំណាចឬការផ្លាស់ប្តូរអំណាចនយោបាយរបស់ក្រុម។

**8.5** Attacks against the life, physical integrity, liberty or security of leaders, prominent individuals or members of opposing groups. Other serious acts of violence, such as terrorist attacks.

ការវាយប្រហារទៅលើជីវិតសេចក្តីថ្លៃថ្នូររូបរាងកាយ សេរីភាពឬសុវត្ថិភាពរបស់មេដឹកនាំ បុគ្គល ឬ សមាជិកដែលលេចធ្លោនៃក្រុមប្រឆាំង។ អំពើហិង្សាធ្ងន់ធ្ងរដទៃទៀត ដូចជាការវាយប្រហារភេរវកម្ម។

**8.6** Religious events or real or perceived acts of religious intolerance or disrespect, including outside national borders.

ព្រឹត្តិការណ៍សាសនាពិតឬការយល់ថាជា អំពើសាសនាថាមិនចេះមិនអត់ឱនឬគ្មានការគោរព រួមបញ្ចូលទាំងខាងក្រៅព្រំដែនជាតិ។

**8.7** Acts of incitement or hate propaganda targeting particular groups or individuals.

សកម្មភាពឃោសនាញុះញង់ឬស្អប់ខ្ពើមដែលផ្តោតសំខាន់ទៅក្រុមឬបុគ្គលជាគោលដៅជាក់លាក់ណាមួយ។

**8.8** Census, elections, pivotal activities related to those processes, or measures that destabilize them.

ជំរឿន ការបោះឆ្នោត សកម្មភាពសំខាន់ៗដែលទាក់ទងទៅនឹងដំណើរការ ឬវិធានការនានាដែលបង្ករឱ្យមានអស្ថិរភាព។

**8.9** Sudden changes that affect the economy or the workforce, including as a result of financial crises, natural disasters or epidemics.

ផ្លាស់ប្តូរមួយរំពេចដែលប៉ះពាល់ដល់សេដ្ឋកិច្ចឬកម្លាំងពលករ រួមទាំងលទ្ធផលនៃវិបត្តិហិរញ្ញវត្ថុ គ្រោះមហន្តរាយធម្មជាតិ ឬជំងឺរាតត្បាត។

**8.10** Discovery of natural resources or launching of exploitation projects that have a serious impact on the livelihoods and sustainability of groups or civilian populations.

ការរកឃើញនៃធនធានធម្មជាតិឬការចាប់ផ្តើមការធ្វើអាជីវកម្មដែលមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពនិងនិរន្តរភាពនៃក្រុមឬប្រជាជនស៊ីវិល។

**8.11** Commemoration events of past crimes or of traumatic or historical episodes that can exacerbate tensions between groups, including the glorification of perpetrators of atrocities.

ពិធីរំឭកខួបនៃឧក្រិដ្ឋកម្មឬព្រឹត្តិការណ៍ជាប្រវត្តិសាស្រ្តឬគួឱ្យតក់ស្លុត ដែលអាចបង្កើនភាពតានតឹងរវាងក្រុមផ្សេងៗ រួមទាំងការលើកតម្កើងជនល្មើសនៃអំពើឃោរឃៅ។

**8.12** Acts related to accountability processes, particularly when perceived as unfair.

អំពើដែលទាក់ទងទៅនឹងដំណើរការនៃគណនីភាព ពិសេសនៅពេលដែលត្រូវបានយល់ថាអយុត្តិធម៌។

## Comment:

The dynamics of atrocity crimes are not the same in all cases. In fact, they can vary considerably. The commission of atrocity crimes may progress at a faster pace if the perpetrators have a clear plan and the immediate capacity to implement it. In other situations, the commission of atrocity crimes might unfold at a late stage of a situation of serious crisis or tension that may have been lasting for a long period of time.

## មតិយោបល់

ថាមវន្តនៃឧក្រិដ្ឋកម្មឃោរឃៅគឺមិនដូចគ្នាគ្រប់ករណីទាំងអស់នោះទេ។ តាមពិតទៅ អាចខុសផ្លែកពីគ្នាច្រើនណាស់។ ការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅអាចមានដំណើរការលឿនប្រសិនបើជនល្មើសមានផែនការច្បាស់លាស់និងសមត្ថភាពក្នុងការអនុវត្តភ្លាមៗ។ ក្នុងស្ថានភាពខ្លះទៀតការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅអាចនឹងកើតឡើងនៅដំណាក់កាលចុងក្រោយក្នុងស្ថានភាពនៃវិបត្តិឬភាពតានតឹងធ្ងន់ធ្ងរដែលអាចបានកើតឡើងក្នុងរយៈពេលយូរមកហើយ។

It can also happen that unpredictable events or circumstances aggravate conditions or spark a sudden deterioration in a situation, prompting the perpetration of atrocity crimes. An adequate early warning assessment should be mindful of all such events or circumstances and consider their potential impact, even if they appear to be unrelated to more direct or structuralrisk factors.

វាក៏អាចកើតមានផងដែរ ដែលមានព្រឹត្តិការណ៍ឬកាលៈទេសៈ មិនអាចទាយទុកជាមុនបាន ស្រាប់អាចតែធ្វើឱ្យស្ថានការណ៍រីករាលដាលកាន់តែធ្ងន់ធ្ងរឡើងភ្លាមៗ ដែលអាចឈានដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ។ ការវាយតម្លៃលើការព្រមានជាមុនគួរតែគិតគូរពីព្រឹត្តិការណ៍ឬកាលៈទេសៈទាំងអស់នេះ និងពិចារណាផលប៉ះពាល់ដែលដែលអាចកើតមានឡើងបើទោះបីជាវាហាក់ដូចជាមិនទាក់ទងនឹងកត្តាផ្ទាល់ឬរចនាសម្ព័ន្ធនៃហានិភ័យក៏ដោយ។

RISK FACTOR 9
កត្តាហានិភ័យ ៩

# Intergroup tensions or patterns of discrimination against protected groups[5]

ភាពតានតឹងអន្តរក្រុម ឬ លំនាំគំរូនៃការរើសអើងមកលើក្រុមដែលត្រូវបានការពារ

## Past or present conduct that reveals serious prejudice against protected groups and that creates stress in the relationship among groups or with the State, generating an environment conducive to atrocity crimes.

អំពើពីអតីតកាលឬបច្ចុប្បន្នដែលបង្ហាញពីការរើសអើងធ្ងន់ធ្ងរមកលើក្រុមដែលត្រូវបានការពារ ហើយបង្កើតភាពតានតឹងរវាងទំនាក់ទំនងរបស់ក្រុមផ្សេងៗក្នុងរដ្ឋមួយ ដែលបង្កើតបរិយាកាសអំណោយផលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ។

## Indicators សូចនាករ

**9.1** Past or present serious discriminatory, segregational, restrictive or exclusionary practices, policies or legislation against protected groups.

អំពើ គោលនយោបាយឬច្បាប់ពីអតីតកាលឬបច្ចុប្បន្នដែលរើសអើងធ្ងន់ធ្ងរ បែងចែក រឹតបន្តឹងឬ មិនរាប់បញ្ចូលមកលើក្រុមដែលត្រូវបានការពារ។

**9.2** Denial of the existence of protected groups or of recognition of elements of their identity.

ការបដិសេធវត្តមាននៃក្រុមដែលត្រូវបានការពារឬការមិនទទួលស្គាល់ធាតុនៃអត្តសញ្ញាណរបស់ពួកគេ។

**9.3** History of atrocity crimes committed with impunity against protected groups.

ប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មឃោរឃៅដែលបានប្រព្រឹត្តលើក្រុមដែលត្រូវបានការពារដោយមាននិទណ្ឌភាព ។

**9.4** Past or present serious tensions or conflicts between protected groups or with the State, with regards to access to rights and resources, socioeconomic disparities, participation in decision making processes, security, expressions of group identity or to perceptions about the targeted group.

ភាពតានតឹងឬការប៉ះទង្គិចគ្នាធ្ងន់ធ្ងរពីអតីតកាលឬបច្ចុប្បន្នរវាងក្រុមដែលត្រូវបានការពារជាមួយរដ្ឋ ដែលទាក់ទងទៅនឹងការទទួលបានសិទ្ធិនិងធនធាន គម្លាតសេដ្ឋកិច្ចសង្គម ការចូលរួមនៅក្នុងដំណើរការនៃការសម្រេចចិត្ត សន្តិសុខ ការបង្ហាញនូវអត្តសញ្ញាណជាក្រុម ឬការយល់ឃើញដូចនោះទៅលើក្រុមបានក្លាយជាគោលដៅ។

**9.5** Past or present serious tensions or conflicts involving other types of groups (political, social, cultural, geographical, etc.) that could develop along national, ethnical, racial or religious lines.

ភាពតានតឹងធ្ងន់ធ្ងរក្នុងអតីតកាលឬបច្ចុប្បន្ន ឬជម្លោះដែលពាក់ព័ន្ធនឹងរឿងផ្សេងៗ (នយោបាយ, សង្គម, វប្បធម៌, ភូមិសាស្ត្រ, ល) ដែលអាចវិវត្តតាមរយៈមាគ៌ាជាតិ ជាតិសាសន៍ ពូជសាសន៍ ឬសាសនា។

**9.6** Lack of national mechanisms or initiatives to deal with identity-based tensions or conflict.

កង្វះនៃយន្តការឬការផ្តួចផ្តើម ថ្នាក់ជាតិ ដើម្បីដោះស្រាយភាពតានតឹងឬជម្លោះដោយសារអត្តសញ្ញាណ ។

1 For a definition of “protected group” within the context of this Framework, please consult Section I — *Who are the victims of atrocity crimes?*.

សម្រាប់និយមន័យនៃ "ក្រុមដែលត្រូវបានការពារ" នៅក្នុងបរិបទនៃក្របខ័ណ្ឌនេះសូមមើលផ្នែកទី I - តើនរណាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មឃោរឃៅ?

### Comment:

Genocide is an extreme form of identity-based crime. Whether real or socially constructed, identity can be subject to manipulation by elites, including as a deliberate tactic for personal or political gain, and may be used to deepen soci-

etal divisions. Identity-based conflict, which may give rise to the crime as defined by the Convention on the Prevention and the Punishment of the Crime of Genocide, can be rooted in differences between national, ethnical, racial or religious groups, whether real or perceived. It can also be rooted in other differences, such as those of a political or even geographical nature, that eventually develop along national, ethnical, racial or religious lines.

មតិយោបល់

អំពើប្រល័យពូជសាសន៍គឺឧក្រិដ្ឋកម្មផ្អែកលើអត្តសញ្ញាណក្នុងរូបភាពអាក្រក់ធ្ងន់ធ្ងរខ្លាំង។ ទោះជាពិតជាក់ស្តែងឬដោយការស្ថាបនាឡើងក្នុងសង្គម អត្តសញ្ញាណអាចនឹងត្រូវប្រើប្រាស់ដើម្បីកេញចំណេញដោយចេតនាពីមេដឹកនាំ ក្នុងការធ្វើជាយុទ្ធសាស្ត្រសម្រាប់ផលប្រយោជន៍នយោបាយផ្ទាល់ខ្លួន ហើយអាចត្រូវបានប្រើដើម្បីបំបែកសង្គមកាន់តែជ្រៅឡើង។ ជម្លោះមកពីអត្តសញ្ញាណដែលអាចបង្កឧក្រិដ្ឋកម្មដែលបានកំណត់នៅក្នុងអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានឫសមកពីភាពខុសគ្នារវាងជាតិ ជាតិសាសន៍ ពូជសាសន៍ ឬសាសនាមិនថាពិតឬការគិតនោះឡើយ។ វាក៏អាចមានឫសគល់មកពីភាពខុសគ្នាផ្សេងទៀត ដូចជានយោបាយឬសូម្បីតែភូមិសាស្ត្រដែលនៅទីបំផុតអាចអភិវឌ្ឍតាមខ្សែបន្ទាត់ជាតិ ជាតិសាសន៍ ពូជសាសន៍ ឬសាសនា។

However, the risk factor is not the existence of diversity within the population of a country, nor is it those differences per se that cause conflict between groups. Instead, it is discrimination based on such differences, and persistent patterns of it, that establish divisions within society which serve as both a material cause and a perceived justification of group violence. Without group-level discrimination, even deeply seated grievances are unlikely to transform into the pat- terns of abuse that give rise to g e n o c i d e .

ទោះជាយ៉ាងណាក៏ដោយ កាលដែលមានកត្តាហានិភ័យមិនមែន មានន័យថាភាពខុសគ្នាក្នុងចំណោមប្រជាពលរដ្ឋនៃប្រទេសមួយទេ ហើយក៏មិនមែនភាពខុសគ្នាដែរដែលបណ្តាលឱ្យមានជម្លោះរវាងក្រុមផ្សេងៗគ្នា។ ផ្ទុយទៅវិញ ការរើសអើងដោយផ្អែកលើភាពខុសគ្នានិងលំនាំនៃការរើសអើងដែលពិបាកកែនេះឯងដែលបង្កើតឱ្យមានការបែងចែកក្នុងសង្គមដែលជាមូលហេតុបង្កពិតនិងជាហេតុផលយកមកប្រើពីក្រោយអំពើហិង្សារវាងក្រុម។ បើមិនមានការរើសអើងក្នុងកម្រិតក្រុមទេ ទោះជាមានកំហឹងដែលចាក់ឫសជ្រៅក៏មិនងាយក្លាយទៅជាលំនាំសកម្មភាពនៃការរំលោភបំពានដែលបង្កឱ្យមានអំពើប្រល័យពូជសាសន៍ដែរ។

# Signs of an intent to destroy in whole or in part a protected group

សញ្ញានៃបំណងក្នុងការបំផ្លាញទាំងមូលឬមួយផ្នែកនៃក្រុមដែលត្រូវបានការពារ

**Facts or circumstances that suggest an intent, by action or omission, to destroy all or part of a protected group based on its national, ethnical, racial or religious identity, or the perception of this identity.**

ហេតុការណ៍ពិតឬកាលៈទេសៈដែលបានបង្ហាញឱ្យឃើញគោលបំណងដោយសកម្មភាព ឬការមិនអើពើ ដើម្បីបំផ្លាញទាំងស្រុងឬផ្នែកមួយនៃក្រុមដែលត្រូវបានការពារ ដោយផ្អែកលើសញ្ជាតិ ជនជាតិអត្តសញ្ញាណពូជសាសន៍ឬសាសនា ឬការយល់ឃើញនៃអត្តសញ្ញាណទាំងនេះ។

## Indicators សូចនករ

**10.1** Official documents, political manifests, media records, or any other documentation through which a direct intent, or incitement, to target a protected group is revealed, or can be inferred in a way that the implicit message could reasonably lead to acts of destruction against that group.

ឯកសារផ្លូវការ ភាពជាក់ស្តែងខាងនយោបាយ កំណត់ត្រាប្រព័ន្ធផ្សព្វផ្សាយ ឬឯកសារផ្សេងទៀតដែលត្រូវបានប្រើដោយចេតនាដោយចេតនាផ្ទាល់ ក្នុងការញុះញង់

ដើម្បីសំដៅប្រឆាំងក្រុមដែលបានការការពារអាចនឹងត្រូវបានបង្ហាញឬអាចត្រូវបានសន្និដ្ឋានបើសារខាងក្នុងអាចចាត់ទុកថាអាចនាំទៅដល់អំពើកម្ទេចក្រុមដែលត្រូវបានការពារនោះ។

**10.2** Targeted physical elimination, rapid or gradual, of members of a protected group, including only selected parts of it, which could bring about the destruction of the group.

ការសំដៅប្រឆាំងលុបបំបាត់រូបរាងកាយនៃសមាជិកក្រុមដែលបានការពារ ដ៏ឆាប់រហ័ស ឬបណ្តើរៗ រួមបញ្ចូលទាំងការសំដៅប្រឆាំងការលុបបំបាត់ផ្នែកនានាដែលអាចនាំមកនូវការបំផ្លាញនៃក្រុមទាំងមូល។

**10.3** Widespread or systematic discriminatory or targeted practices or violence against the lives, freedom or physical and moral integrity of a protected group, even if not yet reaching the level of elimination.

ការរីករាលដាលឬការរើសអើងឬការសំដៅប្រឆាំងជាលក្ខណៈប្រព័ន្ធឬអំពើហិង្សាទៅលើជីវិតសេរីភាពឬបូរណភាពរាងកាយនិងផ្លូវចិត្តរបស់ក្រុមដែលត្រូវបានការពារ បើទោះបីជាមិនទាន់ឈានដល់កម្រិតនៃការលុបបំបាត់ទាំងស្រុងក៏ដោយ។

**10.4** Development of policies or measures that seriously affect the reproductive rights of women, or that contemplate the separation or forcible transfer of children belonging to protected groups.

ការអភិវឌ្ឍនៃគោលនយោបាយឬវិធានការដែលបានប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិបន្តពូជរបស់ស្ត្រីឬជួយដល់ការបំបែកឬការបង្ខំឱ្យផ្លាស់ប្តូរកម្មសិទ្ធិនៃកុមាររបស់ក្រុមដែលត្រូវបានការពារ។

**10.5** Resort to methods or practices of violence that are particularly harmful against or that dehumanize a protected group, that reveal an intention to cause humiliation, fear or terror to fragment the group, or that reveal an intention to change its identity.

ការប្រើវិធីសាស្រ្តឬការអនុវត្តន៍នៃអំពើហិង្សាដែលប្រឆាំងនឹង ឬការធ្វើឱ្យបាត់លក្ខណៈជាមនុស្សនៃ ក្រុមដែលត្រូវបានការពារ ដែលបានបង្ហាញពីបំណងបង្កភាពអាម៉ាស់ ការភ័យខ្លាចឬភេរវកម្មដើម្បីបំបែកក្រុម ឬដែលបង្ហាញពីចេតនាដើម្បីផ្លាស់ប្តូរអត្តសញ្ញាណរបស់ក្រុមនោះ។

**10.6** Resort to means of violence that are particularly harmful or prohibited under international law, including prohibited weapons, against a protected group.

ប្រើប្រាស់មធ្យោបាយហិង្សាដែលអាចធ្វើឱ្យគ្រោះថ្នាក់ ឬមធ្យោបាយរួមទាំងអាវុធប្រឆាំងនឹងក្រុមដែលត្រូវបានការពារ ដែលត្រូវបានហាមឃាត់ក្រោមច្បាប់អន្តរជាតិ ។

**10.7** Expressions of public euphoria at having control over a protected group and its existence.

ការបង្ហាញនៃការពេញចិត្តជាសាធារណៈលើការគ្រប់គ្រងលើក្រុមដែលត្រូវបានការពារ និង អត្ថិភាពរបស់ក្រុមនេះ។

## 10.8 Attacks against or destruction of homes, farms, businesses or other livelihoods of a protected group and/or of their cultural or religious symbols and property.

ការវាយប្រហារប្រឆាំងនឹងការបំផ្លិចបំផ្លាញលំនៅដ្ឋាន កសិដ្ឋាន អាជីវកម្មឬជីវភាពរបស់ក្រុមដែលត្រូវបានការពារនិង / ឬនិមិត្តសញ្ញាវប្បធម៌ឬសាសនា និង ទ្រព្យសម្បត្តិរបស់ពួកគេ។

### Comment:

The intent to destroy in whole or in part a national, ethnical, racial or religious group is both one of the most fundamental and one of the most difficult elements of the crime of genocide to prove. It is also a challenging element to predict from an early warning perspective. Frequently, the intent only comes to light after a crime has taken place, typically during accountability processes, or sometimes when it might be too late to take preventive action due to the advanced level of the violence.

### មតិយោបល់

បំណងក្នុងការបំផ្លាញទាំងស្រុងឬក៏ផ្នែកនៃជាតិ ជាតិសាសន៍ ពូជសាសន៍ ឬសាសនាគឺជាធាតុមូលដ្ឋានគ្រឹះ និងក៏ជាធាតុដែលលំបាកបំផុតបង្ហាញឱ្យឃើញ នៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ វាក៏ជាធាតុដែលពិបាកក្នុងការទស្សន៍ទាយនៅពេលពិចារណាពីការព្រមានទុកជាមុន។ ជារឿយៗ បំណងអាក្រក់លេចឡើងក្រោយពេលដែលឧក្រិដ្ឋកម្មបានកើតឡើងហើយ ជាទូទៅក្នុងអំឡុងពេលដំណើរការទទួលខុសត្រូវឬជួនកាលពេលដែលវាយឺតពេលពេកទៅហើយក្នុងការចាត់វិធានបង្ការដោយសារកម្រិតនៃអំពើហិង្សាមានកម្រិតខ្ពស់។

However, there are some early indicators that can serve as a warning sign. Those indicators are unlikely to be explicit, but they can also be inferred from conduct that would reasonably lead to the belief, even if not the certainty, that the intent of or a plan for annihilation could exist. Indicators can include overt methods of destruction, or otherwise covert or indirect methods that in practice lead to the same ultimate result.In addition, case law has associated intent with the existence of a State or organizational plan or policy, even if thedefinition of genocide in international law does not include that element. As genocide is not a spontaneous act, it isunlikely that it will be committed in the absence of such a plan or policy.

ទោះជាយ៉ាងណាក៏ដោយមានសូចនាករបឋមដែលអាចធ្វើជាសញ្ញាព្រមាន។ សូចនាករទាំងនោះមិនតែងតែលេចចេញច្បាស់ទេ ប៉ុន្តែអាចចេញពីការសន្និដ្ឋាន ផ្អែកលើអំពើដែលអាចនាំទៅដល់ការ ដែលបង្ហាញបំណងឬផែនការនៃការបំផ្លិចបំផ្លាញ។ សូចនាករអាចរាប់បញ្ចូលវិធីសាស្រ្តនៃការបំផ្លិចបំផ្លាញដែលលេចចេញច្បាស់ឬដោយលាក់កំបាំងឬដោយប្រយោលដែលបើអនុវត្តជាក់ស្តែងនឹងអាចនាំទៅដល់លទ្ធផលចុងក្រោយដូចគ្នា។ លើសពីនេះទៀតបណ្តឹងច្បាប់បានផ្សារភ្ជាប់បំណងជាមួយការរៀបចំផែនការឬគោលនយោបាយរបស់រដ្ឋឬក្រុមអង្គការ បើទោះបីជានិយមន័យនៃអំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិមិនបានរាប់បញ្ចូលធាតុនោះក៏ដោយ។ ដោយសារអំពើប្រល័យពូជសាសន៍មិនមែនជាទង្វើកើតឡើងភ្លាមៗនោះទេ ដូចនេះហើយវាងាយនឹងសម្រេចដោយគ្មានវត្តមាននៃផែនការឬគោលនយោបាយរៀបចំទុកមុននោះ។

RISK FACTOR 11
កត្តាហានិភ័យ ១១

## Signs of a widespread or systematic attack against any civilian population[6]

**សញ្ញានៃការវាយប្រហាររីករាលដាល និងជាប្រព័ន្ធ មកលើក្រុមប្រជាជនស៊ីវិល**

**Signs of violent conduct including, but not limited to, attacks involving the use of force, against any civilian population and that suggest massive, large-scale and frequent violence (widespread), or violence with patterns of periodicity, similitude and organization (systematic).**

សញ្ញានៃការប្រព្រឹត្តអំពើហិង្សា រួមមានប៉ុន្តែមិនត្រឹមតែ ការវាយប្រហារ ដោយការប្រើប្រាស់កម្លាំង ដើម្បីប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ដែលបង្ហាញឱ្យឃើញ អំពើហិង្សាទ្រង់ទ្រាយធំ និង ជាញឹកញាប់ (រាលដាល) ឬអំពើហិង្សាដែលមានលំនាំមានពេលវេលា មានសភាពនិងការរៀបចំ (ជាប្រព័ន្ធ) ។

### Indicators សូចនាករ

**11.1** Signs of patterns of violence against civilian populations, or against members of an identifiable group, their property, livelihoods and cultural or religious symbols.

សញ្ញានៃអំពើហិង្សាប្រឆាំងនឹងប្រជាជនស៊ីវិលឬប្រឆាំងនឹងសមាជិកនៃក្រុមដែលអាចកំណត់អត្តសញ្ញាណបាន ទ្រព្យសម្បត្តិ ការចិញ្ចឹមជីវិត និងសញ្ញាវប្បធម៌ឬសាសនារបស់ពួកគេ។

**11.2** Increase in the number of civilian populations or the geographical area targeted, or in the number, types, scale or gravity of violent acts committed against civilian populations.

ការបង្កើនចំនួន ប្រភេទ កម្រិត ឬភាពធ្ងន់ធ្ងរនៃអំពើហិង្សាប្រព្រឹត្តមកលើប្រជាជនស៊ីវិល ឬតំបន់ភូមិសាស្រ្តដែលជាគោលដៅ។

**11.3** Increase in the level of organization or coordination of violent acts and weapons used against a c i v i l i a n population.

ការបង្កើនកម្រិតនៃការចាត់ចែងនិងរៀបចំអំពើហិង្សានិងអាវុធដែលត្រូវបានប្រើប្រឆាំងនឹងប្រជាជនស៊ីវិល។

**11.4** Use of the media or other means to provoke or incite to violent acts.

ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឬមធ្យោបាយផ្សេងទៀតដើម្បីបង្ក ឬញុះញង់ឱ្យមានអំពើហិង្សា។

**11.5** Signs of a plan or policy to conduct attacks against civilian populations.

សញ្ញានៃផែនការ ឬគោលនយោបាយដើម្បីធ្វើការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល។

**11.6** Establishment of new political or military structures that could be used to commit violent acts.

ការបង្កើតរចនាសម្ព័ន្ធនយោបាយឬយោធាថ្មីដែលអាចត្រូវបានប្រើដើម្បីប្រព្រឹត្តអំពើហិង្សា។

**11.7** Access to or increasing use of significant public or private resources for military or belligerent action, including the acquisition of large quantities of weaponry or other instruments that can cause death or serious harm.

លទ្ធភាពក្នុងការប្រើទៅឬការបង្កើនការប្រើប្រាស់ធនធានសាធារណៈឬឯកជនសម្រាប់សកម្មភាពយោធាឬហិង្សា រួមបញ្ចូលទាំងការទទួលបានអាវុធឬឧបករណ៍ផ្សេងទៀតក្នុងបរិមាណច្រើនដែលអាចប្រើក្នុងការបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរឬបាត់បង់ជីវិត។

**11.8** Signs of development or increased use of means or methods of violence that are incapable of distinguishing between civilian and military targets or that are capable of mass destruction, persecution or weakening of communities.

សញ្ញានៃការអភិវឌ្ឍឬការកើនឡើងនៃការប្រើវិធីសាស្រ្តឬមធ្យោបាយហិង្សាដែលមិនមានលទ្ធភាពក្នុងការបែងចែករវាងជនស៊ីវិលនិងកងទ័ព ឬមានលទ្ធភាពក្នុងការបំផ្លាញឬធ្វើបាបឬការធ្វើឱ្យធ្លាក់ចុះនៃសហគមន៍ជាទ្រង់ទ្រាយធំ។

2 For a definition of "civilian population" within the context of this Framework, please consult Section I — *Who are the victims of atrocity crimes?*.

និយមន័យនៃ "ជនស៊ីវិល" នៅក្នុងបរិបទនៃក្របខ័ណ្ឌនេះសូមមើលផ្នែកទី I - តើនរណាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មឃោរឃៅនេះ ?

## Comment:

Crimes against humanity involve either large-scale violence (quantitative element) or a methodical type of violence (qualitative element). This excludes random, accidental or isolated acts of violence that, in addition, could be difficult to predict. Instead, the type of violence that characterizes crimes against humanity will most probably require alevel of preparation that can be revealed through different indicators.

### មតិយោបល់

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធនឹងអំពើហិង្សាទ្រង់ទ្រាយធំទាំង (ធាតុជាបរិមាណ) ឬវិធីសាស្រ្តនៃអំពើហិង្សា (ធាតុជាគុណភាព) ។ នេះមិនរាប់បញ្ចូល អំពើហិង្សាដែលចៃដន្យឬដាច់ដោយឡែកដែលពិបាកក្នុងការព្យាករ។ ផ្ទុយទៅវិញប្រភេទនៃអំពើហិង្សាដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវការការរៀបចំកម្រិតខ្ពស់មួយដែលអាចបង្ហាញឱ្យយើងឃើញតាមរយៈសូចនាករផ្សេងៗ។

Such indicators can, for example, relate to the means and methods used to engage in violence, or to patterns of violent conduct during the early stages of a conflict that can help predict an aggravation of those patterns and, consequently, the potential for crimes againsthumanity. Other indicators can point to patterns of conduct — even outside of a conflict situation — that manifestearlier, such as the building up of capacity for large-scale or systematic violence, or the use of alternative means to target civilian populations or particular groups within them. Identifying early stages of pattern manifestation is crucialto be able to devise strategies to stop them.

សូចនាករបែបនេះ ជាឧទាហរណ៍ ទាក់ទងនឹងមធ្យោបាយនិងវិធីសាស្រ្តដែលត្រូវបានប្រើដើម្បីចូលរួមក្នុងអំពើហិង្សាឬគំរូសកម្មភាពនៃការប្រព្រឹត្តអំពើហិង្សាក្នុងដំណាក់កាលបឋមនៃជម្លោះដែលអាចជួយព្យាករនូវការកើនឡើងនៃគំរូសកម្មភាពទាំងនោះហើយជាលទ្ធផលផ្តល់នូវសក្តានុពលភាពនៃឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ។ សូចនាករផ្សេងៗទៀតអាចចង្អុលបង្ហាញពីគំរូនៃការប្រព្រឹត្ត - ទោះបានលេចឡើងពីខាងក្រៅជម្លោះ ដូចជាការបង្កើនសមត្ថភាពក្នុងការប្រព្រឹត្តអំពើហិង្សាទ្រង់ទ្រាយធំឬជាប្រព័ន្ធ ឬការប្រើប្រាស់មធ្យោបាយផ្សេងៗទៀតដើម្បីសំដៅប្រឆាំងប្រជាជនស៊ីវិលឬក្រុមណាមួយ។ ការកត់សម្គាល់ដំណាក់កាលបឋមនៃសកម្មភាពគំរូដែលលេចឡើងគឺមានសារៈសំខាន់ក្នុងការបង្កើតយុទ្ធសាស្រ្តដើម្បីបញ្ឈប់អំពើទាំងនោះ។

# Signs of a plan or policy to attack any civilian population

សញ្ញានៃផែនការ ឬ គោលនយោបាយវាយប្រហារក្រុមប្រជាជនស៊ីវិល

**Facts or evidence suggestive of a State or organizational policy, even if not explicitly stipulated or formally adopted, to commit serious acts of violence directed against any civilian population.**

ហេតុការណ៍ជាក់ស្តែងឬភ័ស្តុតាងបង្ហាញពីគោលនយោបាយរបស់រដ្ឋឬរបស់អង្គការមួយ ដើម្បីប្រព្រឹត្តអំពើហិង្សាធ្ងន់ធ្ងរមកលើប្រជាជនស៊ីវិលណាមួយ បើទោះបីជាមិនបានចែងឱ្យបានអនុម័តឬចែងជាផ្លូវការ។

## Indicators សូចនាករ

**12.1** Official documents, political manifestos, media records, or any other documentation through which the existence of a State or organizational plan or policy to target civilian populations or protected groups is directly revealed, or could be inferred.

ឯកសារផ្លូវការបង្ហាញអំពីសេចក្តីថ្លែងនយោបាយ កំណត់ត្រាប្រព័ន្ធផ្សព្វផ្សាយ ឬឯកសារផ្សេងទៀតដែលអាចបង្ហាញដោយផ្ទាល់ឬតាមការសន្និដ្ឋានតាមរយៈអត្ថិភាពនៃផែនការឬគោលការណ៍របស់រដ្ឋឬអង្គការ ក្នុងគោលបំណងសំដៅប្រឆាំង លើប្រជាជនស៊ីវិល ឬក្រុមដែលត្រូវបានការពារ ។

**12.2** Adoption of discriminatory security procedures against different groups of the civilian population.

ការអនុម័តនីតិវិធីនៃការរើសអើងផ្នែកសន្តិសុខ ប្រឆាំងនឹងក្រុមប្រជាជនស៊ីវិលផ្សេងៗ។

**12.3** Adoption of measures that result in the alteration of the ethnic, religious, racial or political composition of the overall population, including in defined geographical areas.

ការអនុម័តវិធានការនានាដែលអាចឈានដល់ការកែប្រែជាតិសាសន៍ សាសនាពូជសាសន៍ឬសមាសភាពនយោបាយ នៃចំនួនប្រជាជនសរុប រួមទាំងនៅក្នុងតំបន់ភូមិសាស្រ្តដែលបានកំណត់គោលដៅ។

**12.4** Establishment of parallel institutions or autonomous political or military structures, or organization of a network of potential perpetrators belonging to a specific ethnic, religious, national, racial or political group.

ការបង្កើតស្ថាប័នស្របឬរចនាសម្ព័ន្ធនយោបាយឬយោធាស្វយ័តឬការរៀបចំនៃបណ្តាញអ្នកដែលអាចជាជនល្មើសដែលជាផ្នែកមួយនៃក្រុមជនជាតិ សាសនា ជាតិ ពូជសាសន៍ ឬនយោបាយជាក់លាក់ណាមួយ។

**12.5** Preparation and use of significant public or private resources, whether military or other kinds.

ការរៀបចំនិងការប្រើប្រាស់ច្រើននៃធនធានសាធារណៈឬឯកជនទោះជាយោធាឬប្រភេទផ្សេងទៀត។

**12.6** Access to and use of weaponry or other instruments not easily obtained inside the country.

លទ្ធភាពក្នុងការ និង ការប្រើប្រាស់អាវុធឬឧបករណ៍ផ្សេងៗដែលពិបាករកបាននៅក្នុងប្រទេស។

**12.7** Preparation or mobilization of armed forces en masse against civilian populations.

ការរៀបចំឬការចល័តកងកម្លាំងប្រដាប់អាវុធទ្រង់ទ្រាយធំប្រឆាំងនឹងប្រជាជនស៊ីវិល។

**12.8** Facilitating or inciting violence against the civilian population or protected groups, or tolerance or deliberate failure to take action, with the aim of encouraging violent acts.

ការជួយសម្រួលដល់ឬការញុះញង់ឱ្យមានអំពើហិង្សាប្រឆាំងនឹងប្រជាជនស៊ីវិលឬក្រុមដែលត្រូវបានការពារឬការអត់ឱនឬការបរាជ័យក្នុងការចាត់វិធានការ ដោយមានគោលបំណងចង់ឱ្យមានអំពើហិង្សានេះ។

**12.9** Widespread or systematic violence against civilian populations or protected groups, including only parts of them, as well as on their livelihoods, property or cultural manifestations.

ការរីករាលដាលឬការរៀបចំអំពើហិង្សាជាប្រព័ន្ធសាប្រឆាំងនឹងប្រជាជនស៊ីវិលឬក្រុមដែលត្រូវបានការពារ រួមបញ្ចូលទាំង ទោះគ្រាន់តែជាការវាយប្រហារមួយផ្នែករបស់ពួកគេ ក៏ដូចជាជីវភាព អចលនទ្រព្យឬវប្បធម៌របស់ពួកគេ។

**12.10** Involvement of State institutions or high-level political or military authorities in violent acts.

ការចូលរួមរបស់ស្ថាប័នរដ្ឋឬអាជ្ញាធរនយោបាយឬយោធាថ្នាក់ខ្ពស់នៅក្នុងអំពើហិង្សា។

## Comment:

In addition to the requirement that attacks against the civilian population be widespread or systematic, crimes against humanity are committed in furtherance of a State or organizational policy to commit an attack. Even though this is not included in the definition of the crime under Article 7(1) of the Rome Statute, Article 7(2)(a) of the same document introduces this element.

### មតិយោបល់

បន្ថែមពីលើតម្រូវការដែលថាការវាយប្រហារមកលើជនស៊ីវិលស្ថិតក្នុងរូបភាពរីករាលដាលឬជាប្រព័ន្ធ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងជួយឱ្យរដ្ឋឬក្រុមអង្គការសម្រេចបានគោលនយោបាយដើម្បីធ្វើការវាយប្រហារ។ ទោះបីការនេះមិនត្រូវបានរាប់បញ្ចូលក្នុងនិយមន័យនៃបទឧក្រិដ្ឋតាមមាត្រា 7 (1) នៃលក្ខន្តិកៈទីក្រុងរ៉ូមក៏ដោយនោះ មាត្រា 7 (2) (ក) នៃឯកសារដូចគ្នានេះបានដាក់បញ្ចូលធាតុនេះ។

The plan or policy does not need to be explicitly stipulated or formally adopted and can, therefore, be inferred from the totality of the circumstances. Early signs of those circumstances, such as the indicators mentioned above, reveal planning, promotion or encouragement of violent acts, even if not explicitly presented as such. Conduct that manifests as widespread or systematic, as described in the previous risk factor, can be an indication of a plan or policy. On the other hand, a plan or policy can point to the systematic nature of an attack. The distinction between both might not always be clear.

ផែនការឬគោលនយោបាយមិនចាំបាច់ត្រូវបានចែងច្បាស់លាស់ឬបានអនុម័តជាផ្លូវការ តែក៏អាចក្នុងរូបភាពជាការការសន្និដ្ឋានពីកាលៈទេសៈសរុប។ សញ្ញាដំបូងនៃកាលៈទេសៈទាំងនោះមានដូចជាសូចនាករដែលបានរៀបរាប់ខាងលើ ដែលបានបង្ហាញពីការរៀបចំផែនការ ការលើកកម្ពស់ ឬការលើកទឹកចិត្តឱ្យធ្វើអំពើហិង្សាបើទោះបីជាមិនបានបង្ហាញជាក់ច្បាស់ក៏ដោយ។ ការប្រព្រឹត្តដែលលេចឡើងក្នុងរូបភាពរីករាលដាលឬជាប្រព័ន្ធដូចដែលបានពិពណ៌នានៅក្នុងកត្តាហានិភ័យមុនអាចជាការចង្អុលបង្ហាញពីផែនការឬគោលនយោបាយ។ ម្យ៉ាងវិញទៀតផែនការឬគោលនយោបាយអាចចង្អុលបង្ហាញពីលក្ខណៈជាប្រព័ន្ធនៃការវាយប្រហារ។ភាពខុសគ្នារវាងទាំងពីរនេះមិនតែងតែច្បាស់នោះទេ។

RISK FACTOR 13
កត្តាហានិភ័យ ១៣

# Serious threats to those protected under international humanitarian law[7]

**ការគំរាមកំហែងធ្ងន់ធ្ងរលើជនដែលត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិ**

## Conflict-related conduct that seriously threatens the life and physical integrity of those protected under international humanitarian law.

ការប្រព្រឹត្តដែលទាក់ទងនឹងជម្លោះដែលគំរាមកំហែងដល់ជីវិតនិងបូរណភាពរូបរាងកាយយ៉ាងធ្ងន់ធ្ងររបស់ជនដែលត្រូវបានការពារក្រោមច្បាប់មនុស្សធម៌អន្តរជាតិ។

## Indicators សូចនាករ

**13.1** Fragmentation of parties to the conflict or disintegration or absence of chains of command within them.

ភាគីជម្លោះត្រូវបានបែកជាក្រុមឬបែកបាក់ឬបាត់បង់ខ្សែសង្វាក់បញ្ជាក្នុងក្រុមពួកគេ។

**13.2** Mistrust between opposing parties based on past or present breaches of commitments or agreements.

ភាពមិនទុកចិត្តគ្នារវាងក្រុមដែលប្រឆាំងគ្នាដែលមានមូលដ្ឋានលើការរំលោភបំពានការប្តេជ្ញាចិត្តឬកិច្ចព្រមព្រៀងក្នុងអតីតកាលឬបច្ចុប្បន្ន។

**13.3** Increased radicalization or extremism of opposing parties within a conflict.

ការកើនឡើងនៃភាពជ្រុលនិយមឬរ៉ាឌីកាល់នៃភាគីនៅក្នុងជម្លោះ។

**13.4** Promotion of ethnicity or religion as a determinant of national allegiance or allegiance to a party of the conflict.

ការលើកតម្កើងជាតិសាសន៍ឬសាសនា ដែលជាការកំណត់ស្មោះត្រង់ឬ ស្មោះត្រង់ទៅកាន់ក្រុមជម្លោះនេះ។

**13.5** Conduct that dehumanizes the enemy or particular groups within the population, or that exhibits disrespect for their religious, ethnic or, in general, cultural traditions, morals and values, objects or institutions.

ការប្រព្រឹត្តដែលដកចេញភាពជាមនុស្សពីសត្រូវ ឬក្រុមណាមួយក្នុងពីប្រជាជនសរុប ឬដែលបង្ហាញការមិនគោរពចំពោះសាសនា ជនជាតិ ឬជាទូទៅខាងប្រពៃណី វប្បធម៌ សីលធម៌ តម្លៃ សីលវត្ត ឬស្ថាប័ន។

**13.6** Adoption of measures that severely curtail the rights of those protected under international humanitarian law, including those aligned or perceived as aligned with opposing parties but not taking active part in hostilities.

ការអនុម័តវិធានការដែលបានកាត់បន្ថយសិទ្ធិយ៉ាងធ្ងន់ធ្ងររបស់មនុស្សដែលត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិ រួមបញ្ចូលទាំងអ្នកដែលបានឬត្រូវបានគេគិតថាមានគំនិតស្របគ្នាទៅនឹងក្រុមប្រឆាំងទោះមិនមានសកម្មខ្លាំងក្នុងការប្រឆាំងក៏ដោយ។

**13.7** Evidence of plans or discourse which reveals a threat of or incitement to violence against those protected under international humanitarian law, including as a means to spread terror, intimidate, demoralize, show military strength, provoke displacement, or as preliminary to further violence.

ភ័ស្តុតាងនៃផែនការឬនិន្នាការដែលបង្ហាញការគំរាមកំហែងឬការញុះញង់អំពើហិង្សាប្រឆាំងនឹងបទជនដែលត្រូវបានការពារក្រោមច្បាប់មនុស្សធម៌អន្តរជាតិ រួមទាំងជាមធ្យោបាយដើម្បីសាយភាយភេរវកម្ម, បំភិតបំភ័យ, បង្ខូចសីលធម៌, បង្ហាញកម្លាំងយោធា បង្កការភៀសខ្លួន ឬជាមធ្យោបាយបឋម សម្រាប់អំពើហិង្សាបន្ថែមក្នុងពេលខាងមុខ។

**13.8** Evidence of conduct interfering with or impeding delivery or access to supplies, facilities, equipment, objects or medical or humanitarian support indispensable to the survival of those protected under international humanitarian law.

ភ័ស្តុតាងនៃការប្រព្រឹត្តដែលជ្រៀតជ្រែកឬការរារាំងការប្រគល់ឬការយកបានសម្ភារៈបរិក្ខារ ឧបករណ៍ វត្ថុឬការគាំទ្រមនុស្សធម៌ឬវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់ជីវិតនៃអ្នកដែលបានការការពារក្រោមច្បាប់មនុស្សធម៌អន្តរជាតិ។

**13.9** Evidence of preparation of personnel and logistics enabling the transportation, movement or confinement of large numbers of people, or the conducting of medical experiments.

ភ័ស្តុតាងនៃការរៀបចំកងកម្លាំងនិងការរៀបចំដែលអាចធ្វើឱ្យការដឹកជញ្ជូន ផ្លាស់កន្លែង ឬការបង្ខាំងរបស់ប្រជាជនក្នុងចំនួនច្រើនឬធ្វើការពិសោធវេជ្ជសាស្ត្រ។

**13.10** Evidence of conduct related to the planning, development, production, storage, acquisition, availability or threat of use of weapons, projectiles, materials or substances which are by their nature indiscriminate or cause superfluous injury or unnecessary suffering to people, or that can cause widespread, long-term and severe damage to the natural environment.

ភ័ស្តុតាងនៃការប្រព្រឹត្តដែលទាក់ទងទៅនឹងការធ្វើផែនការ ការអភិវឌ្ឍ ផលិតកម្ម ការរក្សាទុក ការទទួលបាន លទ្ធភាពដែលមាន ឬការគំរាមកំហែងក្នុងការប្រើប្រាស់អាវុធ កាំជ្រួច សម្ភារឬសារធាតុដែលគ្មានការរើសអើងឬអាចបណ្តាលឱ្យរងរបួស រងទុក្ខវេទនាដែលមិនចាំបាច់សោះទៅមនុស្ស ឬអ្វីដែលអាចបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរ រីករាលដាល និងរយៈពេលយូរ ដល់បរិស្ថានធម្មជាតិ។

**13.11** Refusal to allow inspections by competent and independent bodies into allegations of conduct included in point 13.10, or action to stop such conduct.

ការបដិសេធមិនអនុញ្ញាតឱ្យមានការត្រួតពិនិត្យដោយស្ថាប័នមានសមត្ថកិច្ចនិងឯករាជ្យ លើការចោទប្រកាន់នៃអំពីដែលបានដាក់បញ្ចូលនៅក្នុងចំណុច 13.10 ឬសកម្មភាពណាដែលបញ្ឈប់ការប្រព្រឹត្តនេះ។

**13.12** Refusal to acknowledge detentions or places of detention or to allow visits by delegates of the International Committee of the Red Cross.

ការបដិសេធមិនទទួលស្គាល់ការឃុំខ្លួនឬកន្លែងឃុំឃាំងឬការអនុញ្ញាតឱ្យមានដំណើរទស្សនកិច្ចដោយប្រតិភូនៃគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ។

→

*Risk Factor 13 indicators, continued*

សូចនាករនៃកត្តាហានិភ័យ 13 បន្ត

**13.13** Issuance of rules of engagement or legislation that allow the disproportionate or indiscriminate use of force, or failure to take action to avoid launching such attacks or to conduct military operations in heavily populated areas or to non-military targets.

ការចេញបទបញ្ញត្តិឬច្បាប់ដែលអនុញ្ញាតឱ្យមានការប្រើប្រាស់ កម្លាំងវិសមាមាត្រឬមិនរើសអើង ឬការបរាជ័យក្នុងការចាត់វិធានការដើម្បីជៀសវាងការវាយប្រហារបែបនេះឬដើម្បីធ្វើប្រតិបត្តិការយោធានៅតំបន់ដែលមានប្រជាជនច្រើនឬគោលដៅដែលមិនមែនជាយោធា។

**13.14** Increase in the number of any of the attacks or operations mentioned in point 13.13.

ការបង្កើនចំនួននៃការវាយប្រហារណាឬប្រតិបត្តិការដែលបានរៀបរាប់នៅក្នុងឬចំណុច ១៣.១៣។

**13.15** Use of methods of warfare that reveal treachery, including taking advantage of the symbols or emblems of humanitarian or peacekeeping personnel, or not wearing uniforms or distinctive combat gear to portray combatants as civilians.

ការប្រើប្រាស់វិធីសាស្រ្តនៃសង្រ្គាមដែលបង្ហាញអំពើក្បត់ រួមទាំងការទាញយកប្រយោជន៍ពីនិមិត្តសញ្ញាឬតំណាងនៃមនុស្សធម៌ក្រុមរក្សាសន្តិភាព ឬដោយមិនពាក់ឯកសណ្ឋានឬឧបករណ៍ដើម្បីក្លែងយុទ្ធជនជាជនស៊ីវិល។

**13.16** Threats or appropriation, seizure, pillaging or intentional destruction or damage of civilian objects or property that belong, represent or are part of the cultural, social or religious identity of those protected under international humanitarian law, unless used for military purposes.

ការគំរាមកំហែងឬការបម្រុងប្រាក់ទុក, ការរឹបអូស, ប្លន់ឬបំផ្លាញដោយចេតនាឬ ការធ្វើឱ្យខូចខាតវត្ថុស៊ីវិលឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ, តំណាងឬជាផ្នែកមួយនៃអត្តសញ្ញាណវប្បធម៌ សង្គមឬសាសនារបស់អ្នកដែលការពារដោយច្បាប់មនុស្សធម៌អន្តរជាតិ លុះត្រាតែសម្រាប់គោលបំណងយោធា។

**13.17** Threats or orders of warfare without concessions or where there would be no survivors.

ការគំរាមកំហែងឬការបញ្ជាឱ្យមានសង្គ្រាមដោយគ្មានសម្បទានឬវាយកម្ទេចឱ្យអស់។

**13.18** Conduct that threatens the rule of law or any other measures that limit protection of the rights to life and physical integrity afforded by applicable international humanitarian law, including denial of its applicability.

ការប្រព្រឹត្តដែលគំរាមកំហែងដល់វិធានច្បាប់ ឬវិធានការណាមួយផ្សេងទៀតដែលដាក់កំណត់ដល់ការការពារសិទ្ធិក្នុងការរស់រានមានជីវិតនិងបូរណភាពរាងកាយ ដែលផ្តល់ដោយច្បាប់មនុស្សធម៌អន្តរជាតិ រួមទាំងការបដិសេធការអនុវត្តរបស់ច្បាប់នេះ។

3 For a definition of “those protected under international humanitarian law” within the context of this Framework, please consultSection I — Who are the victims of atrocity crimes?. Humanitarian or peacekeeping operations, though also protected under international humanitarian law, will be dealt separately in this Framework under risk factor 14.

និយមន័យនៃ «អ្នកដែលត្រូវបានការពារក្រោមច្បាប់មនុស្សធម៌អន្តរជាតិ» សម្រាប់ក្នុងបរិបទនៃក្របខ័ណ្ឌនេះសូមមើលផ្នែកទី I ស្តីពី តើនរណាជាជនរងគ្រោះនៃឧក្រិដ្ឋកម្មឃោរឃៅ? ប្រតិបត្តិការមនុស្សធម៌ឬរក្សាសន្តិភាព ទោះបីជាត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិនឹងត្រូវបានដោះស្រាយដោយឡែកពីគ្នាក្នុងក្របខ័ណ្ឌនេះនៅក្រោមកត្តាហានិភ័យ 14 ។

## Comment:

In contrast to the crimes of genocide and crimes against humanity, war crimes must always take place in the con- text of an armed conflict. Consequently, indicators specific to war crimes surface at a late stage, when options for prevention are more limited. For earlier preventive action, common risk factors should be considered first. However, even if a conflict is already under way, there are still measures that can be taken to diminish the effects of hostilities and, therefore, to prevent war crimes.

មតិយោបល់

ផ្ទុយទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាមត្រូវតែកើតឡើងជានិច្ចនៅក្នុងបរិបទជម្លោះប្រដាប់អាវុធ។ ហេតុដូច្នេះ សូចនាករជាក់លាក់ចំពោះឧក្រិដ្ឋកម្មសង្គ្រាម គឺលេចឡើងនៅដំណាក់កាលចុងក្រោយនៅពេលដែលជម្រើសសម្រាប់ការបង្ការមានកម្រិត។ ចំពោះសកម្មភាពបង្ការមុន ៗ កត្តាហានិភ័យទូទៅគួរតែត្រូវបានពិចារណាមុនគេ។ ប៉ុន្តែ ទោះបីជាជម្លោះកំពុងកើតមានរួចហើយក៏ដោយ ក៏នៅតែមានវិធានការនានាមួយចំនួនដែលអាចអនុវត្តបានដើម្បីកាត់បន្ថយផលប៉ះពាល់នៃអរិភាពហើយនឹងអាចទប់ស្កាត់ឧក្រិដ្ឋកម្មសង្គ្រាម។

The list of war crimes is long and each has a specific definition. They can also vary according to different norms of international law. The indicators identified above attempt to include indicators relevant to as many war crimes as possible that are related to the protection of human life. However, they are far from exhaustive. Some of the indicators identified can also on their own be war crimes, such as attacks against civilian property, which can point to an increase in the threat to human life.

បញ្ជីនៃឧក្រិដ្ឋកម្មសង្គ្រាម គឺវែង ហើយបញ្ជីនីមួយៗមាននិយមន័យច្បាស់លាស់។ បញ្ជីទាំងនេះក៏អាចប្រែប្រួលតាមបទដ្ឋានផ្សេងៗនៃច្បាប់អន្តរជាតិផងដែរ។ សូចនាករដែលបានកំណត់ខាងលើនេះរួមបញ្ចូលទាំងសូចនាករទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម ដែលអាចជួយការការពារជីវិតមនុស្សបានច្រើនបំផុតដែលអាចទៅរួច។ ទោះជាយ៉ាងណាក៏សូចនាករទាំងនេះ មិនអាចលើកមកបង្ហាញបានអស់ទេ។ សូចនាករមួយចំនួនដែលបានសម្គាល់អាចជាឧក្រិដ្ឋកម្មសង្គ្រាមដោយខ្លួនឯង ដូចជាការវាយប្រហារទៅលើទ្រព្យសម្បត្តិស៊ីវិលដែលអាចចង្អុលបង្ហាញពីការកើនឡើងនូវការគំរាមកំហែងដល់ជីវិតមនុស្ស។

RISK FACTOR 14

កត្តាហានិភ័យ ១៤

## Serious threats to humanitarian or peacekeeping operations

ការគំរាមកំហែងធ្ងន់ធ្ងរដល់ប្រតិបត្តិការមនុស្សធម៌ឬរក្សាសន្តិភាព

**Conflict-related conduct that threatens the protection provided by international humanitarian law to humanitarian assistance or peacekeeping personnel not taking direct part in hostilities.**

## Indicators សូចនាករ

**14.1** Perceptions of partiality or political interference by humanitarian or peacekeeping operations, their members, the broader international community, international, regional or national organizations, individual countries, or others sponsoring or participating in the operations.

ការយល់ឃើញថាជាភាពលម្អៀងឬការជ្រៀតជ្រែកនយោបាយរបស់កងរក្សាសន្តិភាពឬភ្នាក់ងារជំនួយមនុស្សធម៌ សមាជិករបស់ពួកគេ ឬសហគមន៍អន្តរជាតិ អង្គការអន្តរជាតិ ក្នុងតំបន់ឬថ្នាក់ជាតិ បណ្តាប្រទេសនានា ឬអ្នកដទៃទៀតឧបត្ថម្ភឬចូលរួមក្នុងប្រតិបត្តិការ។

**14.2** Increase in identity-based conflicts and perceptions about humanitarian or peacekeeping operations as associated with the opponent or as an obstacle to plans of elimination, marginalization or displacement.

ការបង្កើនជម្លោះដែលមានមូលដ្ឋានលើអត្តសញ្ញាណនិងទស្សនៈអំពីកងរក្សាសន្តិភាពនិងក្រុមការងារមនុស្សធម៌ថាបានផ្សារភ្ជាប់ជាមួយនឹងក្រុមគូជម្លោះ ឬជាឧបសគ្គដល់ផែនការក្នុងការលុបបំបាត់ ការរើសអើង នឹងការផ្លាស់ទីជម្រក។

**14.3** Increased intensity of the conflict and scarcity of livelihoods or other resources.

ការកើនឡើងកម្រិតអាំងតង់ស៊ីតេនៃជម្លោះនិងការខ្វះការចិញ្ចឹមជីវិត ឬធនធានផ្សេងទៀត។

**14.4** Fragmentation of parties to the conflict or disintegration of chains of command within them.

ការបែងចែកនៃភាគីជម្លោះឬការបែកបាក់នៃខ្សែបញ្ជាការក្នុងក្រុមរបស់ពួកគេ។

**14.5** Interference, limitation or prohibition of access or movement of humanitarian or peacekeeping operations or their personnel.

ការជ្រៀតជ្រែក ដែនកំណត់ ឬការហាមឃាត់នៃលទ្ធភាពឬចលនានៃប្រតិបត្តិការថែរក្សាសន្តិភាពឬមនុស្សធម៌ ឬបុគ្គលិក ។

**14.6** Tampering with or removal of signs identifying protected objects or locations where humanitarian or peacekeeping operations are stationed or providing support.

ការរុះរើឬការយកចេញនៃសញ្ញាកំណត់អត្តសញ្ញាណវត្ថុការពារឬទីតាំងដែលជាកន្លែងដែលមានប្រតិបត្តិការមនុស្សធម៌ឬរក្សាសន្តិភាពឈរជើងឬកំពុងផ្តល់ការគាំទ្រជំនួយ។

**14.7** Incidents of improper use of a flag of truce, of the flag or of the military insignia and uniform of the United Nations and the distinctive emblems of the Geneva Conventions.

ឧប្បត្តិហេតុនៃការប្រើប្រាស់មិនត្រឹមត្រូវនៃទង់ជាតិនៃបទឈប់បាញ់ ទង់ជាតិឬនៃសញ្ញានិងឯកសណ្ឋានយោធារបស់អង្គការសហប្រជាជាតិ និងវត្ថុប្រើជានិមិត្តសញ្ញានៃអនុសញ្ញាទីក្រុងហ្សឺណែវ។

**14.8** Attacks against locations in close proximity to humanitarian or peacekeeping operations and personnel, or on the routes taken by them during their activities.

វាយប្រហារប្រឆាំងនឹងទីតាំងនៅជិតនឹងប្រតិបត្តិការ និង ក្រុមមនុស្សធម៌និងកងរក្សាសន្តិភាពឬ នៅលើផ្លូវដែលពួកគេបានប្រើក្នុងអំឡុងសកម្មភាពរបស់ខ្លួន។

**14.9** Discourse or evidence of plans that suggest a threat, or the incitement or tolerance of acts of violence against humanitarian or peacekeeping operations and personnel.

និន្នាការឬភ័ស្តុតាងនៃផែនការដែលបានបង្ហាញការគំរាមកំហែងឬការញុះញង់ឬការអត់ឱនឱ្យអំពើហិង្សាកើតមានឡើងទៅលើក្រុមមនុស្សធម៌ឬកងរក្សាសន្តិភាព។

**14.10** Disrespect, threats or increase in attacks to objects, property or persons using the distinctive emblems of the Geneva Conventions or of other humanitarian or peacekeeping operations.

ការមិនគោរពការគំរាមកំហែងឬការកើនឡើងនៃការវាយប្រហារលើវត្ថុ ទ្រព្យសម្បត្តិ ឬមនុស្សដោយប្រើវត្ថុជានិមិត្តសញ្ញានៃអនុសញ្ញាទីក្រុងហ្សឺណែវ ឬប្រតិបត្តិការមនុស្សធម៌ ឬរក្សាសន្តិភាពផ្សេងទៀត។

## Comment:

International humanitarian law affords specific protection to those working for humanitarian assistance or peacekeeping missions in a setting of armed conflict, as long as they do not take direct part in hostilities, except for self-defense. These operations are particularly exposed to the violence that accompanies periods of conflict due to the key role they play in the protection of human lives and the alleviation of human suffering during those periods. A set of specific indicators can help in assessing the likelihood of attacks against this group that could constitute war crimes. As the focus of the Framework is the protection of human life, attacks against property of humanitarian or peacekeeping operations have been included only as indicators of an increased risk to the lives of their staff.

## មតិយោបល់

ច្បាប់មនុស្សធម៌អន្តរជាតិផ្តល់ការការពារយ៉ាងជាក់លាក់ដល់អ្នកដែលធ្វើការសម្រាប់ជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាពនៅក្នុងជម្លោះប្រដាប់អាវុធ ដរាបណាពួកគេមិនបានចូលរួមដោយផ្ទាល់នៅក្នុងជម្លោះ, លើកលែងតែការការពារខ្លួន។ ប្រតិបត្តិការទាំងនេះប្រឈមនឹងអំពើហិង្សាក្នុងអំឡុងពេលនៃជម្លោះដោយសារតែតួនាទីយ៉ាងសំខាន់របស់ពួកគេក្នុងការការពារជីវិតមនុស្សនិងការកាត់បន្ថយនៃការរងទុក្ខវេទនារបស់មនុស្សក្នុងអំឡុងពេលទាំងនោះ។ សំណុំនៃសូចនាករជាក់លាក់មួយដែលអាចជួយក្នុងការវាយតម្លៃលទ្ធភាពនៃការវាយប្រហារប្រឆាំងនឹងក្រុមនេះដែលអាចចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាម។ ដោយសារការផ្តោតនៃក្របខ័ណ្ឌនេះគឺជាការការពារជីវិតមនុស្ស ការវាយប្រហារប្រឆាំងនឹងរបស់កម្មសិទ្ធិរបស់ក្រុមមនុស្សធម៌ឬកងប្រតិបត្តិការថែរក្សាសន្តិភាពត្រូវបានដាក់បញ្ចូលដើម្បីជាសូចនាករនៃការកើនឡើងហានិភ័យដល់ជីវិតរបស់ពួកគេប៉ុណ្ណោះ។

# Annex 1
# ឧបសម្ព័ន្ធ

# Legal Definitions of Atrocity Crimes

និយមន័យផ្លូវច្បាប់នៃឧក្រិដ្ឋកម្មឃោរឃៅ

**Genocide**

Genocide is defined in Article 2 of the Convention on the Prevention and Punishment of the Crime of Genocide and has become a norm of customary international law. The same definition can be found in other documents of international law: Article 6 of the Rome Statute of the International Criminal Court; Article 4(2) of the Statute of the International Criminal Tribunal for the former Yugoslavia, and Article 2(2) of the Statute of the International Criminal Tribunal for Rwanda.

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍**

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានកំណត់ក្នុងមាត្រា 2 នៃ អនុសញ្ញាស្តីពីការបង្ការ និង ការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបានក្លាយជាបទដ្ឋាននៃច្បាប់ប្រពៃណីអន្តរជាតិ។ និយមន័យដូចគ្នានេះមាននៅក្នុងឯកសារផ្សេងៗទៀតនៃច្បាប់អន្តរជាតិ៖ មាត្រា 6 នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ; មាត្រា 4 (2) នៃលក្ខន្តិកៈសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងមាត្រា 2 (2) នៃលក្ខន្តិកៈសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា។

**Convention on the Prevention and Punishment of the Crime of Genocide**

*Article 2*

In the present Convention, genocide means any of the following acts committed with intent to destroy, in whole or in part, a national, ethnical, racial or religious group, as such:

*(a)* Killing members of the group;

*(b)* Causing serious bodily or mental harm to members of the group;

*(c)* Deliberately inflicting on the group conditions of life calculated to bring about its physical destruction in whole or in part;

*(d)* Imposing measures intended to prevent births within the group;

*(e)* Forcibly transferring children of the group to another group.

**អនុសញ្ញាស្តីពីការបង្ការ និង ការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍**

មាត្រា 2

ក្នុងអនុសញ្ញាបច្ចុប្បន្ននេះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានន័យថាអំពើដូចណាមួយខាងក្រោមដែលត្រូវបានប្រព្រឹត្តក្នុងចេតនាបំផ្លាញទាំងស្រុងឬមួយផ្នែកនូវក្រុមជនរួមជាតិ ជនជាតិ ជាតិសាសន៍ ឬជាតិសាសនា រួមទាំង៖

(ក) ការសម្លាប់សមាជិកក្រុម។

(ខ) ការបង្កគ្រោះថ្នាក់ផ្នែករាងកាយឬផ្លូវចិត្តធ្ងន់ធ្ងរចំពោះសមាជិកនៃក្រុម។

(គ) ការដាក់ដោយចេតនាលើក្រុមនូវលក្ខខណ្ឌជីវិតដែលត្រូវបានចាត់ទុកថានាំមកនូវការបំផ្លាញផ្នែករាងកាយរបស់ក្រុមទាំងស្រុងឬមួយផ្នែក

(ឃ)ការដាក់វិធានការដែលមានចេតនាទប់ស្កាត់កំណើតនៅក្នុងក្រុម

(ង) ការផ្ទេរកុមារនៃក្រុមមួយទៅក្រុមមួយទៀតដោយបង្ខំ។

## Crimes against Humanity

Crimes against humanity have not been codified in a treaty, similar to genocide and war crimes. However, the definition has developed under customary law and through the jurisdiction of international courts. Article 7(1) of the Rome Statute of the International Criminal Court; Article 5 of the Statute of the International Criminal Tribunal for the former Yugoslavia and Article 3 of the Statute of the International Criminal Tribunal for Rwanda, include definitions of crimes against humanity, even though they do not totally coincide.

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនត្រូវបានបង្កើតជាក្រមនៅក្នុងសន្ធិសញ្ញាមួយដែលស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងសង្គ្រាមឡើយ។ ទោះជាយ៉ាងនេះក្តី និយមន័យវាបានអភិវឌ្ឍក្រោមច្បាប់ប្រពៃណីនិងតាមរយៈយុត្តាធិការរបស់តុលាការអន្តរជាតិ។ មាត្រា 7 (1) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា 5 នៃលក្ខន្តិកៈសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងមាត្រា 3 នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា រួមទាំងនិយមន័យនានានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្វីបើលក្ខន្តិកៈទាំងនេះមិនដូចគ្នាទាំងស្រុងក៏ដោយ។

## Rome Statute of the International Criminal Court

*Article 7*

1. For the purpose of this Statute, "crime against humanity" means any of the following acts when committed as part of a widespread or systematic attack directed against any civilian population, with knowledge of the attack:

*(a)* Murder;

*(b)* Extermination;

*(c)* Enslavement;

*(d)* Deportation or forcible transfer of population;

*(e)* Imprisonment or other severe deprivation of physical liberty in violation of fundamental rules of international law;

*(f)* Torture;

*(g)* Rape, sexual slavery, enforced prostitution, forced pregnancy, enforced sterilization, or any other form of sexual violence of comparable gravity;

*(h)* Persecution against any identifiable group or collectivity on political, racial, national, ethnic, cultural, religious, gender as defined in paragraph 3, or other grounds that are universally recognized as impermissible under international law, in connection with any act referred to in this paragraph or any crime within the jurisdiction of the Court;

*(i)* Enforced disappearance of persons;

*(j)* The crime of apartheid;

*(k)* Other inhumane acts of a similar character intentionally causing great suffering, or serious injury to body or to mental or physical health.

2. For the purpose of paragraph 1:

*(a)* "Attack directed against any civilian population" means a course of conduct involving the multiple commission of acts referred to in paragraph 1 against any civilian population, pursuant to or in furtherance of a State or organizational policy to commit such attack;

**លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ**

មាត្រា7

1. សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ ពាក្យ "បទល្មើសប្រឆាំងមនុស្សជាតិ" មានន័យថា អំពើណាមួយដូចតទៅនេះ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារដ៏រីករាយដាលឬមានលក្ខណៈជាប្រព័ន្ធមួយដោយផ្ទាល់ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់ ដោយមានការដឹងពីការវាយប្រហារ៖

(ក) ឃាតកម្ម។

(ខ) ការធ្វើឱ្យសាបសូន្យ។

(គ) ការដាក់មនុស្សឱ្យធ្វើជាទាសករ។

(ឃ) ការនិរទេស ឬ ការផ្លាស់ទីប្រជាពលរដ្ឋដោយបង្ខិតបង្ខំ។

(ង) ការដាក់ពន្ធនាគារ ឬ ការដកហូតសេរីភាពខាងរូបកាយ ដែលជាការបំពានលើវិធានជាមូលដ្ឋាននៃច្បាប់អន្តរជាតិ។

(ច) ការធ្វើទារុណកម្ម។

(ឆ) ការចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយការដាក់បង្ខំ ការមានគភ៌ដោយបង្ខំ វណ្ណកម្មដោយដាក់បង្ខំ ឬការបំពានផ្លូវភេទក្នុងទ្រង់ទ្រាយផ្សេងទៀត ដែលមានភាពធ្ងន់ធ្ងរប្រហែលគ្នានេះ។

(ជ) ការធ្វើទុក្ខបុកម្នេញលើក្រុម ឬលើសមូហភាពជាក់លាក់ណាមួយ លើមូលដ្ឋាននយោបាយ ពូជសាសន៍ ជាតិសាសន៍ ជាតិពន្ធ វប្បធម៌ សាសនា យេនឌ័រ ដូចបានកំណត់និយមន័យក្នុងកថាខ័ណ្ឌទី3 ឬ លើមូលដ្ឋានផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ជាសាកលថា មិនអាចអនុញ្ញាតឱ្យធ្វើបានឡើយតាមច្បាប់អន្តរជាតិនៅក្នុងទំនាក់ទនងជាមួយអពើណាមួយដែលបានចែងក្នុងកថាខ័ណ្ឌនេះ ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលស្ថិតក្នុងយុត្តាធិការតុលាការ។

(ឈ) ការបាត់ខ្លួនមនុស្សដោយដាក់បង្ខំ។

(ញ) បទល្មើសព្រហ្មទនញឧអាប៉ាថេត

(ដ) អំពើអមនុស្សធម៌ដែលមានលក្ខណៈជាអន្តរជាតិស្រដៀងគ្នាដទៃទៀត ដែលមានចេតនាបង្កឱ្យមានការរងគ្រោះដ៏ធំធេង ឬគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់រូបកាយ ឬដល់សុខភាពខាងបញ្ញាស្មារតី ឬសុខភាពខាងរូបកាយ។

2. សម្រាប់គោលបណងនៃកថាខ័ណ្ឌទី១

(ក) “ការវាយប្រហារប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់” មានន័យថា ដំណើរការនៃការប្រព្រឹត្តមួយពាក់ព័ន្ធ នឹងការប្រព្រឹត្តអំពើជាច្រើនដែលមានចែងក្នុងកថាខ័ណ្ឌទី1 ប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាម្នាក់ស្របតាម ឬ ស្ថិតក្នុងការធ្វើឱ្យជឿនលឿនទៅមុខរបស់រដ្ឋមួយ ឬ គោលនយោបាយចាត់តាំងដើម្បីប្រព្រឹត្តការវាយប្រហារបែបនេះ។

## War Crimes

War crimes are those violations of international humanitarian law that incur perpetrators in individual criminal responsibility under international law. There is no one single document that codifies all war crimes. Lists can be found in both international humanitarian law and international criminal law treaties, as well as in inter- national customary law. The 1949 Geneva Conventionsand 1977 Additional Protocol I contain lists. Article 8 of the Rome Statute of the International Criminal Court; Article 2 and 3 of the Statute of the International Criminal Tribunal for the former Yugoslavia and Article 4 of the Statute of the International Criminal Tribunal for Rwanda, also include lists of war crimes. They do not always coincide.

**ឧក្រិដ្ឋកម្មសង្គ្រាម**

ឧក្រិដ្ឋកម្មសង្គ្រាមគឺការរំលោភបំពានទាំងឡាយនៃច្បាប់មនុស្សធម៌អន្តរជាតិដែលដាក់បន្ទុកជនល្មើសជាបុគ្គល ដែលនៅក្នុងទទួលខុសត្រូវបទឧក្រិដ្ឋព្រហ្មទណ្ឌដែលស្ថិតក្រោមច្បាប់អន្តរជាតិ។ មិនមានឯកសារតែមួយដែលចងក្រងឧក្រិដ្ឋកម្មសង្គ្រាមទាំងអស់នោះទេ។ បញ្ជីរាយនាមមាននៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិនិងសន្ធិសញ្ញាផ្សេងៗនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ រួមទាំងនៅក្នុងច្បាប់ប្រពៃណីអន្តរជាតិ។ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ1949 និងអនុស្សរណៈបន្ថែមឆ្នាំ1977 មានរាយបញ្ជីនេះ។ មាត្រា 8 នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា 2 និង 3 នៃលក្ខន្តិកៈរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងមាត្រា 4 នៃលក្ខន្តិកៈសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា ក៏មានដាក់បញ្ចូលនូវបញ្ជីនៃឧក្រិដ្ឋកម្មសង្គ្រាមដែរ។ ពួកគេមិនតែងតែដូចគ្នានោះទេ។

**លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ**

មាត្រា8

1. តុលាការត្រូវមានយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌសង្គ្រាម ជាពិសេស នៅពេលដែលអំពើនោះបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃផែនការ ឬនយោបាយ ឬជាផ្នែកមួយនៃការប្រព្រឹត្តក្នុងទំហំដ៏ធំធេងនៃបទល្មើសព្រហ្មទណ្ឌបែបនេះ។

2. សម្រាប់គោលបំណងនៃច្បាប់លក្ខន្តិកៈនេះ “បទល្មើសព្រហ្មទណ្ឌសង្គ្រាម” មានន័យថា៖

(ក) ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី12 ខែសីហា ឆ្នាំ1949 នូវអំពើប្រឆាំងនឹងមនុស្ស ឬទ្រព្យសម្បត្តិដែលត្រូវការការពារតាមបទប្បញ្ញតិទាំងឡាយនៃអនុសញ្ញាទីក្រុងហ្សឺណែវដែលទាក់ទង ដែលមានរាយឈ្មោះដូចខាងក្រោម៖

(i) ការសម្លាប់ដោយឆន្ទៈ

(ii) ទារុណកម្ម ឬការប្រព្រឹត្តអពើអមនុស្សធម៌រួមទាំងការពិសោធជីវសាស្រ្ត

(iii) ការបង្កការរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ដល់រូបរាងកាយឬសុខភាពយ៉ាងធ្ងន់ធ្ងរដោយឆន្ទៈ

(iv) ការបំផ្លិចបំផ្លាញ និងការដកហូតយកទ្រព្យសម្បត្តិដ៏ធំធេង ដែលមិនធ្វើឡើងដោយមកពីមូលហេតុនៃភាពចាំបាច់ខាងយោធា និង ធ្វើឡើងដោយខុសច្បាប់ និង ដោយព្រៃផ្សៃ

(v) ការបង្ខំអ្នកទោសឈ្លើយសង្គ្រាម ឬជនដែលត្រូវការការពារដទៃទៀត ឱ្យបំរើការក្នុងកងកម្លាំងរបស់សត្រូវ

(vi) ការដកហូតសិទ្ធិរបស់អ្នកទោសឈ្លើយសង្គ្រាម ឬជនដែលត្រូវការពារដទៃទៀតដោយឆន្ទៈពិការជំនុំជំរះទោសត្រឹមត្រូវ និង តាមប្រក្រតី

(vii) ការនិរទេសដោយខុសច្បាប់ ឬ ការបញ្ជូនផ្លាស់ទីដោយខុសច្បាប់ ឬការបង្ខាំងមនុស្សដោយខុសច្បាប់

(viii) ការចាប់មនុស្សធ្វើជាចំណាប់ខ្មាំង

(ខ) ការបំពានលើច្បាប់ទំនៀមទម្លាប់ដ៏ធ្ងន់ធ្ងរដទៃទៀត ដែលអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ នៅក្នុងគម្រោងដែលបានបង្កើតឡើងតាមច្បាប់អន្តរជាតិនូវអំពើណាមួយដូចរាយឈ្មោះតទៅនេះ៖

(i) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិល ឬប្រឆាំងនឹងឯកត្តជនស៊ិវិលដែលមិនចូលរួមដោយផ្ទាល់នៅក្នុងការប្រទូសរាយគ្នានោះទេ

(ii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិល ដែលនោះជាវត្ថុដែលមិនមែនជាចំណុចគោលដៅយោធា

(iii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹង មន្ត្រី ប៉ុស្តិ៍ទីតាំង សម្ភារៈ អង្គភាព ឬ យានជំនិះ ពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាព អនុលោមតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ដរាបណាពួកគេមានសិទ្ធិចំពោះការការពារដែលផ្តល់ឱ្យដល់ជនស៊ីវិល ឬ ដល់វត្ថុស៊ីវិលតាមច្បាប់អន្តរជាតិពីជម្លោះប្រដាប់អាវុធ។

(iv) ការបើកការវាយប្រហារដោយចេតនា ដោយដឹងថាការវាយប្រហារនេះនឹងបង្កឱ្យបាត់បង់អាយុជីវិត ឬគ្រោះថ្នាក់ជនស៊ីវិល ឬធ្វើឱ្យខូចខាតវត្ថុស៊ីវិលជាយថាហេតុ ឬការខូចខាតដ៏សុសសាយរយៈពេលវែងឆ្ងាយ និងដ៏ធំធេងចំពោះបរិស្ថានធម្មជាតិដែលពិតជាមានលក្ខណៈហួសហេតុក្នុងទំនាក់ទំនងទៅនឹងប្រយោជន៍យោធាទាំងមូលដោយផ្ទាល់និង ដោយច្បាស់លាស់។

(v) ការវាយប្រហារ ឬ ការទម្លាក់គ្រាប់បែកតាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ លំនៅដ្ឋាន ឬអគារ ដែលមិនត្រូវបានការពារ និង មិនមែនជាចំណុចគោលដៅយោធា។

(vi) ការសម្លាប់ ឬការធ្វើឱ្យរបួសដល់យុទ្ធជនដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ ឬជនដែលគ្មានមធ្យោបាយការពារខ្លួនទៅទៀត ដែលបានចុះចាញ់ព្រមតាមខ្លួន។

(vii) ការធ្វើការប្រើប្រាស់មិនសមស្របនូវទង់សង្គ្រាម ទង់ជាតិ សញ្ញាសម្គាល់យោធា និង ឯកសណ្ឋានសត្រូវ ឬ ឯកសណ្ឋានរបស់អង្គការសហប្រជាជាតិ ក៏ដូចជានិមិត្តសញ្ញាដោយឡែកៗនៃសញ្ញាទីក្រុងហ្សឺណែវ ដែលបណ្តាលឱ្យមានការស្លាប់ ឬគ្រោះថ្នាក់ដល់មនុស្សយ៉ាងធ្ងន់ធ្ងរ។

(viii) ការបញ្ជូនផ្លាស់ទីដោយផ្ទាល់ ឬដោយប្រយោល នូវកម្លាំងដែលកំពុងកាន់កាប់ផ្នែកខ្លះនៃពលរដ្ឋស៊ីវិលរបស់ខ្លួនផ្ទាល់ ចូលទៅក្នុងទឹកដីដែលខ្លួនកាន់កាប់ ឬការនិរទេស ឬការបញ្ជូនផ្លាស់ទីពលរដ្ឋខ្លះ ឬទាំងអស់នៃទឹកដីដែលបានចូលកាន់កាប់ទៅក្នុងទឹកដីនោះ ឬចេញក្រៅទឹកដីនោះ។

(ix) ការដឹកនាំចេតនានូវការវាយប្រហារប្រឆាំងនឹងអគារ ដែលបានសង់ឡើង សម្រាប់គោលបណងសាសនា ការអប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬគោលបំណងសប្បុរសធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីពេទ្យ និង ទីកន្លែងដែលអ្នកជំងឺ និង អ្នករងរបួសប្រមូលផ្តុំនៅ ដោយកន្លែងទាំងនេះមិនមែនជាចំណុចគោលដៅយោធា។

(x) ការដាក់ជនទាំងឡាយដែលស្ថិតក្នុងអំណាចរបស់គូបដិបក្ខឱ្យរងការធ្វើវិកលកម្ម ឬការពិសោធខាងវេជ្ជសាស្ត្រ ឬខាងវិទ្យាសាស្ត្រប្រភេទណាមួយ ដែលធ្វើយុត្តិកម្មដោយការព្យាបាលខាងវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឬការដេកពេទ្យ ដល់ជនពាក់ព័ន្ធទាំងនោះទេ ឬដែលមិន ធ្វើឡើងដើម្បីជាប្រយោជន៍របស់ជននោះ និង ដែលបណ្តាលឱ្យជននោះស្លាប់ឬធ្វើឱ្យជននោះ រងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់សុខភាព។

(xi) ការសម្លាប់ ឬ ការធ្វើឱ្យរបួសដោយចិត្តក្បត់ដល់ជនទាំងឡាយដែលជារបស់ប្រទេស ឬយោធាបច្ចាមិត្ត។

(xii) ការប្រកាសថាមិនផ្តល់ការត្រាប្រណីណាមួយឡើយ។

(xiii) ការបំផ្លាញ ឬការរឹបអូសយកទ្រព្យសម្បត្តិរបស់សត្រូវ លើកលែងតែការបំផ្លាញឬការរឹបអូសនោះត្រូវទាមទារបញ្ជាឱ្យធ្វើដោយសារភាពចាំបាច់នៃសង្គ្រាម។

(xiv) ការប្រកាសលុបចោល ពន្យារ ឬ មិនទទួលខុសត្រូវនៅក្នុងតុលាការនៃច្បាប់ (court of law) នូវសិទ្ធិ និង សកម្មភាពទាំងឡាយណារបស់ពលរដ្ឋនៃភាគីបច្ចាមិត្ត។

(xv) ការបង្ខំឱ្យពលរដ្ឋនៃភាគីបច្ចាមិត្តចូលរួមក្នុងប្រតិបត្តិការសឹកសង្គ្រាមដឹកនាំធ្វើឡើងប្រឆាំងនឹងប្រទេសរបស់ពួកគេផ្ទាល់ ទោះបីជាពួកគេបានបម្រើការប្រទូសរាយមុនការចាប់ ផ្តើមសង្គ្រាមក៏ដោយ។

(xvi) ការចូលលួចប្លន់ទីក្រុង ឬ ទីកន្លែងណាមួយ ទោះបីធ្វើឡើងដោយការវាយតប់ក៏ដោយ។

(xvii) ការប្រើប្រាស់ជាតិពុល ឬអាវុធជាតិពុល។

(xviii) ការប្រើប្រាស់ឧស្ម័នស្ទះដង្ហើម ឧស្ម័នពុល ឬ ឧស្ម័នដទៃទៀត និង ថ្នាំទឹក ឧបករណ៍ ឬគ្រឿងស្រដៀងគ្នានេះដទៃទៀត។

(xix) ការប្រើប្រាស់គ្រាប់កាំភ្លើងដែលអាចរីក ឬ ផ្ទុះបែកនៅក្នុងខ្លួនមនុស្សបានយ៉ាងងាយស្រួលដូចជា គ្រាប់កាំភ្លើងដែលមានស្រទាប់ស្រោបពីខាងក្រៅយ៉ាងរឹងមាំតែមិនមានស្រោបត្រង់បណ្តូលវាទាំងមូលទេ ឬដែលមានច្រៀកដោយស្នាមវះ។

(xx) ការប្រើប្រាស់អាវុធកាំភ្លើងធ្លោង ព្រមទាំងឧបករណ៍ និង វិធីសាស្ត្រធ្វើសង្គ្រាមសឹកដែលមានលក្ខណៈបណ្តាលឱ្យជនរងគ្រោះថ្នាក់ដ៏លើសលប់ ឬគ្រោះថ្នាក់ដែលមិនចាំបាច់ ឬ ដែលមិនរើសមុខ យ៉ាងជាប់នូវក្នុងការបំពានច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធដោយលក្ខខ័ណ្ឌថា អាវុធ កាំភ្លើងធ្លោងព្រមទាំងឧបករណ៍ និងវិធីសាស្ត្រធ្វើសង្គ្រាមសឹកនោះ គឺជាកម្មវត្ថុនៃការហាមឃាត់ដ៏ទូលំទូលាយមួយ ហើយត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធនៃច្បាប់លក្ខន្តិកៈនេះដោយការធ្វើវិសោធនកម្ម អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធដូចមានចែងក្នុងមាត្រា121 និង 123។

(xxi) ការប្រព្រឹត្តអំពើយង់ឃ្នងខ្លាំងលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ជាពិសេស ការប្រព្រឹត្តដែលធ្វើឱ្យអាម៉ាស និង បាត់បង់តម្លៃមនុស្ស។

(xxii) ការប្រព្រឹត្តអំពើចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយដាក់បង្ខំ ការមានគភ៌ដោយបង្ខំ ដូចមានកំណត់និយមន័យនៅ កថាខ័ណ្ឌទី2(ច) នៃមាត្រា7 វណ្ណកម្មដោយដាក់បង្ខំ ឬការបំពានផ្លូវភេទក្នុងទ្រង់ទ្រាយផ្សេងៗទៀត ក៏បង្កើតជាការពំពានយ៉ាងធ្ងន់ធ្ងរលើ អនុសញ្ញាទីក្រុងហ្សឺណែវដែរ។

(xxiii) ការប្រើប្រាស់វត្តមាននៃជនស៊ីវិល ឬជនដែលត្រូវការពារដទៃទៀតដើម្បីទទួលបានអភ័យឯកសិទ្ធិលើតំបន់ ឬលើកកម្លាំងយោធាជាក់លាក់ដើម្បីឱ្យរួចផុតពីប្រតិបត្តិការសឹក។

(xxiv) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអគារ ឧបករណ៍ សម្ភារៈសុខភិបាល ឧបករណ៍ដឹកជញ្ជូនវេជ្ជសាស្ត្រ បុគ្គលិកពេទ្យ ដោយការប្រើប្រាស់និមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងហ្សឺណែវ ស្របតាមច្បាប់អន្តរជាតិ។

(xxv) ការប្រើប្រាស់ការបង្អត់អាហារដោយចេតនាដល់ជនស៊ីវិល ធ្វើជាមធ្យោបាយសឹកសង្គ្រាម ដោយការដកហូតយកពីពួកគេនូវវត្ថុដែលមានចាំបាច់សម្រាប់ការរស់នៅរបស់ពួកគេ រួមទាំងការរារាំងបង្អាក់ជាឆន្ទៈនូវការផ្គត់ផ្គង់ជំនួយសង្គ្រោះ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ។

(xxvi) ការកេងឬការបញ្ជូនកុមារក្រោមអាយុដប់ប្រាំឆ្នាំឱ្យចូលបម្រើកងទ័ពជាតិ ឬ ប្រើប្រាស់ពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងការប្រទូសរាយគ្នា។

(គ) ក្នុករណីជម្លោះយោធាដែលមិនមានលក្ខណៈអន្តរជាតិ មិនមានការបំពានដ៏ធ្ងន់ធ្ងរលើមាត្រា3រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួនចុះថ្ងៃទី12ខែសីហាឆ្នាំ1949 សកម្មភាពណាមួយដូចមានរាយឈ្មោះខាងក្រោមនេះ ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនទាំងឡាយ ដែលមិនបានចូលរួមសកម្មក្នុងការប្រទូសរាយទេ រួមទាំងសមាជិកនៃពលទាហានដែលបានទម្លាក់អាវុធរបស់ខ្លួនចុះ និងអ្នកដែលស្ថិតនៅក្នុទីលានប្រយុទ្ធ (Those placed hers de contract) ដោយមានជំងឺ មានរបួស ដោយការឃុំឃាំង ឬដោយមូលហេតុដទៃទៀត៖

(i) អំពើហិង្សាដល់ជីវិត ឬ មនុស្ស ជាពិសេសអំពើមនុស្សឃាតគ្រប់ប្រភេទទាំងអស់ ការធ្វើកាយវិកាល ការប្រព្រឹត្តឃោរឃៅ និង អំពើទារុញកម្ម

(ii) ការប្រព្រឹត្តអំពើយង់ឃ្នងខ្លាំងលើសេចក្តីថ្លៃថ្នូររបស់បុគ្គល ជាពិសេស ការប្រព្រឹត្តអំពើដែលនាំឱ្យមានភាពអាម៉ាស់ និងអស់តម្លៃមនុស្ស។

(iii) ការចាប់ធ្វើចំណាប់ខ្មាំង។

(iv) ការទប់ស្កាត់ និងការអនុវត្តការកាត់ទោសដោយគ្មានសាលក្រមចេញដោយតុលាការ ដែលត្រូវបានបង្កើតឡើងជាប្រក្រតីដែលផ្តល់ការធានាខាងតុលាការដែលជាទូទៅត្រូវបានទទួលស្គាល់ថាមានភាពសំខាន់ខានមិនបាន។

(ឃ) កថាខ័ណ្ឌទី2(គ) អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមានចរិតលក្ខណៈជាអន្តរជាតិ ដូច្នេះហើយមិនអនុវត្តលើស្ថានភាពនៃការរំខាន និងភាពតានតឹងផ្ទៃក្នុងដូចជា កុបកម្ម អំពើហិង្សា មិនទៀងទាត់និងដាច់ឯកកោពីគេ ឬសកម្មភាពដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នា។

(ង) ការបំពានដ៏ធ្ងន់ធ្ងរដទៃទៀតលើច្បាប់ និង ទំនៀមទម្លាប់ដែលយកមកអនុវត្តចំពោះជម្លោះប្រដាប់អាវុធ ដែលមិនមានចរិតលក្ខណៈជាអន្តរជាតិ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិ នូវអំពើដូចមានរាយឈ្មោះតទៅនេះ៖

(i) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងពលរដ្ឋស៊ីវិលទូទៅឬប្រឆាំងនឹងពលរដ្ឋស៊ីវិលឯកត្តជនដែលមិនចូលរួមដោយផ្ទាល់ក្នុងអរិភាព។

(ii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអគារ ឧបករណ៍ សម្ភារៈសុខាភិបាល និង ឧបករណ៍ដឹកជញ្ជូនវេជ្ជសាស្ត្រ ព្រមទាំងបុគ្គលិកពេទ្យ ដោយប្រើប្រាស់និមិត្តសញ្ញាដោយឡែកៗនៃអនុសញ្ញាទីក្រុងហ្សឺណែវ តាមច្បាប់អន្តរជាតិ។

(iii) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងនឹងមន្ត្រី  ប៉ុស្តិ៍ទីតាំង ឧបករណ៍ សម្ភារៈ ឬ យានជំនិះពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាព ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ដរាបណាពួកគេមានសិទ្ធិទទួលបានការការពារ ដែលមានឱ្យដល់ពលរដ្ឋស៊ីវិល ឬវត្ថុស៊ីវិល តាមច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ។

(iv) ការដឹកនាំដោយចេតនានូវការវាយប្រហារប្រឆាំងនឹងអគារ ដែលប្រើប្រាស់សម្រាប់គោលបំណងសាសនា ការអប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬគោលបំណងសប្បុរសធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីពេទ្យ និង ទីកន្លែងដែលមានអ្នកជំងឺ និង អ្នករបួស ប្រមូលផ្តុំដោយទីកន្លែងមិនមែនជាចំណុចគោលដៅយោធា។

(v) ការចូលលួចប្លន់ទីក្រុង ឬកន្លែងណាមួយ ទោះបីជាធ្វើឡើងដោយការវាយតប់ក៏ដោយ។

(vi) ការប្រព្រឹត្តការចាប់រំលោភ ទាសកម្មផ្លូវភេទ ពេស្យាកម្មដោយដាក់បង្ខំ ការមានគភ៌ដោយបង្ខំ ដូចមានកំណត់និយមន័យក្នុងមាត្រា7 កថាខ័ណ្ឌ2(ច) វណ្ឌកម្មដោយដាក់បង្ខំ និង អំពើបំពានផ្លូវភេទក្នុងទ្រង់ទ្រាយណាផ្សេងទៀត ក៏បង្កើតបានជាការបំពានដ៏ធ្ងន់ធ្ងរលើមាត្រា3រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួនដែរ។

(vii) ការកេណ្ឌ និងបញ្ចូលកុមារអាយុក្រោម15ឆ្នាំឱ្យចូលក្នុងកម្លាំងឬក្រុមប្រដាប់អាវុធ ឬការប្រើប្រាស់ពួកគេឱ្យបម្រើការយ៉ាងសកម្មក្នុងអរិភាព។

(viii) ការបញ្ជាឱ្យផ្លាស់ទីលំនៅរបស់ជនស៊ីវិលដោយសារហេតុផលដែលទាក់ទងនឹងជម្លោះ លើកលែងតែពេលជាប់ពាក់ព័ន្ធនឹងសន្តិសុខរបស់ជនស៊ីវិលផ្ទាល់ ឬហេតុផលយោធាចាំបាច់ទាមទារខ្លាំង។

(ix) ការសម្លាប់ ឬការធ្វើឱ្យរងរបួសដល់ពលទាហានដែលក្បត់។

(x) ការប្រកាសថាមិនផ្តល់ការត្រាប្រណីណាមួយ។

(xi) ការដាក់ជនដែលស្ថិតនៅក្នុងអំណាចនៃភាគីមួយទៀតក្នុងជម្លោះឱ្យរងការធ្វើកាយវិកល ឬការពិសោធខាងវេជ្ជសាស្ត្រ ទន្តសាស្ត្រដល់ជនពាក់ព័ន្ធនោះទេ ដែលមិនធ្វើឡើងដើម្បីប្រយោជន៍ជននោះ និង ដែលបណ្តាលឱ្យជននោះស្លាប់ឬធ្វើឱ្យជននោះរងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់សុខភាព។

(xii) ការបំផ្លាញ ការរឹបអូសយកទ្រព្យសម្បត្តិរបស់បច្ចាមិត្ត លើកលែងតែការបំផ្លាញ ឬការរឹបអូសយកនោះជាតម្រូវការចាំបាច់ខ្លាំងដោយសារជម្លោះ។

(ច) កថាខ័ណ្ឌទី2(ង) អនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមែនលក្ខណៈអន្តរជាតិហើយដូច្នេះមិនអនុវត្តចំពោះស្ថានភាពចលាចលនិងភាពតានតឹងផ្ទៃក្នុង ដូចជាកុបកម្ម អំពើហិង្សាម្តងម្កាលនិងហិង្សារឺអំពើផ្សេងៗដែលមានលក្ខណៈស្រដៀងគ្នា។ វាអនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលកើតមានឡើងនៅក្នុងទឹកដីរបស់រដ្ឋមួយនៅពេលមានជម្លោះប្រដាប់អាវុធរ៉ាំរ៉ៃរវាងអាជ្ញាធររដ្ឋាភិបាលនិងក្រុមប្រដាប់អាវុធ។

## Ethnic Cleansing

Ethnic cleansing has not been recognized as an independent crime under international law. In the context of the war in former Yugoslavia, a United Nations Commission of Experts defined it as:

**ការលុបបំបាត់ជាតិសាសន៍**

**ការលុបបំបាត់ជាតិសាសន៍**មិនទាន់ត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មដាច់ដោយឡែកក្រោមច្បាប់អន្តរជាតិទេ។ នៅក្នុងបរិបទនៃសង្គ្រាមនៅក្នុងអតីតយូហ្គោស្លាវី ក្រុមអ្នកជំនាញនៃគណៈកម្មការអង្គការសហប្រជាជាតិបានកំណត់វាជា

**Interim Report of the Commission of Experts Established Pursuant to Security Council Resolution 780 (1992),**
***U.N. SCOR, U.N. Doc. S/25274 (26 January 1993), at 16***

"… rendering an area ethnically homogeneous by using force or intimidation to remove persons of given groups from the area,"

**Final Report of the Commission of Experts Established Pursuant to United Nations Security Council Resolution 780 (1992),**
***U.N. SCOR, U.N. Doc. S/1994/674 (27 May 1994), Annex, at 3, 33***

"… a purposeful policy designed by one ethnic or religious group to remove by violent and terror-inspiring means the civilian population of another ethnic or religious group from certain geographic areas."

**របាយការណ៍បណ្តោះអាសន្ននៃគណៈកម្មការអ្នកជំនាញការត្រូវបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចលេខ 780(1992) របស់ក្រុមប្រឹក្សាសន្តិសុខ U.N. SCOR, U.N. Doc. S/25274 (26 ខែមករាឆ្នាំ 1993) នៅ16**

"… ការបង្កើតចេញតំបន់សភាគ(ហូម៉ូជីនាស)មួយដោយប្រើកម្លាំងឬការបំភិតបំភ័យដើម្បីដកក្រុមមនុស្សឱ្យចេញពីតំបន់នោះ"

**របាយការណ៍ចុងក្រោយរបស់គណៈកម្មការអ្នកជំនាញការត្រូវបានបង្កើតឡើងតាមអនុលោមសេចក្តីសម្រេចលេខ 780(1992) របស់ក្រុមប្រឹក្សាសន្តិសុខ**

**U.N. SCOR, U.N. Doc. S/1994/674 (27 ឧសភា 1994) ឧបសម្ព័ន្ធ 3 និង 33**

"... គោលនយោបាយដែលបានរៀបចំឡើងដោយជាតិសាសន៍ឬសាសនាមួយក្រុមក្នុងបំណងដើម្បី

ដកចេញក្រុមប្រជាជនស៊ីវិលមកពីជាតិសាសន៍ឬក្រុមសាសនាផ្សេងមួយទៀតពីតំបន់ភូមិសាស្ត្រណាមួយដោយប្រើមធ្យោបាយអំពើហិង្សានិងគំនិតបំផុសភេរវកម្ម"

The same Commission of Experts stated that the coercive practices used to remove the civilian population can include: murder, torture, arbitrary arrest and detention, extrajudicial executions, rape and sexual assaults, severe physical injury to civilians, confinement of civilian population in ghetto areas, forcible removal, displacement and deportation of civilian population, deliberate military attacks or threats of attacks on civilians and civilian areas, use of civilians as human shields, destruction of property, robbery of personal property, attacks on hospitals, medical personnel, and locations with the Red Cross/Red Crescent emblem,among others.

ក្រុមអ្នកជំនាញនៃគណៈកម្មការដដែលបានថ្លែងថាការអនុវត្តការបង្ខិតបង្ខំដើម្បីលុបបំបាត់ជនស៊ីវិលអាចរួមមាន៖ មនុស្សឃាត ការធ្វើទារុណកម្ម ការចាប់ខ្លួននិងឃុំខ្លួនតាមទំនើងចិត្ត ការសម្លាប់ក្រៅប្រព័ន្ធតុលាការ ការរំលោភនិងបំពានផ្លូវភេទ ការបង្ករបួសរូបរាងកាយធ្ងន់ធ្ងរដល់ជនស៊ីវិល ការបង្ខាំងប្រជាជនស៊ីវិលនៅក្នុងតំបន់ឃើសអើង ការជម្លៀសនិងការនិរទេសប្រជាជនស៊ីវិល ការវាយប្រហារឬគំរាមកំហែងយោធាលើជនស៊ីវិលនិងតំបន់ស៊ីវិល ការប្រើជនស៊ីវិលជាខែលមនុស្ស ការបំផ្លាញទ្រព្យសម្បត្តិ ការប្លន់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការវាយប្រហារទៅលើមន្ទីរពេទ្យ បុគ្គលិកពេទ្យនិងទីតាំងដែលមានទង់សញ្ញាអឌ្ឍចន្ទក្រហម/កាកបាទក្រហម ក្នុងចំណោមសកម្មភាពផ្សេងៗទៀត។

The Commission of Experts added that these practices can "... constitute crimes against humanity and can be assimilated to specific war crimes. Furthermore, such acts could also fall within the meaning of the Genocide Convention."

ក្រុមអ្នកជំនាញបានបន្ថែមថាការអនុវត្តទាំងនេះអាច "... ចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងអាចបញ្ចូលជាមួយបទឧក្រិដ្ឋកម្មសង្គ្រាមជាក់លាក់នានា។ លើសពីនេះទៀតអំពើបែបនេះរាប់បញ្ចូលនឹងអត្ថន័យនៃអនុសញ្ញាប្រល័យពូជសាសន៍" ។

Prevention means acting early…
Together with the commitment to
Accountability, we owe this to the
millions of victims of the horrific international crimes of the past
– and those whose lives we may be able to save in the future.

Secretary General Ban Kim-moon

ការបង្ការមានន័យថា ការធ្វើសកម្មភាពទុកជាមុន......

ទាំងអស់គ្នារួមទាំងការប្តេជ្ញាចិត្តចំពោះការទទួលខុសត្រូវ យើងជំពាក់ជនរងគ្រោះរាប់លាននាក់ នៃបទឧក្រិដ្ឋដ៏សហាវដែលមានលក្ខណៈអន្តរជាតិក្នុងពេលកន្លងមក ហើយជីវិតជនរងគ្រោះដែលយើងអាចជួយបាននៅពេលអនាគត។